**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ក្របខ័ណ្ឌគោលនយោបាយ
# ស្តីពី
# ការអភិវឌ្ឍមូលបត្ររដ្ឋ
# ២០២៣ - ២០២៨

រៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ខែវិច្ឆិកា ឆ្នាំ២០២៣

# បុព្វកថា

ក្រោយការបិទបញ្ចប់ជាស្ថាពរនូវសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃ, តាមរយៈ**នយោបាយឈ្នះ - ឈ្នះ** របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងការអនុវត្តគោលនយោបាយជាតិគន្លឹះៗ កម្ពុជាបានឆ្លងកាត់បរិវត្តកម្មជាបន្តបន្ទាប់ ដោយបានប្រែក្លាយពីវាលពិឃាត មកជាការរស់រានមានជីវិត, ពីប្រទេសដែលត្រូវបានបំផ្លាញខ្ទេចខ្ទីដោយការហែកហួរអូសបន្លាយរាប់ទសវត្សរ៍ មកជាប្រទេសមានសុខសន្តិភាព និងការឯកភាពជាតិពេញបរិបូរណ៍, ពីប្រទេសពោរពេញដោយភាពក្រីក្រតោកយ៉ាក មកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងត្រៀមចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ប្រកបដោយភាពជឿជាក់ ដើម្បីឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

សមិទ្ធផលធំធេងមិនអាចកាត់ថ្លៃបានទាំងនេះ បូករួមទាំងភាពជោគជ័យក្នុងការគ្រប់គ្រងស្ថានការណ៍នៃជំងឺកូវីដ-១៩ និងការងើបឡើងវិញយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ច, ការបំពេញតួនាទីជាប្រធានប្តូរវេន និងជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា ព្រមទាំងការធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍កីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ គឺជាសក្ខីភាពដែលបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីនយោបាយដឹកនាំដ៏ត្រឹមត្រូវ និងប្រាកដនិយមរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់ និងកាច់ចង្កូតជោគវាសនាប្រទេសជាតិ។

ចាប់តាំងពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៥ ក្នុងពេលដែលកម្ពុជាមានឋានៈជាប្រទេសមានចំណូលទាប ដៃគូអភិវឌ្ឍនានា បានផ្តល់នូវកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការពេញទំហឹងក្នុងទម្រង់ជាហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់ ដែលឧបករណ៍ហិរញ្ញប្បទានទាំងនេះត្រូវបានប្រើប្រាស់ជាប្រភពទុនដ៏សំខាន់សម្រាប់ការវិនិយោគសាធារណៈក្នុងវិស័យដែលមានផលិតភាពសេដ្ឋកិច្ច និងជំរុញការហក់ឡើងនៃកំណើននៅកម្ពុជា។ ជាមួយនឹងការសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប កាលពីឆ្នាំ២០១៥ និងការបោះជំហានយ៉ាងស្វាហាប់ឈានឡើងក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ ខាងមុខ កម្ពុជាប្រឈមនឹងការបាត់បង់លក្ខខណ្ឌអនុគ្រោះពីប្រភពហិរញ្ញប្បទានប្រពៃណីទាំងពីរខាងលើ និងត្រូវអនុវត្តតាមលក្ខខណ្ឌហិរញ្ញប្បទានថ្មី ដែលផ្អែកតាមធម្មនុញ្ញនៃដៃគូអភិវឌ្ឍ ប្រភពហិរញ្ញប្បទានឥតសំណងកាន់តែរីងស្ងួត និងកម្រិតសម្បទាននៃឥណទានកាន់តែទាបជាងមុន ជាហេតុធ្វើឱ្យថ្លៃដើមនៃការខ្ចីកើនឡើង។

បរិការណ៍នេះ ទាមទារឱ្យកម្ពុជាត្រូវពង្រឹងសមត្ថភាព និងភាពជាម្ចាស់ក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យកាន់តែទូលំទូលាយជាងមុន ទាំងការធ្វើពិពិធកម្មស្វែងរកដៃគូអភិវឌ្ឍថ្មីបន្ថែមលើដៃគូអភិវឌ្ឍប្រពៃណី និងទាំងការធ្វើពិពិធកម្មស្វែងរកឧបករណ៍ហិរញ្ញប្បទានថ្មី ដើម្បីបង្កើនវិនិយោគសាធារណៈលើវិស័យអាទិភាពជាយុទ្ធសាស្ត្រជាពិសេស វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងអាចទ្រទ្រង់ចីរភាពនៃកំណើនរយៈពេលវែង សំដៅជំរុញការកសាងមូលដ្ឋានគ្រឹះមួយរឹងមាំ សម្រាប់ដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ស្របតាមយុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១។

ឆ្លើយតបទៅនឹងបរិការណ៍ខាងលើ, រាជរដ្ឋាភិបាលសម្លឹងឃើញថា ការអភិវឌ្ឍមូលបត្ររដ្ឋ គឺជាមធ្យោបាយសក្តានុពលមួយ ក្នុងការកៀរគរទុនពីទីផ្សារ ដែលជាប្រភពហិរញ្ញប្បទានជាតិថ្មីមួយបន្ថែមទៀត សម្រាប់យកមកបំពេញតម្រូវការវិនិយោគសាធារណៈ ដើម្បីរួមចំណែកអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយចីរភាព, បរិយាប័ន្ន, និងភាពធន់នឹងវិបត្តិ ក្នុងរយៈពេលមធ្យម និងវែង។ ទន្ទឹមនេះ, វត្តមានមូលបត្ររដ្ឋ ក៏នឹងធ្វើឱ្យទីផ្សារមូលបត្រកម្ពុជាមានលក្ខណៈពេញលេញ ដែលជាកត្តាសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុឱ្យកាន់តែគ្រប់ជ្រុងជ្រោយផងដែរ។

ក្នុងន័យនេះ, ដើម្បីតម្រង់ទិសលើការអភិវឌ្ឍមូលបត្ររដ្ឋសម្រាប់រយៈពេលមធ្យម និងវែងខាងមុខ រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវ **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** នាពេលនេះ សំដៅគ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។

ឆ្លៀតក្នុងឱកាសនេះ, ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមការដឹកនាំរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** ដែលបានខិតខំរៀបចំ **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** នេះឡើង ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាជាមួយនឹងយុទ្ធសាស្ត្រពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។

ជាចុងក្រោយ, ខ្ញុំសូមណែនាំ និងប្រគល់ភារកិច្ចជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកដឹកនាំសម្របសម្រួលលើការតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការជាអាទិភាពនានា ដែលបានដាក់ចេញឱ្យទទួលបានជោគជ័យ និងមានប្រសិទ្ធភាព។ ជាមួយគ្នានេះ, ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គ្រប់តួអង្គពាក់ព័ន្ធទាំងអស់នៃវិស័យមូលបត្រ នឹងចូលរួមសហការឱ្យបានពេញលេញក្នុងការអនុវត្តរាល់វិធានការគោលនយោបាយដែលបានដាក់ចេញក្នុង **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** នេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៨ រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# អារម្ភកថា

ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ កម្ពុជារក្សាបាននូវសុខសន្តិភាព, ស្ថិរភាពនយោបាយ និងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពប្រយ័ត្នប្រយែងខ្ពស់ ដែលជាមូលដ្ឋានគ្រឹះក្នុងការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាប្រចាំឆ្នាំជាមធ្យម ៧% ក្រោមការដឹកនាំដ៏ឆ្នើមប្រកបដោយគតិបណ្ឌិត, ចក្ខុវិស័យវែងឆ្ងាយ និងឆន្ទៈនយោបាយមុតស្រួចរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**។ ទន្ទឹមនេះ, បើទោះជាទទួលរងនូវផលប៉ះពាល់ខ្លាំងពីវិបត្តិនៃជំងឺកូវីដ-១៩ និងឥទ្ធិពលពីបញ្ហាសកលមួយចំនួនក្តី, ក៏សេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងវិញពីកំណើនអវិជ្ជមាននៅ ឆ្នាំ២០២០ មកកំណើនក្នុងអត្រា **៣%** នៅឆ្នាំ២០២១ និង **៥,២%** នៅឆ្នាំ២០២២ ហើយរំពឹងថានឹងកើនដល់ **៥,៦%** នៅឆ្នាំ២០២៣ ដែលការសម្រេចបាននូវកំណើនដ៏ល្អប្រសើរបែបនេះ ឆ្លុះបញ្ចាំងឱ្យឃើញពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ និងកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនោះ ការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាព គឺជាសមាសភាគដ៏សំខាន់មួយ។

ក្នុងបរិការណ៍អភិវឌ្ឍថ្មីនៃសេដ្ឋកិច្ច, កម្ពុជាពុំអាចនៅតែបន្តពឹងផ្អែកខ្លាំងលើប្រភពហិរញ្ញប្បទានសម្បទានពីក្រៅប្រទេសទៀតទេ ខណៈដែលកម្ពុជាមានសក្តានុពលខ្លាំងក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយបន្ថែមទៀត សម្រាប់បំពេញតម្រូវការទុនវិនិយោគសាធារណៈ។

តាមរយៈនេះ, ក្នុងគោលដៅជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ ស្របតាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំច្បាប់ស្តីពីមូលបត្ររដ្ឋថ្មី ដែលត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត តាមរយៈព្រះរាជក្រមលេខ នស/រកម/១២២០/០៤០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ និងបានរៀបចំនូវ «**ក្របខ័ណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ**» ជាជំហានដំបូង ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកាលពីដើមខែតុលា ឆ្នាំ២០២១ ដោយផ្តោតសំខាន់លើការដាក់ចេញនូវកញ្ចប់វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ ក្នុងការកៀរគរទុនពីទីផ្សារតាមរយៈការសាកល្បងបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូងនៅឆ្នាំ២០២២ សម្រាប់យកមកបំពេញតម្រូវការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិនៃជំងឺកូវីដ-១៩។

ជាជំហានឆ្ពោះទៅកសាងប្រព័ន្ធគ្រប់គ្រងការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋឱ្យបានរឹងមាំ និងគ្រប់ជ្រុងជ្រោយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំ «**ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨**» ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាលនាពេលនេះ ក្នុងចក្ខុវិស័យអភិវឌ្ឍមូលបត្ររដ្ឋ ដើម្បីធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន តាមរយៈការកៀរគរទុនពីទីផ្សារមកបំពេញតម្រូវការវិនិយោគសាធារណៈ និងរួមចំណែកអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ សំដៅពង្រឹងភាពប្រកួតប្រជែង និងជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន។

ក្នុងគោលបំណងគ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ, ក្របខ័ណ្ឌគោលនយោបាយនេះ បានដាក់ចេញនូវវិធានការជាអាទិភាព ជា ២ ដំណាក់កាល រួមមាន៖

**ក. ដំណាក់កាលទី១ (ឆ្នាំ២០២៣-២០២៦)** បង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយពេញលេញ សម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស ក្នុងនោះ មានចង្កោមសកម្មភាពដែលត្រូវអនុវត្ត ដូចខាងក្រោម៖

១. បន្តពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

២. រៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទុនពីការបោះផ្សាយលក់មូលបត្ររដ្ឋ

៣. បន្តអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ

៤. រៀបចំយន្តការសម្របសម្រួលដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណាត់ថ្នាក់ឥណទានរបស់ប្រទេស

៥. សិក្សារៀបចំយន្តការបោះផ្សាយសញ្ញាបណ្ណរដ្ឋតាមវិស័យ

៦. ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស។

**ខ. ដំណាក់កាលទី២ (ឆ្នាំ២០២៧ - ២០២៨)** ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធគ្រប់គ្រង សម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស ព្រមទាំងចាប់ផ្តើមសិក្សា និងត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុនក្នុងការឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស៖

១. ពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីរួមប្រតិបត្តិការ

២. ពិនិត្យ និងកែលម្អទីផ្សារមូលបត្ររដ្ឋ

៣. សិក្សាយន្តការបោះផ្សាយមូលបត្ររដ្ឋនៅក្រៅប្រទេស

៤. ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស។

ក្នុងនាមក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងខ្លួនខ្ញុំផ្ទាល់, ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ដែលបានអនុម័ត និងដាក់ឱ្យអនុវត្តនូវ **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** ដ៏មានសារៈសំខាន់នេះ។ ទន្ទឹមនេះ, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះក្រុមការងារបច្ចេកទេសរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ដែលមានឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធាន និងឯកឧត្តម **ប៉ែន ធីរុទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអនុប្រធានប្រចាំការ ព្រមទាំងលេខាធិការដ្ឋាន ដឹកនាំដោយលោក **ម៉ាង សុតារ៉ា** អគ្គនាយករង នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក្នុងការរៀបចំក្របខ័ណ្ឌគោលនយោបាយនេះ ប្រកបដោយភាពជាម្ចាស់ និងស្មារតីទទួលខុសត្រូវខ្ពស់។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធនានាក្នុងវិស័យមូលបត្រ ប្តេជ្ញានឹងអនុវត្តរាល់វិធានការគោលនយោបាយ ដែលបានដាក់ចេញក្នុង **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** នេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

**បុព្វកថា** .................... i
**អារម្ភកថា** .................... iii
**ខ្លឹមសារសង្ខេប** .................... vi
**បញ្ជីពាក្យកាត់** .................... ix
**ជំពូកទី១៖ សេចក្តីផ្តើម** .................... ១
១.១. សាវតារ .................... ១
១.២. សារៈសំខាន់ .................... ២
**ជំពូកទី២៖ ចក្ខុវិស័យ គោលបំណង និងគោលដៅ** .................... ៤
២.១. ចក្ខុវិស័យ .................... ៤
២.២. គោលបំណង និងគោលដៅ .................... ៤
**ជំពូកទី៣៖ ការអភិវឌ្ឍមូលបត្ររដ្ឋ៖ បទពិសោធន៍ជាអន្តរជាតិ និងបរិការណ៍កម្ពុជា** .... ៥
៣.១. បទពិសោធន៍ជាអន្តរជាតិ .................... ៥
៣.២. បរិការណ៍កម្ពុជា .................... ២១
**ជំពូកទី៤៖ បញ្ហាប្រឈម និងកាលានុវត្តភាព** .................... ៣៣
៤.១.បញ្ហាប្រឈម .................... ៣៣
៤.២. កាលានុវត្តភាព .................... ៣៤
**ជំពូកទី៥៖ វិធានការគោលនយោបាយ** .................... ៣៧
៥.១. វិធានការគោលនយោបាយដំណាក់កាលទី១ (ឆ្នាំ២០២៣ - ២០២៦) .................... ៣៧
៥.២. វិធានការគោលនយោបាយដំណាក់កាលទី២ (ឆ្នាំ២០២៧ - ២០២៨) .................... ៣៩
**ជំពូកទី៦៖ យន្តការតាមដាន, ត្រួតពិនិត្យ, វាយតម្លៃ, និងដោះស្រាយបញ្ហាប្រឈម** .... ៤១
៦.១. យន្តការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃ .................... ៤១
៦.២. យន្តការដោះស្រាយបញ្ហាប្រឈម .................... ៤១
**ជំពូកទី៧៖ សេចក្តីសន្និដ្ឋាន** .................... ៤២

**ឧបសម្ព័ន្ធ៖**

- ឧបសម្ព័ន្ធទី១៖ សទ្ទានុក្រម
- ឧបសម្ព័ន្ធទី២៖ ផែនការសកម្មភាព
- ឧបសម្ព័ន្ធទី៣៖ ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស

# ខ្លឹមសារសង្ខេប

ស្ថិតក្នុងបរិការណ៍នៃសុខសន្តិភាពពេញលេញ, សុវត្ថិភាព និងស្ថិរភាពនយោបាយ រាជរដ្ឋាភិបាលកម្ពុជាក្រោមមាគ៌ាដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានកសាងនូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន ជាមួយនឹងសមិទ្ធផលដ៏ត្រចះត្រចង់ជាច្រើន តាមរយៈការអនុវត្តយុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រគន្លឹះៗ របស់រាជរដ្ឋាភិបាល។ ជាតថភាព, កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ៧% ក្នុងមួយឆ្នាំ នៅមុនវិបត្តិនៃជំងឺកូវីដ-១៩ និងបានប្រែក្លាយពីប្រទេសមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥ និងកំពុងត្រៀមចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ព្រមទាំងបានបោះជំហានឆ្ពោះទៅមុខ ដើម្បីក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

យ៉ាងណាមិញ, ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ បានធ្វើឱ្យសេដ្ឋកិច្ចពិភពលោកធ្លាក់ចុះយ៉ាងគំហុក ហើយក៏បានរុញច្រានសេដ្ឋកិច្ចកម្ពុជាធ្លាក់ក្នុងកំណើនអវិជ្ជមាន **-៣,១%** ក្នុងឆ្នាំ២០២០ ផងដែរ។ តាមរយៈការដាក់ចេញយ៉ាងសកម្ម និងបុរេសកម្ម និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកញ្ចប់វិធានការបន្ទាន់ និងវិធានការអន្តរាគមន៍នានា ក៏ដូចជា យុទ្ធនាការជាតិចាក់វ៉ាក់សាំង និងគោលនយោបាយនានា, រាជរដ្ឋាភិបាលអាចគ្រប់គ្រងស្ថានការណ៍នៃជំងឺរាតត្បាតនេះបានដោយជោគជ័យ ព្រមទាំងអាចស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញបានយ៉ាងឆាប់រហ័ស ជាមួយកំណើន **៣%** ក្នុងឆ្នាំ២០២១, **៥,២%** ក្នុងឆ្នាំ២០២២ និងរំពឹងថានឹងអាចកើនដល់ **៥,៦%** នៅឆ្នាំ២០២៣ ហើយស្ថានភាពបំណុលសាធារណៈកម្ពុជា នៅតែត្រូវបានវាយតម្លៃថាមាន **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»** ដដែល ដោយរាល់សូចនាករបំណុលគន្លឹះៗ សុទ្ធតែស្ថិតក្រោមពិតាន ក្នុងនោះ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈធៀបនឹង ផ.ស.ស. ក្នុងឆ្នាំ២០២២ និងព្យាករណ៍ នៅឆ្នាំ២០២៣ មានត្រឹមរង្វង់ **២៥%** ធៀបនឹងពិតាន **៥៥%**។

ក្នុងរបត់ថ្មីនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច, រាជរដ្ឋាភិបាលមើលឃើញអំពីកំណើនតម្រូវការហិរញ្ញប្បទានដ៏ច្រើនសន្ធឹកសន្ធាប់សម្រាប់ការវិនិយោគសាធារណៈ ដើម្បីបន្តអភិវឌ្ឍជាតិ ក៏ដូចជាជំរុញកំណើនសេដ្ឋកិច្ចតាមរយៈការស្តារឡើងវិញ, ការកែទម្រង់ និងការកសាងភាពធន់ ស្របពេលដែលថវិកាជាតិមួយផ្នែកធំ ត្រូវចំណាយលើមុខសញ្ញាអាទិភាពចំពោះមុខសម្រាប់ការបន្តអន្តរាគមន៍ និងអភិវឌ្ឍសង្គម សេដ្ឋកិច្ច ព្រមទាំងចំណាយផ្សេងទៀត ដែលបានកំណត់ក្នុងកម្មវិធី និងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

ក្នុងទិដ្ឋភាពនេះ, កម្ពុជាមានភាពចាំបាច់ក្នុងការកៀរគរទុនបន្ថែមឱ្យបានច្រើន ដើម្បីយកមកបំពេញតម្រូវការវិនិយោគសាធារណៈក្នុងវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬ ផលិតភាពផលិតកម្ម។ ទោះជាយ៉ាងនេះក្តី, រាជរដ្ឋាភិបាលដឹងច្បាស់ថា ប្រភពហិរញ្ញប្បទានសម្បទានពីក្រៅប្រទេសដែលកម្ពុជាធ្លាប់តែពឹងផ្អែករហូតមកនេះនឹងកាន់តែថមថយទៅ ខណៈដែលកម្ពុជាក៏មានលទ្ធភាពក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យកាន់តែទូលំទូលាយ ប្រកបដោយភាពជាម្ចាស់ និងឯករាជ្យជាងមុនផងដែរ។ លើមូលដ្ឋាននេះ, ប្រភពទុនដ៏សំខាន់មួយដែលរាជរដ្ឋាភិបាលបានចាប់ផ្តើមសាកល្បងកៀរគរដែរនោះ **គឺទីផ្សារមូលបត្រក្នុងប្រទេស តាមរយៈការបោះផ្សាយលក់មូលបត្ររដ្ឋ។**

ការបោះផ្សាយលក់មូលបត្ររដ្ឋ មិនត្រឹមតែជាមធ្យោបាយគន្លឹះក្នុងការកៀរគរទុនមកបំពេញតម្រូវការហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែ ក៏រួមចំណែកផងដែរដល់ការពង្រឹងលំហរសារពើពន្ធ ឬស្ថានភាព

ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល និងបង្កើតឡើងនូវក្របខ័ណ្ឌយន្តការហិរញ្ញប្បទានជាតិមួយ សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន ក៏ដូចជាការជំរុញអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែស៊ីជម្រៅ ក្នុងរយៈពេលមធ្យម និងវែងទៅមុខ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្តនូវ **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** ក្នុងចក្ខុវិស័យ **អភិវឌ្ឍមូលបត្ររដ្ឋ ដើម្បីធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានតាមរយៈការកៀរគរទុនពីទីផ្សារមកបំពេញតម្រូវការវិនិយោគសាធារណៈ និងរួមចំណែកអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ សំដៅពង្រឹងភាពប្រកួតប្រជែង និងជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន។** ក្របខ័ណ្ឌគោលនយោបាយនេះមានគោលបំណងគ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើ ក្របខ័ណ្ឌគោលនយោបាយនេះ ដាក់ចេញនូវវិធានការគោលនយោបាយក្នុងការកសាងឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយ សម្រាប់ការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ នៅក្នុងប្រទេស និងត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុនក្នុងការឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋ នៅក្រៅប្រទេស ដូចខាងក្រោម៖

**ក. ដំណាក់កាលទី១ (ឆ្នាំ២០២៣-២០២៦)** បង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយពេញលេញ សម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស ក្នុងនោះ មានចង្កោមសកម្មភាពដែលត្រូវអនុវត្ត ដូចខាងក្រោម៖

១. បន្តពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្ត
២. រៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទុនពីការបោះផ្សាយលក់មូលបត្ររដ្ឋ
៣. បន្តអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ ដោយរៀបចំនិម្មាបនកម្មទីផ្សារ (Market Architecture) តាមប្រព័ន្ធរបស់ធនាគារជាតិនៃកម្ពុជាទាំងស្រុង សម្រាប់រាល់ប្រតិបត្តិការបោះផ្សាយក្នុងទីផ្សារដំបូង, ជួញដូរក្នុងទីផ្សារបន្ទាប់, ទូទាត់ និងរក្សាទុកមូលបត្ររដ្ឋ
៤. រៀបចំយន្តការសម្របសម្រួលដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណាត់ថ្នាក់ឥណទានរបស់ប្រទេស
៥. សិក្សារៀបចំយន្តការបោះផ្សាយសញ្ញាបណ្ណរដ្ឋតាមវិស័យ
៦. ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស។

**ខ. ដំណាក់កាលទី២ (ឆ្នាំ២០២៧-២០២៨)** ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធគ្រប់គ្រង សម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស ព្រមទាំងចាប់ផ្តើមសិក្សា និងត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុនក្នុងការឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស៖

១. ពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីរួមប្រតិបត្តិការ
២. ពិនិត្យ និងកែលម្អទីផ្សារមូលបត្ររដ្ឋ
៣. សិក្សាយន្តការបោះផ្សាយមូលបត្ររដ្ឋនៅក្រៅប្រទេស
៤. ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស។

ទន្ទឹមនេះ, ដើម្បីជំរុញការអនុវត្តវិធានការគោលនយោបាយប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក្របខ័ណ្ឌគោលនយោបាយនេះ ក៏បានដាក់ចេញនូវយន្តការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃអំពីវឌ្ឍនភាពជាប្រចាំ និងយន្តការដោះស្រាយបញ្ហាប្រឈមផងដែរ។

«**ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨**» ត្រូវបានរៀបចំដោយធានាបាននូវសង្គតិភាព និងភាពប្រទាក់ក្រឡាជាមួយនឹងយុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១ ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រគន្លឹះៗរបស់រាជរដ្ឋាភិបាល ហើយត្រូវបានចាត់ទុកថាជា «**ឯកសាររស់**» ដែលអាចនឹងត្រូវបានកែសម្រួលជាយថាហេតុ ក្នុងករណីចាំបាច់ ដើម្បីធានាសង្គតិភាព និងការឆ្លើយតបទៅនឹងការវិវឌ្ឍនៃបរិការណ៍ចំពោះមុខជាក់ស្តែង ទាំងក្នុង និងក្រៅប្រទេស។

ការអនុវត្តដោយជោគជ័យនូវក្របខ័ណ្ឌគោលនយោបាយនេះ នឹងរួមចំណែកៈ ១) ពន្លឿនការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ក៏ដូចជា ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង និង ២) ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់ការវិនិយោគសាធារណៈ ដែលទាំងនេះ គឺជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព, បរិយាប័ន្ន និងមានភាពធន់។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទទួលបន្ទុកជាស្ថាប័នដឹកមុខក្នុងការសម្របសម្រួលលើការអនុវត្ត «**ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨**» ដោយត្រូវមានការចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

# បញ្ជីពាក្យកាត់

| | |
|---|---|
| ក.ស.ហ.វ. | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ធ.ជ.ក. | ធនាគារជាតិនៃកម្ពុជា |
| ប.ស.ស. | បេឡាជាតិសន្តិសុខសង្គម |
| ផ.ម.ក. | ផ្សារមូលបត្រកម្ពុជា |
| អ.ស.ប. | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល |
| ACMF | ASEAN Capital Markets Forum |
| ICMA | International Capital Market Association |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា ( Liquidity-Providing Collateralized Operation ) |
| NBCP | ផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា ( National Bank of Cambodia Platform ) |
| NCD | មូលបត្រអាចជួញដូរបាន ( Negotiable Certificate of Deposits ) |

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១. សាវតារ

រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរជាទីមោទនៈក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ ដោយរក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាជាមធ្យមប្រចាំឆ្នាំរង្វង់ **៧%** នៅមុនវិបត្តិនៃជំងឺកូវីដ-១៩ និងបានប្រែក្លាយពីប្រទេសមានចំណូលទាប មកជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅក្នុងឆ្នាំ២០១៥ និងកំពុងត្រៀមចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ព្រមទាំងបានបន្តដំណើរយ៉ាងសកម្មឥតឈប់ឈរ ដើម្បីសម្រេចចក្ខុវិស័យក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់ ស្របតាមគន្លងមាគ៌ាអភិវឌ្ឍន៍ដែលបានដាក់ចេញនូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ទោះជាយ៉ាងនេះក្តី, ដំណើរនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា ត្រូវបានទទួលរងនូវផលរំខានដោយសារឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ឆ្លើយតបទៅនឹងវិបត្តិនេះប្រកបដោយស្មារតីបុរេសកម្ម, រាជរដ្ឋាភិបាលបានដាក់ចេញ និងអនុវត្តយ៉ាងមុតមាំនូវកញ្ចប់វិធានការបន្ទាន់ និងវិធានការអន្តរាគមន៍នានា, យុទ្ធនាការជាតិចាក់វ៉ាក់សាំង ព្រមទាំងគោលនយោបាយ និងផែនការយុទ្ធសាស្រ្តជាតិគន្លឹះនានា ដែលជាលទ្ធផល កម្ពុជាទទួលបានជោគជ័យក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការគ្រប់គ្រងសភាព-ការណ៍នៃវិបត្តិនេះបានយ៉ាងល្អប្រសើរ ដោយបានជំរុញការងើបឡើងវិញពីកំណើនអវិជ្ជមានយ៉ាងឆាប់រហ័ស និងធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រឡប់មកប្រក្រតីភាព ជាពិសេស នៅតែបន្តរក្សាបាននូវស្ថានភាពបំណុលសាធារណៈប្រកបដោយ **«ចីរភាព»** និង **«ហានិភ័យកម្រិតទាប»** ដដែល។ ជាក់ស្តែង, កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច **៣%** ក្នុងឆ្នាំ២០២១, **៥,២%** ក្នុងឆ្នាំ២០២២ និងរំពឹងថានឹងកើនដល់ **៥,៦%** នៅឆ្នាំ២០២៣ ហើយរាល់សូចនាករបំណុលគន្លឹះៗ សុទ្ធតែស្ថិតនៅក្រោមពិតានកំណត់ ក្នុងនោះ អនុបាតតម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈ ធៀបនឹង ផ.ស.ស. ក្នុងឆ្នាំ២០២២ និងព្យាករណ៍នៅឆ្នាំ២០២៣ មានត្រឹមរង្វង់ **២៥%** ធៀបនឹងពិតាន **៥៥%**។

នៅក្នុងដំណាក់កាលនៃការអភិវឌ្ឍជាតិតាមគន្លងប្រក្រតីភាពថ្មី និងយុគនៃបដិវត្តន៍ឧស្សាហកម្មទី ៤.០, រាជរដ្ឋាភិបាលត្រូវការជាចាំបាច់នូវទុនវិនិយោគសាធារណៈដ៏ច្រើន សម្រាប់ធ្វើហិរញ្ញប្បទានគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តឌីជីថល និងបៃតង ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់បំផុត ដើម្បីជំរុញការតភ្ជាប់សេដ្ឋកិច្ច, ការអភិវឌ្ឍប្រកបដោយចីរភាព និងការធ្វើបរិវត្តកម្មឌីជីថលនៅកម្ពុជា។

បន្ថែមលើនេះ, ថវិកាជាតិមួយផ្នែកធំ នឹងត្រូវប្រើប្រាស់លើចំណាយអាទិភាពសំខាន់ៗជាច្រើន ជាពិសេសសម្រាប់៖ ១) ការបន្តអន្តរាគមន៍សង្គម សេដ្ឋកិច្ច សំដៅការពារអាយុជីវិត និងសុខភាពរបស់ប្រជាជន, ធានារក្សាលំនឹងសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាពលរដ្ឋ និង ២) ការបន្តអភិវឌ្ឍសង្គម តាមរយៈការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធសុខភាពសាធារណៈ ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម ព្រមទាំងកសាងភាពធន់នៃសង្គម, ការដំឡើងបៀវត្សជូនមន្រ្តីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, ការគាំទ្រសមត្ថភាពបច្ចេកទេសរដ្ឋបាលនៃស្ថាប័នរាជរដ្ឋាភិបាល។ល។ ដែលនាំឱ្យអតិរេកថវិកាសម្រាប់យកមកវិនិយោគសាធារណៈកាន់តែខើចទៅៗ។

កត្តាទាំងនេះ ជំរុញឱ្យរាជរដ្ឋាភិបាលចាំបាច់ត្រូវបង្កើនការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូ

អភិវឌ្ឍក្រៅប្រទេស ដើម្បីយកមកបំពេញតម្រូវការហិរញ្ញប្បទានសម្រាប់ការវិនិយោគសាធារណៈ និងគាំទ្រកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ទោះជាយ៉ាងនេះក្តី, ដោយមើលឃើញអំពី៖ ១) ស្ថានភាពសេដ្ឋកិច្ចសកលដែលបាននិងកំពុងរងឥទ្ធិពលពីសង្គ្រាមពាណិជ្ជកម្មនិងបច្ចេកវិទ្យា និងភាពកាន់តែតានតឹងនៃភូមិសាស្ត្រនយោបាយ និង ២) ការប្រឈមនឹងការបាត់បង់លក្ខខណ្ឌអនុគ្រោះខ្ពស់ នៃឥណទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍក្រៅប្រទេសនៅពេលកម្ពុជាឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ រាជរដ្ឋាភិបាលដឹងច្បាស់ថា កម្ពុជាមិនអាចនៅតែបន្តពឹងផ្អែកខ្លាំងលើប្រភពទុនជាប្រពៃណីពីក្រៅប្រទេសនេះទៀតទេ ខណៈដែលការរីកចម្រើននៃសេដ្ឋកិច្ច និងការរក្សាបាននូវចីរភាពបំណុលសាធារណៈ បាននិងកំពុងធ្វើឱ្យកម្ពុជាមានលទ្ធភាពក្នុងការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យកាន់តែទូលំទូលាយ ប្រកបដោយភាពជាម្ចាស់ និងឯករាជ្យជាងមុន ដើម្បីជានានិរន្តរភាពនៃការអភិវឌ្ឍទាំងក្នុងពេលធម្មតា និងទាំងក្នុងពេលមានវិបត្តិ។

ក្នុងន័យនេះ, ប្រភពហិរញ្ញប្បទានដ៏សំខាន់មួយ ដែលរាជរដ្ឋាភិបាលបានចាប់ផ្តើមសាកល្បងកៀរគរយកមកបំពេញតម្រូវការហិរញ្ញប្បទានវិនិយោគសាធារណៈដែរនោះ **គឺទីផ្សារមូលបត្រក្នុងប្រទេស តាមរយៈការបោះផ្សាយលក់មូលបត្ររដ្ឋ។**

## ១.២. សារៈសំខាន់

**«មូលបត្ររដ្ឋ»** សំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល រួមមាន៖ បណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ, សញ្ញាបណ្ណរតនាគារដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ និងមូលបត្ររដ្ឋផ្សេងទៀត។ មូលបត្ររដ្ឋ គឺជាប្រភេទឧបករណ៍ហិរញ្ញវត្ថុគ្មានហានិភ័យ ដែលតែងត្រូវបានប្រើប្រាស់ជាគោលសម្រាប់កំណត់ថ្លៃនៃឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ក៏ដូចជាមូលដ្ឋានប្រៀបធៀប និង/ឬ ធាតុចូល សម្រាប់ការបង្កើតគោល-នយោបាយ និងវិធានប្រតិបត្តិ នៃការបោះផ្សាយនិងជួញដូរមូលបត្រក្នុងវិស័យឯកជន ផងដែរ។

ការអភិវឌ្ឍមូលបត្ររដ្ឋ ពិតជាមានសារៈសំខាន់ណាស់ចំពោះការទ្រទ្រង់កំណើនសេដ្ឋកិច្ច, ការពង្រឹងលំហសារពើពន្ធ ឬស្ថានភាពហិរញ្ញវត្ថុសាធារណៈ, ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងសន្ទនីយភាព, ការអនុវត្តគោលនយោបាយរូបិយវត្ថុ ប្រកបដោយភាពបត់បែន និងឯករាជ្យភាព, ការជំរុញអភិវឌ្ឍវិស័យហិរញ្ញវត្ថុឱ្យកាន់តែស៊ីជម្រៅ ជាពិសេស ការបង្កើតបាននូវក្របខ័ណ្ឌយន្តការហិរញ្ញប្បទានជាតិមួយ សម្រាប់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន ក្នុងរយៈពេលមធ្យម និងវែង។

នៅក្នុងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច, ការបោះផ្សាយលក់មូលបត្ររដ្ឋ មិនត្រឹមតែជាមធ្យោបាយគន្លឹះក្នុងការកៀរគរទុនមកបំពេញតម្រូវការហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ តែក៏ជាឧបករណ៍សម្រាប់ធនាគារកណ្តាល ប្រើប្រាស់ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុផងដែរ ដើម្បីបង្កើនលទ្ធភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងរំហូររូបិយវត្ថុ និងសន្ទនីយភាពក្នុងសេដ្ឋកិច្ច។ បន្ថែមលើនេះ, មូលបត្ររដ្ឋអាចផ្តល់លទ្ធភាពដល់ធនាគារកណ្តាល ក្នុងការចូលធ្វើអន្តរាគមន៍ទីផ្សារពេលមានវិបត្តិតាមរយៈការចាក់បញ្ចូលសាច់ប្រាក់ (Quantitative Easing) ដើម្បីបំពេញតម្រូវការសន្ទនីយភាព។

ទន្ទឹមនេះ, ការបោះផ្សាយលក់មូលបត្ររដ្ឋ អាចជួយទ្រទ្រង់ដល់ការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ និងជំរុញការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានក្នុងស្រុក តាមរយៈការបង្កើតឱ្យមានឧបករណ៍ហិរញ្ញវត្ថុថ្មីៗ ដូចជា៖ ឧបករណ៍និស្សន្ទ (Derivative Instruments) និងឧបករណ៍ទីផ្សាររូបិយវត្ថុ (Money Market Instruments) ជាដើម សំដៅឈានទៅធ្វើសមាហរណកម្មទីផ្សារមូលធនក្នុងតំបន់ និងសកល ព្រមទាំងរួមចំណែកយ៉ាងសំខាន់ក្នុងការគ្រប់គ្រង

ហានិភ័យ និងរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុទាំងមូល។ ម៉្យាងវិញទៀត, មូលបត្ររដ្ឋ ជាឧបករណ៍វិនិយោគដែលមានសុវត្ថិភាព និងសន្ទនីយភាពខ្ពស់ សម្រាប់វិនិយោគិន ដោយផ្តល់នូវចំណូលការប្រាក់ថេរ និងទៀងទាត់ ហើយអាចត្រូវបានប្រើប្រាស់ជាវត្ថុធានាសម្រាប់ដាក់ប្រាតិភោគ ព្រមទាំងអាចឱ្យវិនិយោគិនដឹងជាមុនអំពីវេហូរសាច់ប្រាក់ពីការវិនិយោគ និងធ្វើពិពិធកម្មការវិនិយោគ។

ឈរលើទិដ្ឋភាពខាងលើ, ដើម្បីជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ និងក្នុងបរិបទនៃវិបត្តិជំងឺកូវីដ-១៩, រាជរដ្ឋាភិបាល បានគិតគូររៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ជា **២** ជំហាន ដែលក្នុងនោះ៖

- ជំហានទី១ គឺការអនុម័ត និងដាក់ឱ្យអនុវត្តនូវ **«ក្របខ័ណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ»** កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ដោយផ្តោតសំខាន់លើការដាក់ចេញនូវកញ្ចប់វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ និងផែនការសកម្មភាពជាក់លាក់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញក្នុងពេលវិបត្តិកន្លងមកនេះ និងដើម្បីបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូងឱ្យបានក្នុងឆ្នាំ២០២២ ដែលជាការសាកល្បងទីផ្សារ, និង
- ជំហានទី២ គឺការរៀបចំ និងដាក់ឱ្យអនុវត្ត **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** នេះ ដែលជាផែនទីបង្ហាញផ្លូវ សម្រាប់តម្រង់ទិសក្នុងការបន្តអភិវឌ្ឍមូលបត្ររដ្ឋឱ្យបានពេញលេញ ប្រកបដោយចីរភាព និងប្រសិទ្ធភាព តាមរយៈការដាក់ចេញនូវវិធានការក្នុងការកសាងនូវប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយ សម្រាប់ការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ។

**«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** ត្រូវបានរៀបចំដោយធានាបាននូវសង្គតិភាព និងភាពផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយ និងយុទ្ធសាស្ត្រជាតិគន្លឹះៗ ដូចជា៖ i) យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ii) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, iii) យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ, iv) យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ, v) យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥ ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត។

ក្របខ័ណ្ឌគោលនយោបាយនេះ ត្រូវបានចាត់ទុកជា **«ឯកសាររស់»** ដែលអាចនឹងត្រូវបានកែសម្រួលជាយថាហេតុ ក្នុងករណីចាំបាច់ ដើម្បីធានាសង្គតិភាព និងការឆ្លើយតបទៅនឹងការវិវឌ្ឍនៃបរិការណ៍ចំពោះមុខជាក់ស្តែង ទាំងក្នុង និងក្រៅប្រទេស។

# ជំពូកទី២
# ចក្ខុវិស័យ គោលបំណង និងគោលដៅ

## ២.១. ចក្ខុវិស័យ

ក្របខ័ណ្ឌគោលនយោបាយនេះ មានចក្ខុវិស័យអភិវឌ្ឍមូលបត្ររដ្ឋ ដើម្បីធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានតាមរយៈការកៀរគរទុនពីទីផ្សារមកបំពេញតម្រូវការវិនិយោគសាធារណៈ និងរួមចំណែកអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុសំដៅពង្រឹងភាពប្រកួតប្រជែង និងជំរុញកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាប័ន្ន។

## ២.២. គោលបំណង និងគោលដៅ

ក្របខ័ណ្ឌគោលនយោបាយនេះ មានគោលបំណងគ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើ ក្របខ័ណ្ឌគោលនយោបាយនេះ មានគោលដៅកំណត់វិធានការគោលនយោបាយសម្រាប់៖

១) កសាងឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយ សម្រាប់ការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ នៅក្នុងប្រទេស ត្រឹមឆ្នាំ២០២៨, និង

២) ត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុនក្នុងការឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋ នៅក្រៅប្រទេសក្នុងកាលៈទេសៈចាំបាច់។

# ជំពូកទី៣
# ការអភិវឌ្ឍមូលបត្ររដ្ឋ៖ បទពិសោធន៍ជាអន្តរជាតិ និងបរិការណ៍កម្ពុជា

## ៣.១. បទពិសោធន៍ជាអន្តរជាតិ

ការអភិវឌ្ឍមូលបត្ររដ្ឋនៅក្នុងបណ្ដាប្រទេសនានា មានលក្ខណៈពិសេសដោយឡែកពីគ្នា អាស្រ័យទៅតាមរចនាសម្ព័ន្ធ, កម្រិតអភិវឌ្ឍន៍នៃសេដ្ឋកិច្ច, និងទីផ្សារមូលបត្ររបស់ប្រទេសនីមួយៗ។ ទោះជាយ៉ាងនេះក្ដី, ផ្អែកតាមការសិក្សាស្រាវជ្រាវ និងដកស្រង់បទពិសោធន៍ជាអន្តរជាតិ បង្ហាញថា ជារួម ការអភិវឌ្ឍមូលបត្ររដ្ឋប្រកបដោយប្រសិទ្ធភាព និងជោគជ័យ ទាមទារឱ្យមានការរៀបចំប្រព័ន្ធបោះផ្សាយនិងជួញដូរមូលបត្ររដ្ឋមួយរឹងមាំ និងគ្រប់ជ្រុងជ្រោយ ដែលរួមមាន ជាតុផ្សំចម្បងៗ ជាអាទិ៍៖ ក្របខ័ណ្ឌគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រ, យន្តការស្ថាប័ន/សម្របសម្រួល, និងទីផ្សារ ដូចមានបរិយាយលម្អិតតាមចំណុចនីមួយៗខាងក្រោម៖

### ៣.១.១. ក្របខ័ណ្ឌគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រ

#### ក. ក្របខ័ណ្ឌគតិយុត្ត

ការរៀបចំឱ្យមានក្របខ័ណ្ឌគតិយុត្តរឹងមាំ គឺជាបុរេលក្ខខណ្ឌមួយចាំបាច់ ដើម្បីធានាបាននូវទំនុកចិត្ត, យុត្តិធម៌, ប្រសិទ្ធភាព, និងតម្លាភាពនៃកិច្ចដំណើរការទីផ្សារ។ ជាទូទៅ, វិធានជាសារវន្តសម្រាប់ការបោះផ្សាយ និងគ្រប់គ្រងមូលបត្ររដ្ឋ ដែលត្រូវបានកំណត់នៅក្នុងច្បាប់ មានជាអាទិ៍៖ គោលការណ៍ និងសិទ្ធិអំណាចក្នុងការខ្ចី, យន្តការនិងនីតិវិធីបោះផ្សាយ, និងយន្តការស្ថាប័ន ជាដើម ដោយប្រទេសភាគច្រើនកំណត់វិធានទាំងនេះនៅក្នុងច្បាប់ស្ដីពីមូលបត្ររដ្ឋ ឯប្រទេសខ្លះទៀតកំណត់ជាផ្នែកមួយនៃច្បាប់ស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ហើយចំពោះទំហំបោះផ្សាយលក់មូលបត្ររដ្ឋប្រចាំឆ្នាំ ត្រូវបានកំណត់នៅក្នុងច្បាប់ថវិកាប្រចាំឆ្នាំ និង/ឬ លិខិតបទដ្ឋានពាក់ព័ន្ធប្រហាក់ប្រហែលដទៃទៀត។ ដោយឡែក, វិធានលម្អិតពាក់ព័ន្ធនានា ត្រូវបានកំណត់នៅក្នុងបទប្បញ្ញត្តិ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលចេញដោយរដ្ឋាភិបាល និង/ឬ ក្រសួងហិរញ្ញវត្ថុ ដើម្បីឱ្យមានភាពបត់បែនក្នុងការអនុវត្ត។ បន្ថែមលើនេះ, ដើម្បីធានាសណ្ដាប់ធ្នាប់ និងប្រសិទ្ធភាពនៃកិច្ចដំណើរការទីផ្សារ ប្រទេសជាច្រើនក៏បានដាក់ចេញផងដែរ នូវបទប្បញ្ញត្តិបន្ថែមមួយចំនួនផ្សេងទៀតពាក់ព័ន្ធនឹងការបោះផ្សាយ, ការជួញដូរ, ការទូទាត់សាច់ប្រាក់, និងការរក្សាទុកមូលបត្ររដ្ឋ ជាដើម។

#### ខ. ក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រ

ក្នុងគោលបំណងតម្រង់ទិស និងធានាប្រសិទ្ធភាពនៃការអភិវឌ្ឍមូលបត្ររដ្ឋ បណ្ដាប្រទេសនានាបានរៀបចំគោលនយោបាយ និង/ឬ យុទ្ធសាស្ត្រ ដោយកំណត់អំពីចក្ខុវិស័យ និងវិធានការនានា ព្រមទាំងដាក់ចេញផងដែរនូវផែនការសកម្មភាព ក៏ដូចជា យន្តការដោះស្រាយបញ្ហាប្រឈម និងយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តការងារជាប់ជាប្រចាំ។ ជាបទពិសោធន៍, ក្រុមប្រទេសដែលស្ថិតនៅក្នុងដំណាក់-កាលដំបូងនៃការអភិវឌ្ឍមូលបត្ររដ្ឋ ឬដែលទើបចាប់ផ្ដើមអភិវឌ្ឍមូលបត្ររដ្ឋ បានរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្ររយៈពេលមធ្យម ទៅវែង ដោយផ្ដោតសំខាន់លើការជំរុញការអភិវឌ្ឍជាតុផ្សំសំខាន់ៗ ដើម្បីគាំទ្រកិច្ចដំណើរការទីផ្សារ, កំណត់តួនាទី និងភារកិច្ចនៃស្ថាប័នពាក់ព័ន្ធ, រៀបចំ និងគ្រប់គ្រងប្រព័ន្ធគាំទ្រទីផ្សារហិរញ្ញវត្ថុ, ឬបញ្ជាបអន្តរកម្មហិរញ្ញវត្ថុ។ល។ ដោយឡែក, ក្រុមប្រទេសដែលទីផ្សារមូលបត្រមានការអភិវឌ្ឍ បានរៀបចំគោល-នយោបាយ និងយុទ្ធសាស្ត្ររយៈពេលខ្លី ទៅមធ្យម ដោយផ្ដោតសំខាន់លើការពង្រឹងប្រសិទ្ធភាពនៃកិច្ចដំណើរការក្នុងទីផ្សារ ដូចជា៖ ការជំរុញការអភិវឌ្ឍឧបករណ៍ថ្មីៗស្របតាមវិវឌ្ឍនាការនៃទីផ្សារ និងបច្ចេកវិទ្យា, ការពង្រឹង

ប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលសាធារណៈ, ការពង្រឹងការគ្រប់គ្រងហានិភ័យ ក៏ដូចជា ការធ្វើឱ្យប្រសើរឡើងនៃប្រព័ន្ធគាំទ្រទីផ្សារហិរញ្ញវត្ថុ ជាដើម។

បន្ថែមលើនេះ, ក្នុងទិសដៅជំរុញការចូលរួមវិនិយោគ និងពង្រីកមូលដ្ឋានវិនិយោគិនបន្ថែម ប្រទេសភាគច្រើនក៏បានដាក់ចេញផងដែរនូវគោលនយោបាយ និងយុទ្ធសាស្ត្រទាក់ទាញមួយចំនួន ដូចជា៖ ការផ្តល់បុព្វសិទ្ធិពិសេស, ការលើកទឹកចិត្តពន្ធដារសម្រាប់ក្រុមវិនិយោគិនគោលដៅ, ឬការកែសម្រួលលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមវិនិយោគ ជាដើម។ ជាការកត់សម្គាល់, ការលើកទឹកចិត្តពន្ធដារ ភាគច្រើនត្រូវបានអនុវត្តនៅប្រទេសដែលទើបចាប់ផ្តើមអភិវឌ្ឍមូលបត្ររដ្ឋ ឬដែលទីផ្សារមូលបត្ររដ្ឋពុំសូវមានការជួញដូរ។ បើទោះបីជាការលើកទឹកចិត្តពន្ធដារ អាចនឹងប៉ះពាល់ដល់ការប្រមូលពន្ធក្នុងរយៈពេលខ្លីក៏ពិតមែន ក៏ប៉ុន្តែ ការជំរុញសន្ទនីយភាពនៃការជួញដូរមូលបត្ររដ្ឋ នឹងផ្តល់បច្ច័យវិជ្ជមានត្រឡប់មកវិញដល់សេដ្ឋកិច្ច និងទីផ្សារហិរញ្ញវត្ថុទាំងមូល សម្រាប់រយៈពេលវែង។

### ៣.១.២. យន្តការស្ថាប័ន/សម្របសម្រួល

ទន្ទឹមនឹងការរៀបចំឱ្យមានក្របខ័ណ្ឌគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្ររឹងមាំ, ការរៀបចំយន្តការស្ថាប័ន/សម្របសម្រួល ដែលមានការបែងចែកមុខងារ និងភារកិច្ចទទួលបន្ទុកច្បាស់លាស់ និងប្រទាក់ក្រឡាគ្នាជាប្រព័ន្ធ ក៏ជាកត្តាដ៏សំខាន់នៅក្នុងការជំរុញការអភិវឌ្ឍមូលបត្ររដ្ឋផងដែរ។ ជាទូទៅ, ស្ថាប័នសំខាន់ៗដែលមានតួនាទីចូលរួមជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ ក៏ដូចជា កិច្ចដំណើរការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ មានជាអាទិ៍៖

**ក) ក្រសួងហិរញ្ញវត្ថុ** ជាសេនាធិការរបស់រដ្ឋាភិបាលទទួលបន្ទុកការងារបោះផ្សាយលក់មូលបត្ររដ្ឋ ដោយមានអគ្គនាយកដ្ឋាន ឬអង្គភាពទទួលបន្ទុកកិច្ចការគ្រប់គ្រងបំណុលសាធារណៈ ជាអង្គភាពប្រតិបត្តិ ព្រោះថា មូលបត្ររដ្ឋ មានចរិតជាបំណុលសាធារណៈ ហើយជាឧបករណ៍មួយដ៏សំខាន់របស់រដ្ឋាភិបាលក្នុងការកៀរគរទុនពីទីផ្សារសម្រាប់បំពេញតម្រូវការហិរញ្ញប្បទាន។ ផ្អែកតាមរចនាសម្ព័ន្ធនៃបណ្តាប្រទេសភាគច្រើន, អគ្គនាយកដ្ឋាន ឬអង្គភាពទទួលបន្ទុកនេះ មាននាយកដ្ឋាន ឬផ្នែកក្រោមឱវាទ ដើម្បីបំពេញភារកិច្ចចម្បងមួយចំនួន ដូចជា៖ រៀបចំផែនការនិងកាលវិភាគបោះផ្សាយ, សម្របសម្រួលការបោះផ្សាយ, តាមដាន និងវិភាគស្ថានភាពទីផ្សារ, គ្រប់គ្រងការធ្វើហិរញ្ញប្បទានពីការបោះផ្សាយ, អភិវឌ្ឍឧបករណ៍និងទីផ្សារមូលបត្ររដ្ឋ, ពង្រឹងទំនាក់ទំនងជាមួយវិនិយោគិន និងតួអង្គពាក់ព័ន្ធ ព្រមទាំងប្រតិបត្តិការពាក់ព័ន្ធនឹងការគ្រប់គ្រងមូលបត្ររដ្ឋ ជាដើម។

**ខ) ធនាគារកណ្តាល** ជាស្ថាប័នដែលមានតួនាទីគ្រប់គ្រងស្ថិរភាពថ្លៃ ដោយមានភារកិច្ចសំខាន់ៗ ជាអាទិ៍៖ អនុវត្តគោលនយោបាយរូបិយវត្ថុ, ត្រួតពិនិត្យវិស័យធនាគារ និងហិរញ្ញវត្ថុ, គ្រប់គ្រងប្រព័ន្ធទូទាត់ជាតិ, និងចាត់ចែងកិច្ចការទូទាត់ជូនរដ្ឋាភិបាល ជាដើម។ តាមរយៈនេះ, ធនាគារកណ្តាល គឺជាតួអង្គមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍមូលបត្ររដ្ឋ ដោយមានភារកិច្ចចូលរួមសម្របសម្រួល និងផ្តល់យោបល់លើការរៀបចំកិច្ចដំណើរការបោះផ្សាយ និងជួញដូរ, ការគ្រប់គ្រង, និងការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ ហើយភាគច្រើនត្រូវបានចាត់ជាអាណត្តិគាហក (Fiscal Agent) សម្រាប់ការបោះផ្សាយលក់មូលបត្ររដ្ឋ។

**គ) និយ័តករវិស័យមូលបត្រ** ជាស្ថាប័នមានភារកិច្ចគ្រប់គ្រង និងត្រួតពិនិត្យកិច្ចដំណើរការនៅក្នុងទីផ្សារមូលបត្រ ដើម្បីធានាឱ្យមានប្រសិទ្ធភាព, តម្លាភាព, ភាពយុត្តិធម៌ និងរបៀបរៀបរយ ព្រមទាំងជំរុញការជួញដូរមូលបត្រនៅក្នុងទីផ្សារបន្ទាប់ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

**ឃ) ផ្សារមូលបត្រ** ជាស្ថាប័នស្វ័យនិយ័តករ (Self-Regulatory Organization) ដើរតួជាប្រតិបត្តិករសម្រាប់ការរៀបចំ, សម្របសម្រួល និងគ្រប់គ្រងការជួញដូរមូលបត្រ។ នៅប្រទេសមួយចំនួនតូច, ផ្សារមូលបត្រក៏ត្រូវបានចាត់ជាអាណត្តិគាហក សម្រាប់ការបោះផ្សាយលក់មូលបត្ររដ្ឋផងដែរ ដើម្បីបើកឱ្យមានការចូលរួម

វិនិយោគលើមូលបត្ររដ្ឋកាន់តែទូលំទូលាយ ក៏ដូចជា បង្កើនប្រសិទ្ធភាពនៃការជួញដូរមូលបត្ររដ្ឋនៅក្នុងទីផ្សារបន្ទាប់ និងការគ្រប់គ្រងព័ត៌មានអំពីការជួញដូរមូលបត្ររដ្ឋនៅលើទីផ្សារ។

**ង) ប្រតិបត្តិកររក្សាទុកមូលបត្ររដ្ឋ** ជាស្ថាប័ន ឬអង្គភាពទទួលបន្ទុកការងារទូទាត់ និងរក្សាទុកមូលបត្ររដ្ឋ។ ជាទូទៅ, ធនាគារកណ្តាលដែលជាអាណត្តិគាហក តែងត្រូវបានចាត់ជាប្រតិបត្តិកររក្សាទុកមូលបត្ររដ្ឋ ដោយការអនុវត្តបែបនេះ អាចជួយពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងមូលបត្ររដ្ឋ ទាំងលើទិដ្ឋភាពថ្លៃ និងការគ្រប់គ្រងហានិភ័យ។ ដោយឡែក, ប្រទេសមួយចំនួនដែលទីផ្សារមានការអភិវឌ្ឍ និងមានការជួញដូរសកម្ម បានបង្កើតជាប្រតិបត្តិកររក្សាទុកមូលបត្ររួម (Central Securities Depository - CSD) តែម្តង ដើម្បីកាត់បន្ថយភាពបែកខ្ញែកនៃទីផ្សារមូលបត្រ និងធានាប្រសិទ្ធភាពនៃការទូទាត់ និងរក្សាទុកមូលបត្រ ដោយនៅប្រទេសខ្លះ CSD ជាបុត្រសម្ព័ន្ធនៃផ្សារមូលបត្រ ហើយនៅប្រទេសខ្លះទៀត ជាស្ថាប័នដោយឡែក។

**ច) សមាគមពាណិជ្ជករមូលបត្រ** ជាស្ថាប័នស្វ័យនិយ័តករ ដែលមានតួនាទីផ្សេងៗគ្នា អាស្រ័យទៅតាមស្ថានភាព និងតម្រូវការជាក់ស្តែងនៃទីផ្សាររបស់ប្រទេសទាំងនោះ។ ជាទូទៅ, សមាគមពាណិជ្ជករមូលបត្រមានតួនាទីចម្បង ជាអាទិ៍៖ សម្របសម្រួល និងជំរុញការជួញដូរមូលបត្ររដ្ឋនៅទីផ្សារបន្ទាប់; ចូលរួមគ្រប់គ្រងសណ្តាប់ធ្នាប់នៃទីផ្សារ តាមរយៈការដាក់ចេញបទប្បញ្ញត្តិ, វិធាន, ក្រមប្រតិបត្តិ, និងស្តង់ដា សម្រាប់ត្រួតពិនិត្យប្រតិបត្តិការផ្តល់សេវាហិរញ្ញវត្ថុពាក់ព័ន្ធប្រកបដោយវិជ្ជាជីវៈ; ប្រមូលផ្តុំ និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការជួញដូរមូលបត្រក្នុងទីផ្សារ; ការពារវិនិយោគិន; ពង្រឹងកិច្ចសន្ទនារវាងអ្នកពាក់ព័ន្ធ; បណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងវិស័យមូលបត្រ; និងកំណត់តម្លៃមូលបត្រនៅក្នុងទីផ្សារ ជាដើម។

ជាមួយគ្នានេះ, ក្នុងគោលបំណងធានានូវភាពប្រទាក់ក្រឡា និងសង្គតិភាពនៃការអនុវត្តការងាររបស់តួអង្គពាក់ព័ន្ធ ក្នុងការអភិវឌ្ឍមូលបត្ររដ្ឋប្រកបដោយប្រសិទ្ធភាព ប្រទេសមួយចំនួនបានបង្កើតយន្តការសម្របសម្រួលទាំងក្នុងកម្រិតគោលនយោបាយ ទាំងក្នុងកម្រិតបច្ចេកទេស និង/ឬ កម្រិតប្រតិបត្តិ តាមរយៈ៖ i) ការបង្កើតគណៈកម្មាធិការអន្តរស្ថាប័នទទួលបន្ទុកការងារអភិវឌ្ឍមូលបត្ររដ្ឋ ដឹកនាំដោយក្រសួងហិរញ្ញវត្ថុ និងមានសមាសភាពចូលរួមពីស្ថាប័នពាក់ព័ន្ធដូចជា៖ ធនាគារកណ្តាល, និយ័តករវិស័យមូលបត្រ, ស្ថាប័នស្វ័យនិយ័តករ, គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធំៗមួយចំនួន ដោយមានភារកិច្ចចម្បងក្នុងការកំណត់អំពីទិសដៅរួមនៃការអភិវឌ្ឍទីផ្សារ និងដាក់ចេញវិធានការដោះស្រាយបញ្ហាប្រឈមនានា; និង ii) ការបង្កើតក្រុមការងារកម្រិតបច្ចេកទេស និង/ឬ កម្រិតប្រតិបត្តិ ដើម្បីអនុវត្តផែនការសកម្មភាព ដែលដាក់ចេញដោយគណៈកម្មាធិការអន្តរស្ថាប័ន។

### ៣.១.៣. ទីផ្សារ

#### ក. ទីផ្សារដំបូង

ការរៀបចំឱ្យមានយន្តការការងារមួយច្បាស់លាស់សម្រាប់គាំទ្រកិច្ចដំណើរការទីផ្សារដំបូង គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការបោះផ្សាយលក់មូលបត្ររដ្ឋ ជាពិសេស នៅក្នុងដំណាក់កាលចាប់ផ្តើមនៃការអភិវឌ្ឍមូលបត្ររដ្ឋ។ ជាទូទៅ, ការរៀបចំទីផ្សារដំបូងប្រកបដោយប្រសិទ្ធភាពត្រូវប្រកាន់នូវគោលការណ៍ស្នូលចំនួន ៣ គឺ៖ តម្លាភាព, ភាពប៉ាន់ប្រមាណទុកជាមុនបាន, និងយន្តការទីផ្សារ ដោយផ្តោតលើកិច្ចការជាអាទិភាពមួយចំនួន មានជាអាទិ៍៖

- **ការរៀបចំផែនការបោះផ្សាយ**

ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការបោះផ្សាយលក់ និងគ្រប់គ្រងមូលបត្ររដ្ឋ ក៏ដូចជាការគ្រប់គ្រងបំណុលសាធារណៈជារួម, ក្រសួងហិរញ្ញវត្ថុត្រូវកំណត់ឱ្យបានជាក់លាក់ទុកជាមុនអំពីទំហំបោះផ្សាយប្រចាំឆ្នាំ ដោយធ្វើការវិភាគ និងព្យាករណ៍អំពីទំហំ និងពេលវេលានៃតម្រូវការហិរញ្ញប្បទាន។ ជាទូទៅ, ទំហំបោះផ្សាយ

ត្រូវបានកំណត់នៅក្នុងច្បាប់ថវិកាប្រចាំឆ្នាំ, យុទ្ធសាស្ត្រហិរញ្ញប្បទានប្រចាំឆ្នាំ, ឬលិខិតបទដ្ឋានប្រហាក់ប្រហែលដទៃទៀត ដែលអាចជាទំហំជាក់លាក់ ឬជាពិតាននៃការបោះផ្សាយ។ តាមរយៈនេះ, ស្ថាប័នបោះផ្សាយ ត្រូវរៀបចំផែនការបោះផ្សាយប្រចាំឆ្នាំ ដោយរំលេចអំពីព័ត៌មានមូលដ្ឋានមួយចំនួន ដូចជា៖ ទំហំបោះផ្សាយ, ឧបករណ៍មូលបត្ររដ្ឋ, គម្លាតនៃការបោះផ្សាយ, និងវិធីសាស្ត្របោះផ្សាយ ជាដើម ហើយត្រូវផ្សព្វផ្សាយផែនការនេះជាសាធារណៈនៅមុនឆ្នាំថវិកានីមួយៗ។ បន្ថែមលើនេះ, ប្រទេសមួយចំនួន ក៏បានរៀបចំ និងផ្សព្វផ្សាយផងដែរនូវសេចក្តីប្រកាសព័ត៌មានជាប្រចាំសប្តាហ៍, ប្រចាំខែ, ឬប្រចាំត្រីមាស ដើម្បីជូនដំណឹងដល់សាធារណជនអំពីទំហំបោះផ្សាយជាក់លាក់តាមឥណប្រតិទាន, អត្រាគូប៉ុង ព្រមទាំងកាលបរិច្ឆេទបោះផ្សាយនិងទូទាត់សាច់ប្រាក់។

– **ការកំណត់ច្រកបោះផ្សាយ**

ច្រកនៃការបោះផ្សាយមូលបត្ររដ្ឋ អាចត្រូវបានកំណត់ផ្សេងគ្នាអាស្រ័យទៅនឹងស្ថានភាព និងរចនាសម្ព័ន្ធទីផ្សារនៃប្រទេសនីមួយៗ។ ជាទូទៅ, មូលបត្ររដ្ឋត្រូវបានបោះផ្សាយលក់តាមរយៈធនាគារកណ្តាល ដោយហេតុថា ធនាគារកណ្តាលមានភារកិច្ចស្នូលក្នុងការជួយចាត់ចែងប្រតិបត្តិការហិរញ្ញវត្ថុជូនរដ្ឋាភិបាល, គ្រប់គ្រងប្រព័ន្ធទូទាត់ជាតិ ព្រមទាំងមានហេដ្ឋារចនាសម្ព័ន្ធសមស្របសម្រាប់ការទូទាត់មូលបត្ររដ្ឋ ប្រកបដោយទំនុកចិត្តខ្ពស់, ហានិភ័យទាប, និងថ្លៃប្រតិបត្តិការទាប។ ទន្ទឹមនេះ, ក៏មានប្រទេសមួយចំនួនតូចដែលប្រើប្រាស់ច្រកបោះផ្សាយផ្សេងពីធនាគារកណ្តាលដែរ ដូចជា តាមរយៈផ្សារមូលបត្រ, រតនាគារ ឬអង្គភាពគ្រប់គ្រងបំណុល។

– **ការកំណត់វិធីសាស្ត្របោះផ្សាយ**

តាមការអនុវត្តនៅបណ្តាប្រទេសនានា, មានវិធីសាស្ត្រចំនួន ៤ ដែលត្រូវបានប្រើប្រាស់សម្រាប់ការបោះផ្សាយលក់មូលបត្ររដ្ឋ គឺ៖ ការដេញថ្លៃ (Auction), ការធ្វើសហជីព (Syndication), ការលក់ជាលក្ខណៈឯកជន (Private Placement), និងការលក់ដោយកំណត់មុន (Tap Sales) ដូចមានរៀបរាប់លម្អិតខាងក្រោម៖

- **ការដេញថ្លៃ**
  - **និយមន័យ៖** ជាវិធីសាស្ត្របោះផ្សាយលក់មូលបត្ររដ្ឋ ដោយអនុញ្ញាតឱ្យវិនិយោគិនដាក់ស្នើទិញក្នុងបរិមាណ (Bidding Amount) និងអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន (Yield) ឬថ្លៃ (Price) ទៅតាមតម្រូវការ និងលទ្ធភាពជាក់ស្តែង។
  - **នីតិវិធី៖** ជាទូទៅ, មានទម្រង់ជាការដេញថ្លៃដោយប្រកួតប្រជែង (Competitive Bidding) ដោយការស្នើរបស់វិនិយោគិនទាំងអស់នឹងត្រូវតម្រៀបតាមលំដាប់ពីទាបទៅខ្ពស់ (ករណីដាក់ស្នើជាអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន) ឬពីខ្ពស់មកទាប (ករណីដាក់ស្នើជាថ្លៃ) ដើម្បីជាមូលដ្ឋានកំណត់អ្នកឈ្នះ។ បន្ថែមលើនេះ, នៅតាមបណ្តាប្រទេសមួយចំនួន ក៏បើកឱ្យមានផងដែរនូវការដេញថ្លៃដោយមិនប្រកួតប្រជែង (Non-Competitive Bidding) ក្នុងកម្រិតណាមួយនៃទំហំដេញថ្លៃប្រកួតប្រជែង ដោយតម្រូវឱ្យវិនិយោគិនដាក់ស្នើតែបរិមាណប៉ុណ្ណោះ។
  - **ការកំណត់តម្លៃមូលបត្រ**

    ការកំណត់តម្លៃមូលបត្រសម្រាប់ការដេញថ្លៃដោយប្រកួតប្រជែងមាន ៣ អភិក្រម ដូចខាងក្រោម៖
    - អភិក្រមពហុតម្លៃ (Multiple Price Auction)៖ តម្លៃមូលបត្ររដ្ឋនឹងត្រូវកំណត់ខុសៗគ្នាទៅតាមអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន ឬថ្លៃដែលអ្នកឈ្នះបានដាក់ស្នើ។
    - អភិក្រមតម្លៃតែមួយ (Single Price Auction)៖ តម្លៃមូលបត្ររដ្ឋនឹងត្រូវកំណត់ដូចគ្នាដោយយកអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិនខ្ពស់ជាងគេ ឬថ្លៃទាបជាងគេ ក្នុងចំណោមអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន ឬថ្លៃដែលអ្នកឈ្នះបានដាក់ស្នើ។

- អភិក្រមកូនកាត់ (Hybrid Price Auction)៖ ជាអភិក្រមបន្សំគ្នារវាងអភិក្រមពហុតម្លៃ និងអភិក្រមតម្លៃតែមួយ ដោយអ្នកបោះផ្សាយកំណត់នូវអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន ឬថ្លៃជាចន្លោះៗ (Range) ដើម្បីញែកអ្នកឈ្នះជាក្រុម ហើយតម្លៃមូលបត្ររដ្ឋតាមក្រុមនីមួយៗ ត្រូវកំណត់ដោយយក អត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិនខ្ពស់ជាងគេ ឬថ្លៃទាបជាងគេនៅក្នុងក្រុម។ ដូចនេះ, ក្រុមនីមួយៗ នឹងទទួលបានតម្លៃមូលបត្រខុសគ្នា ប៉ុន្តែ អ្នកឈ្នះក្នុងក្រុមនឹងទទួលបានតម្លៃមូលបត្រដូចគ្នា។

ដោយឡែក, ការកំណត់តម្លៃមូលបត្រសម្រាប់ការដេញថ្លៃដោយមិនប្រកួតប្រជែង ត្រូវអាស្រ័យទៅតាមអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន ឬថ្លៃ (ភាគច្រើន ជាតម្លៃមធ្យមទម្ងន់ "Weighted Average") ដែលឈ្នះនៅក្នុងការដេញថ្លៃប្រកួតប្រជែង។

- **ការអនុវត្ត៖** ការដេញថ្លៃជាវិធីសាស្ត្រដែលនិយមប្រើច្រើនជាងគេ ព្រោះមានតម្លាភាពខ្ពស់ និងជួយជំរុញដល់យន្តការទីផ្សារ ហើយការដេញថ្លៃត្រូវធ្វើឡើងជាទៀងទាត់ ស្របតាមផែនការបោះផ្សាយដើម្បីឱ្យវិនិយោគិនអាចត្រៀមលក្ខណៈក្នុងការចូលរួមដេញថ្លៃ។ ទន្ទឹមនេះ, ការកំណត់តម្លៃមូលបត្រតាមអភិក្រមពហុតម្លៃ ត្រូវបានប្រើប្រាស់ច្រើនជាងគេ ដោយសារអាចឆ្លុះបញ្ចាំងអំពីតម្លៃទីផ្សារពិតប្រាកដ និងជួយកាត់បន្ថយការបញ្ចុះថ្លៃមូលបត្រ។ ជាមួយគ្នានេះ, អភិក្រមតម្លៃតែមួយ ក៏ត្រូវបានប្រើប្រាស់ផងដែរ ព្រោះមានលក្ខណៈសាមញ្ញ អាចទាក់ទាញវិនិយោគិនច្រើនឱ្យចូលរួម និងដើម្បីបញ្ចៀស ឬកាត់បន្ថយនូវហេតុការណ៍អាក្រក់របស់អ្នកឈ្នះ (Winner's Curse) ដែលកើតចេញពីការប្រើប្រាស់អភិក្រមពហុតម្លៃ និងជួយបង្កើតតម្លៃយោងសម្រាប់ការបោះផ្សាយលក់មូលបត្ររដ្ឋប្រភេទថ្មី។ ដោយឡែក, អភិក្រមកូនកាត់ ត្រូវបានប្រើប្រាស់តិចតួចបំផុត ដោយសារមានភាពស្មុគស្មាញខ្លាំងក្នុងការអនុវត្ត។

- **ការធ្វើសហជីព (Syndication)**
  - **និយមន័យ៖** ជាវិធីសាស្ត្របោះផ្សាយលក់មូលបត្ររដ្ឋ ដោយមានស្ថាប័នមួយក្រុម ជាអ្នកជានាទិញ និងចាត់ចែងលក់មូលបត្ររដ្ឋបន្តទៅវិនិយោគិន ទាំងវិនិយោគិនស្ថាប័ន និងវិនិយោគិនបុគ្គលដែលមានទ្រព្យច្រើន (High-Net-Worth Investor)។
  - **នីតិវិធី៖** អង្គភាពបោះផ្សាយ ត្រូវកំណត់ស្ថាប័នមួយក្រុមដែលអាចមានសមាសភាពជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និង/ឬ ក្រុមហ៊ុនមូលបត្រ ដើម្បីបំពេញភារកិច្ចជាអ្នកជានាទិញ, អន្តរការី, អ្នកធ្វើទីផ្សារ និងជាអ្នកផ្តល់យោបល់លើការកំណត់ថ្លៃនិងបែងចែកលក់មូលបត្ររដ្ឋ។ ទន្ទឹមនេះ, អង្គភាពបោះផ្សាយត្រូវចាត់ឱ្យមានជាប្រធានក្រុម (Lead Manager) ឬសហប្រធានក្រុម (Joint Lead Manager) ដែលភាគច្រើនជាគ្រឹះស្ថានធនាគារ ដើម្បីស្វែងរកវិនិយោគិនមកទិញមូលបត្ររដ្ឋ និងរាយការណ៍អំពីតម្រូវការទីផ្សារជាក់ស្តែង។
  - **ការកំណត់តម្លៃមូលបត្រ៖** អង្គភាពបោះផ្សាយកំណត់តម្លៃមូលបត្ររដ្ឋក្នុងកម្រិតណាមួយ បន្ទាប់ពីបានពិនិត្យ និងពិភាក្សាជាមួយក្រុមស្ថាប័ន។
  - **ការអនុវត្ត៖** ជាទូទៅ, វិធីសាស្ត្រនេះ ត្រូវបានអនុវត្តចំពោះការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងទំហំធំ ឬមូលបត្ររដ្ឋប្រភេទថ្មីណាមួយ ដែលពុំទាន់មានមូលដ្ឋានវិនិយោគិនប្រាកដប្រជានៅក្នុងទីផ្សារ។

ទន្ទឹមនេះ, ការធ្វើសហជីព អាចត្រូវធ្វើឡើងអាស្រ័យតាមតម្រូវការរបស់អង្គភាពបោះផ្សាយ និងស្ថានភាពទីផ្សារជាក់ស្ដែង។

- **ការលក់ជាលក្ខណៈឯកជន** (Private Placement)
  - **និយមន័យ៖** ជាវិធីសាស្ត្របោះផ្សាយលក់មូលបត្ររដ្ឋ ដោយផ្ទាល់ទៅឱ្យវិនិយោគិនគោលដៅតាមរយៈការចរចា។
  - **នីតិវិធី៖** វិនិយោគិនដាក់លិខិតស្នើសុំទិញមកអង្គភាពបោះផ្សាយដោយផ្ទាល់ ឬតាមរយៈអន្តរការីដោយបញ្ជាក់អំពីលក្ខខណ្ឌស្នើទិញជាក់លាក់ ដូចជា៖ ទំហំ, ឥណប្រតិទាន, អត្រាគូប៉ុង ជាដើម។ ក្នុងករណីឯកភាពលើលក្ខខណ្ឌស្នើទិញ, អង្គភាពបោះផ្សាយត្រូវជូនដំណឹងទៅវិនិយោគិន ហើយបន្តនីតិវិធីចុះកិច្ចព្រមព្រៀងទិញ-លក់មូលបត្ររដ្ឋ និងចេញវិញ្ញាបនបត្របញ្ជាក់។ ក្នុងករណីពុំឯកភាពលើលក្ខខណ្ឌស្នើទិញ, អង្គភាពបោះផ្សាយ ត្រូវជូនដំណឹងទៅវិនិយោគិនអំពីការច្រានចោល ឬស្នើចរចាបន្ថែមជាមួយវិនិយោគិន។
  - **ការកំណត់តម្លៃមូលបត្រ៖** តម្លៃមូលបត្ររដ្ឋ ត្រូវកំណត់ដោយការព្រមព្រៀងគ្នារវាងអង្គភាពបោះផ្សាយ និងវិនិយោគិន។
  - **ការអនុវត្ត៖** វិធីសាស្ត្រនេះ ត្រូវបានអនុវត្តសម្រាប់តែប្រភេទមូលបត្រ និងក្រុមវិនិយោគិនគោលដៅជាក់លាក់ប៉ុណ្ណោះ។

- **ការលក់ដោយកំណត់មុន** (Tap Sale)
  - **និយមន័យ៖** ជាវិធីសាស្ត្របោះផ្សាយលក់មូលបត្ររដ្ឋ ដោយបើកលក់ឡើងវិញនូវប្រភេទមូលបត្ររដ្ឋ ដែលធ្លាប់បានដាក់ឱ្យដេញថ្លៃកន្លងមកតែមិនទាន់ដល់កាលបរិច្ឆេទសង (ប្រភេទមូលបត្រដដែល ទាំងកាលបរិច្ឆេទសង, តម្លៃចារឹក, អត្រាគូប៉ុង, និងលេខកូដស្តង់ដា) តាមរយៈការអនុញ្ញាតឱ្យវិនិយោគិនដាក់ពាក្យស្នើសុំទិញ ក្នុងរយៈពេលកំណត់។ ជាទូទៅ, មូលបត្ររដ្ឋដែលបើកលក់ឡើងវិញ នឹងមានរយៈពេលសងដើមជាក់ស្ដែង ខ្លីជាងឥណប្រតិទាន។
  - **នីតិវិធី៖** នៅពេលដេញថ្លៃលក់មូលបត្ររដ្ឋ, ស្ថាប័នបោះផ្សាយត្រូវបញ្ជាក់ឱ្យហើយថា មូលបត្ររដ្ឋប្រភេទណា ដែលនឹងត្រូវបើកលក់ឡើងវិញនាពេលខាងមុខ។ ពេលមានតម្រូវការបើកលក់ជាក់ស្ដែង, ស្ថាប័នបោះផ្សាយត្រូវជូនដំណឹងជាសាធារណៈ ដោយបញ្ជាក់អំពីទំហំបោះផ្សាយ, លក្ខខណ្ឌចូលរួម, និងរយៈពេលទទួលការស្នើទិញដែលជាទូទៅមានរយៈពេលបីថ្ងៃ ឬមួយសប្តាហ៍។ បន្ទាប់ពីទទួលបានការស្នើទិញ, ស្ថាប័នបោះផ្សាយនឹងពិនិត្យសម្រេចលើ៖ តម្លៃលក់ជារួម, ទំហំដែលត្រូវលក់ទៅវិនិយោគិននីមួយៗ, និងកាលបរិច្ឆេទបោះផ្សាយ។
  - **ការកំណត់តម្លៃមូលបត្រ៖** ស្ថាប័នបោះផ្សាយកំណត់តម្លៃមូលបត្ររដ្ឋ ដោយផ្អែកលើស្ថានភាព និងតម្រូវការទីផ្សារជាក់ស្ដែង។
  - **ការអនុវត្ត៖** ជាទូទៅ, វិធីសាស្ត្រនេះ ត្រូវបានយកមកអនុវត្តចំពោះប្រភេទមូលបត្ររដ្ឋដែលមានឥណប្រតិទានខ្លី (ត្រឹម ៣ឆ្នាំ) ដើម្បីកៀរគរទុនបានឆាប់រហ័ស នៅពេលមានតម្រូវការប្រើប្រាស់។

ជាការអនុវត្តជាក់ស្ដែង, វិធីសាស្ត្របោះផ្សាយលក់មូលបត្ររដ្ឋ អាចត្រូវបានយកមកប្រើលើសពីមួយ ហើយមានលក្ខណៈពិសេស និងភាពបត់បែនផ្សេងៗគ្នា ទៅតាមបរិការណ៍ជាក់ស្ដែងរបស់ប្រទេសនីមួយៗ ក្នុងនោះ

វិធីសាស្ត្រដែលមានប្រជាប្រិយជាងគេ គឺការដេញថ្លៃ។ យ៉ាងណាមិញ, គុណសម្បត្តិ និងគុណវិបត្តិនៃវិធីសាស្ត្រនីមួយៗ មានដូចក្នុងតារាងទី១ ខាងក្រោម៖

**តារាងទី១៖ គុណសម្បត្តិ និងគុណវិបត្តិនៃវិធីសាស្ត្របោះផ្សាយ**

| វិធីសាស្ត្រ | គុណសម្បត្តិ | គុណវិបត្តិ |
|---|---|---|
| **ការដេញថ្លៃ** | - មានភាពប្រកួតប្រជែង និងតម្លាភាពខ្ពស់<br>- អនុញ្ញាតឱ្យវិនិយោគិនចូលរួមបានទូលំទូលាយ<br>- ធ្វើឱ្យយន្តការទីផ្សារមានដំណើរការល្អ។ | - ពុំសូវមានភាពបត់បែន ដោយត្រូវអនុវត្តតាមផែនការ ទាំងកាលវិភាគ និងទំហំបោះផ្សាយដែលបានកំណត់<br>- ពុំមានលទ្ធភាពគ្រប់គ្រងតម្លៃលក់មូលបត្រ និងជ្រើសរើសវិនិយោគិន។ |
| **ការធ្វើសហជីព** | - មានភាពបត់បែន ព្រោះមិនត្រូវអនុវត្តតាមផែនការបោះផ្សាយ<br>- អាចមានលទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងតម្លៃលក់មូលបត្រ និងពង្រីកមូលដ្ឋានវិនិយោគិន<br>- បង្កើនប្រសិទ្ធភាពនៃការបោះផ្សាយលក់ឧបករណ៍ថ្មីក្នុងទីផ្សារ ពិសេសឧបករណ៍ដែលមិនទាន់មានសកម្មភាពជួញដូរ<br>- អាចជំរុញឱ្យការបោះផ្សាយលក់មូលបត្ររដ្ឋបានគ្រប់តាមតម្រូវការ។ | - ចំណាយពេលវេលាច្រើនក្នុងការរៀបចំ<br>- ត្រូវចំណាយលើកម្រៃសេវាផ្សេងៗ<br>- ទាមទារឱ្យមានសមត្ថភាពបច្ចេកទេស និងជំនាញខ្ពស់ ជាពិសេស លើការវិភាគព័ត៌មានទីផ្សារ<br>- អាចប៉ះពាល់ដល់កិច្ចដំណើរការ និងយន្តការទីផ្សារ ក្នុងករណីអនុវត្តវិធីសាស្ត្រនេះញឹកញាប់<br>- មិនសូវមានតម្លាភាព។ |
| **ការលក់ជាលក្ខណៈឯកជន** | - មានភាពបត់បែនទាំងការជ្រើសរើសវិនិយោគិន ទាំងពេលវេលា និងលក្ខខណ្ឌបោះផ្សាយ<br>- អាចបោះផ្សាយលក់មូលបត្ររដ្ឋ ក្នុងអត្រាគូប៉ុងទាបជាងទីផ្សារ។ | - អាចប៉ះពាល់ដល់យន្តការទីផ្សារ<br>- ពុំជំរុញឱ្យមានការជួញដូរក្នុងទីផ្សារបន្ទាប់ ដោយសារភាគច្រើនជាការទិញ ហើយរក្សាទុករហូតដល់ ថ្ងៃឥណប្រតិទាន។ |
| **ការលក់ដោយកំណត់មុន** | - មានភាពបត់បែនទាំងការជ្រើសរើសវិនិយោគិន ទាំងពេលវេលា និងលក្ខខណ្ឌបោះផ្សាយ<br>- អាចកៀរគរទុនបានឆាប់រហ័ស តាមតម្រូវការ។ | - អាចប៉ះពាល់ដល់យន្តការទីផ្សារ ជាពិសេស ដល់ការដេញថ្លៃមូលបត្រដើម ព្រោះវិនិយោគិនមានទំនោរដាក់ស្នើតម្លៃទាប ឬមិនចូលរួមដេញថ្លៃ ដោយរំពឹងថាមូលបត្រនោះ នឹងដាក់លក់នៅពេលក្រោយទៀត<br>- វិនិយោគិនពិបាកត្រៀមលក្ខណៈក្នុងការចូលរួម។ |

– **ការជ្រើសរើសឧបករណ៍មូលបត្ររដ្ឋ**

ការជ្រើសរើសឧបករណ៍មូលបត្ររដ្ឋសម្រាប់ការបោះផ្សាយ ត្រូវផ្អែកលើកកត្តាចម្បងៗមួយចំនួនដូចជា៖ តម្រូវការហិរញ្ញប្បទាន, ចីរភាពបំណុលសាធារណៈ, ស្ថានភាពទីផ្សារ, និងដំណាក់កាលនៃការអភិវឌ្ឍមូលបត្ររដ្ឋ ជាដើម។

ជាបទពិសោធន៍, ប្រទេសដែលបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូង ឬប្រទេសដែលមានទីផ្សារកំពុងអភិវឌ្ឍ ភាគច្រើនបោះផ្សាយលក់មូលបត្ររដ្ឋដែលមានលក្ខណៈសាមញ្ញ (ដូចជា៖ បណ្ណរតនាគារដែលមានឥណប្រតិទានតិចជាង ១ឆ្នាំ ឬសញ្ញាបណ្ណដែលមានអត្រាគូប៉ុងថេរ) ហើយនៅពេលដែលទីផ្សារមានការអភិវឌ្ឍទើបមានការបោះផ្សាយលក់មូលបត្ររដ្ឋដែលមានលក្ខណៈស្មុគស្មាញ (ដូចជា៖ សញ្ញាបណ្ណមានអត្រាគូប៉ុងប្រែប្រួល, ឬសញ្ញាបណ្ណផ្សារភ្ជាប់នឹងអតិផរណា, សញ្ញាបណ្ណរាយ ជាដើម)។ ទន្ទឹមនេះ, ប្រទេសមួយចំនួនបង្កើតឱ្យមានជាសញ្ញាបណ្ណគោល (Benchmark Bonds) ដោយបោះផ្សាយលក់ប្រភេទមូលបត្ររដ្ឋ ដែលមានសកម្មភាពជួញដូរច្រើន និងទំហំធំនៅក្នុងទីផ្សារ ដើម្បីកាត់បន្ថយភាពបែកខ្ញែកនៃសន្និធិមូលបត្ររដ្ឋ និងជំរុញការកសាងខ្សែកោងអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន (Yield Curve)។

បន្ថែមលើនេះ, ក៏មានការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ (Thematic Bonds) ផងដែរ ដើម្បីកៀរគរទុនសម្រាប់អនុវត្តគម្រោងអភិវឌ្ឍដែលមានគោលដៅជាក់លាក់ ជាពិសេស ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព(Sustainable Development Goals - SDGs) ដូចមានលម្អិតក្នុងចំណុច ៣.១.៤. ខាងក្រោម។

– **ការចុះបញ្ជី**

ការចុះបញ្ជីមាន ២ ទម្រង់ គឺ៖ ការចុះបញ្ជីជួញដូរ (Normal Listing) និងការចុះបញ្ជីព័ត៌មាន (Profile Listing) ដែលការចុះបញ្ជីទាំងនេះ ត្រូវធ្វើនៅផ្សារមូលបត្រ។ គោលបំណងនៃការចុះបញ្ជីជួញដូរ គឺដើម្បីអនុញ្ញាតឱ្យមូលបត្ររដ្ឋដែលបានបោះផ្សាយ អាចជួញដូរបាននៅលើផ្សារមូលបត្រ។ ដោយឡែក, ការចុះបញ្ជីព័ត៌មាន គឺដើម្បីបង្ហាញព័ត៌មានទូទៅជូនដល់សាធារណជន អំពីមូលបត្ររដ្ឋដែលបានបោះផ្សាយ។ ជាការអនុវត្តនៅតាមបណ្ដាប្រទេសនានា, ការចុះបញ្ជីពុំមែនជាលក្ខខណ្ឌតម្រូវចាំបាច់ទេ ដោយសារមូលបត្ររដ្ឋ ជាឧបករណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ហើយភាគច្រើន ត្រូវបានជួញដូរតាមរំលងបញ្ជរ (Over-the-Counter - OTC)។

– **ការទូទាត់សាច់ប្រាក់ និងរក្សាទុកមូលបត្ររដ្ឋ**

ជាឧត្តមានុវត្តន៍, ការទូទាត់សាច់ប្រាក់ និងរក្សាទុកមូលបត្ររដ្ឋ ត្រូវអនុវត្តតាមគោលការណ៍ប្រគល់-ទទួល និងទូទាត់ក្នុងពេលតែមួយ (Delivery Versus Payment - DVP)។ ជាទូទៅ, ការទូទាត់សាច់ប្រាក់ ត្រូវធ្វើឡើងដោយធនាគារកណ្ដាល ដែលជាស្ថាប័នគ្រប់គ្រងប្រព័ន្ធទូទាត់ជាតិ និងចាត់ចែងកិច្ចការទូទាត់ជូនរដ្ឋាភិបាល។ ទន្ទឹមនេះ, ដោយសារធនាគារកណ្ដាលមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ បណ្ដាប្រទេសភាគច្រើន ក៏ចាត់ធនាគារកណ្ដាលជាប្រតិបត្តិកររក្សាទុកមូលបត្ររដ្ឋដែរ ដើម្បីធានាថា ប្រតិបត្តិការទូទាត់សាច់ប្រាក់ និងរក្សាទុកមូលបត្ររដ្ឋអាចអនុវត្តបានប្រកបដោយទំនុកចិត្ត, ភាពងាយស្រួល ព្រមទាំងមានថ្លៃប្រតិបត្តិការនិងហានិភ័យទាប។ ដោយឡែក, ប្រទេសមួយចំនួន បង្កើតជាស្ថាប័នដោយឡែកតែម្ដង ដើម្បីទទួលបន្ទុកជាប្រតិបត្តិកររក្សាទុកមូលបត្ររួម (Central Securities Depository) ដោយរក្សាទុកទាំងមូលបត្ររដ្ឋ និងមូលបត្រសាជីវកម្ម។

– **ការរៀបចំឱ្យមានពាណិជ្ជករដំបូង**

ការរៀបចំឱ្យមានពាណិជ្ជករដំបូង ផ្ដល់នូវផលប្រយោជន៍ចម្បងៗ ដូចជា៖ i) ជួយកំណត់ឱ្យបានច្បាស់លាស់អំពីតម្រូវការទិញមូលបត្ររដ្ឋ, ii) អាចកៀរគរទុនបានតាមផែនការ, iii) ជំរុញការដឹងថ្លៃ (Price Discovery), និង iv) ជំរុញការជួញដូរមូលបត្ររដ្ឋនៅក្នុងទីផ្សារបន្ទាប់។

ជាការអនុវត្ត, ប្រទេសមួយចំនួនបានជ្រើសរើសវិនិយោគិនស្ថាប័នដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាពាណិជ្ជករដំបូង ដើម្បីបំពេញកាតព្វកិច្ចសំខាន់ៗ ដូចជា៖ i) ចូលរួមដេញថ្លៃ និងជានាទិញមូលបត្ររដ្ឋក្នុងទីផ្សារដំបូង, ii) លក់មូលបត្ររដ្ឋបន្តក្នុងទីផ្សារបន្ទាប់, iii) ជួយជំរុញសន្ទនីយភាពនៃមូលបត្ររដ្ឋនៅក្នុងទីផ្សារ, iv)

ចូលរួមផ្តល់យោបល់ពាក់ព័ន្ធនឹងដំណើរការបោះផ្សាយលក់មូលបត្ររដ្ឋ និងការរៀបចំយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងៗ, និង v) ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងលទ្ធផលនៃការជួញដូរនៅក្នុងទីផ្សារបន្ទាប់។ ទន្ទឹមនេះ, ស្ថាប័នបោះផ្សាយ ត្រូវផ្តល់បុព្វសិទ្ធិមួយចំនួនដល់ពាណិជ្ជករដំបូង ដូចជា៖ i) លទ្ធភាពចូលរួមដេញថ្លៃផ្តាច់មុខ, ii) សិទ្ធិក្នុងការស្នើទិញមូលបត្រក្រោយការបោះផ្សាយ ឬស្នើសុំទិញបន្ថែមនូវមូលបត្ររដ្ឋជាក់លាក់ណាមួយ, iii) ក្លាយជាដៃគូសន្ទនាគោលនយោបាយជាមួយស្ថាប័នបោះផ្សាយ, iv) សិទ្ធិទទួលបានទុនបង្វិលរយៈពេលខ្លីពីរដ្ឋាភិបាល ជាដើម។

ជារួម, ការរៀបចំឱ្យមានពាណិជ្ជករដំបូងជួយជំរុញប្រសិទ្ធភាពនៃការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ ប៉ុន្តែ ក៏អាចប៉ះពាល់ដល់ការប្រកួតប្រជែង ដូចជា យន្តការទីផ្សារផងដែរ ដែលទាមទារឱ្យស្ថាប័នបោះផ្សាយ ត្រូវមានការប្រយ័ត្នប្រយែង ដោយថ្លឹងថ្លែងរវាងការផ្តល់បុព្វសិទ្ធិនិងការកំណត់កាតព្វកិច្ច ព្រមទាំងត្រូវមាននីតិវិធីច្បាស់លាស់ក្នុងការជ្រើសរើស, វាយតម្លៃ, និងគ្រប់គ្រងពាណិជ្ជករដំបូង។

– **ទំនាក់ទំនងជាមួយធនាគារកណ្តាល**

មូលបត្ររដ្ឋ មិនត្រឹមតែជាឧបករណ៍សម្រាប់ការកៀរគរទុនមកបំពេញតម្រូវការហិរញ្ញប្បទានរបស់រដ្ឋាភិ-បាលប៉ុណ្ណោះទេ ប៉ុន្តែ ក៏ជាឧបករណ៍ចម្បងសម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារកណ្តាលផងដែរ ដូចនេះ អន្តរសកម្មរវាងស្ថាប័នទាំងពីរ គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍមូលបត្ររដ្ឋ។ ផ្អែកតាមឧត្តមានុវត្តន៍ជាអន្តរជាតិ, ធនាគារកណ្តាលភាគច្រើន ពុំផ្តល់ហិរញ្ញប្បទានផ្ទាល់ក្នុងរយៈពេលវែងដល់រដ្ឋាភិបាល ឬចូលរួមទិញមូលបត្ររដ្ឋក្នុងទីផ្សារដំបូងទេ ដោយការណ៍នេះអាចបង្កជាបច្ច័យអវិជ្ជមាន ដូចជា៖ i) ការចុះខ្សោយនៃស្វយ័តភាពរបស់ធនាគារកណ្តាល, ii) ការធ្លាក់ចុះប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ និង iii) ការចុះខ្សោយនៃការគោរពវិន័យថវិកា។ ទោះជាយ៉ាងនេះក្តី, ធនាគារកណ្តាលអាចទិញមូលបត្ររដ្ឋនៅក្នុងទីផ្សារបន្ទាប់ដើម្បីអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ខ្លួន។

ដោយឡែក, នៅប្រទេសខ្លះ ធនាគារកណ្តាលក៏ត្រូវបានអនុញ្ញាតឱ្យទិញមូលបត្ររដ្ឋនៅក្នុងទីផ្សារដំបូងផងដែរ ប៉ុន្តែ ក្នុងទំហំតិចតួចបំផុត ហើយភាគច្រើនទិញតាមរយៈការដេញថ្លៃមិនប្រកួតប្រជែង ដើម្បីធានាថាធនាគារកណ្តាលមានមូលបត្ររដ្ឋនៅក្នុងដៃ សម្រាប់ការអនុវត្តគោលនយោបាយរូបិយវត្ថុ។ ទន្ទឹមនេះ, ក្នុងបរិការណ៍នៃវិបត្តិកូវីដ-១៩ ប្រទេសមួយចំនួនបានកែសម្រួលក្របខ័ណ្ឌគតិយុត្ត និងគោលនយោបាយរបស់ខ្លួន ដើម្បីបើកផ្លូវឱ្យធនាគារកណ្តាលជួយអន្តរាគមន៍ដល់រដ្ឋាភិបាល តាមរយៈការទិញមូលបត្ររដ្ឋក្នុងទីផ្សារដំបូង ឬផ្តល់ឥណទានផ្ទាល់ដល់រដ្ឋាភិបាលតែម្តង។

### ខ. ទីផ្សារបន្ទាប់

ការជួញដូរមូលបត្ររដ្ឋនៅក្នុងទីផ្សារបន្ទាប់ អាចធ្វើឡើងនៅលើផ្សារមូលបត្រ ឬតាមរំលងបញ្ជរ (Over-the-Counter – OTC)។ ជាការអនុវត្តនៅតាមបណ្តាប្រទេសភាគច្រើន, មូលបត្ររដ្ឋ ត្រូវបានជួញដូរតាមរំលងបញ្ជរដែលអាចជាការចរចាគ្នាដោយផ្ទាល់រវាងអ្នកលក់ និងអ្នកទិញ ឬ តាមរយៈឈ្មួញកណ្តាល។ ទន្ទឹមនេះ, ដើម្បីជំរុញឱ្យទីផ្សារបន្ទាប់មានដំណើរការល្អ, ប្រទេសមួយចំនួនបានរៀបចំឱ្យមានពាណិជ្ជករដំបូង, បង្កើតសញ្ញាបណ្ណគោល, ពង្រីកទំហំនៃការបោះផ្សាយ, បង្កើនកិច្ចសន្ទនាជាមួយអ្នកពាក់ព័ន្ធក្នុងទីផ្សារ ជាដើម។

### គ. ទីផ្សាររូបិយវត្ថុ

ទីផ្សាររូបិយវត្ថុ គឺជាទីផ្សារសម្រាប់ការជួញដូរឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី ដែលមានសន្ទនីយភាពខ្ពស់ មានដូចជា៖ វិញ្ញាបនបត្រសន្សំ, កម្ចីអន្តរធនាគារ, បណ្ណរតនាគារដែលមានឥណប្រតិទានតិចជាង ១ឆ្នាំ, ការឱ្យខ្ចីមូលបត្រ, កិច្ចព្រមព្រៀងទទួលទិញវិញ ជាដើម។ វត្តមាននៃទីផ្សាររូបិយវត្ថុដែលមានសន្ទនីយភាពខ្ពស់ ជា

មូលដ្ឋានយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ ក៏ដូចជា ទីផ្សារហិរញ្ញវត្ថុឱ្យកាន់តែស៊ីជម្រៅ, រឹងមាំ, និងស្ថិរភាពខ្ពស់។ ទន្ទឹមនេះ, រដ្ឋាភិបាលអាចធ្វើការកៀរគរទុនរយៈពេលខ្លីកាន់តែមានប្រសិទ្ធភាព ដើម្បីគ្រប់គ្រងសាច់ប្រាក់, ពង្រីកប្រភេទមូលបត្ររដ្ឋ, បង្កើនប្រសិទ្ធភាពនៃព័ត៌មានទីផ្សារ ព្រមទាំងជំរុញការធ្វើឱ្យប្រសើរឡើងនូវសុក្រឹតភាពនៃការកំណត់តម្លៃឧបករណ៍ក្នុងទីផ្សារ និងកិច្ចដំណើរការនៃទីផ្សារបន្ទាប់ ជាដើម។

ដើម្បីកសាងទីផ្សាររូបិយវត្ថុប្រកបដោយជោគជ័យ ចាំបាច់ត្រូវបំពេញលក្ខខណ្ឌមូលដ្ឋានមួយចំនួន មានជាអាទិ៍៖ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, គោលនយោបាយរូបិយវត្ថុ និងក្របខ័ណ្ឌគតិយុត្តគ្រប់ជ្រុងជ្រោយ, តម្លាភាព និងទំនុកចិត្តក្នុងទីផ្សារ, ពិពិធភាពនៃឧបករណ៍ហិរញ្ញវត្ថុ, សន្ទនីយភាពទីផ្សារ, និងប្រព័ន្ធគាំទ្រទីផ្សារពេញលេញ។ ជាទូទៅ, ធនាគារកណ្តាល ជាស្ថាប័នមានតួនាទីស្នូលនៅក្នុងការជំរុញកិច្ចដំណើរការនៃទីផ្សាររូបិយវត្ថុ តាមរយៈការបោះផ្សាយលក់មូលបត្ររយៈពេលខ្លី និង/ឬការធ្វើប្រតិបត្តិការទីផ្សារចំហ ដើម្បីគ្រប់គ្រងសន្ទនីយភាពក្នុងទីផ្សារ និងគាំទ្រការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ខ្លួន។ ទន្ទឹមនេះ, រដ្ឋាភិបាលក៏ដើរតួយ៉ាងសំខាន់ក្នុងការចូលរួមចំណែកគាំទ្រដល់ការអភិវឌ្ឍទីផ្សាររូបិយវត្ថុផងដែរ តាមរយៈការបោះផ្សាយជាទៀងទាត់នូវបណ្ណរតនាគារដែលមានឥណប្រតិទានតិចជាង ១ឆ្នាំ ឬមូលបត្ររដ្ឋប្រភេទផ្សេងទៀត តាមតម្រូវការទីផ្សារជាក់ស្តែង។

### ឃ. មូលដ្ឋានវិនិយោគិន

មូលដ្ឋានវិនិយោគិនប្រកបដោយពិពិធភាព គឺជាកត្តាចម្បងមួយ ដើម្បីធានាបាននូវតម្រូវការមូលបត្ររដ្ឋ និងភាពធន់នៃទីផ្សារ។ ជាទូទៅ, វិនិយោគិនមូលបត្ររដ្ឋភាគច្រើន គឺជាវិនិយោគិនស្ថាប័ន ដូចជា៖ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, ក្រុមហ៊ុនធានារ៉ាប់រង, ក្រុមហ៊ុនមូលបត្រ, មូលនិធិសង្គហមិត្ត, មូលនិធិសោធន, មូលនិធិសន្សំ (Provident Funds) ជាដើម។ បន្ថែមលើនេះ, បណ្តាប្រទេសមួយចំនួន ក៏បានពង្រីកមូលដ្ឋានវិនិយោគិនដោយទាក់ទាញឱ្យមានការចូលរួមបន្ថែមពីវិនិយោគិនបុគ្គល (Retail Investor), វិនិយោគិនបរទេស, ឬវិនិយោគិនជំនាញ (Professional Investor) ផងដែរ។

ក្នុងគោលបំណងរក្សា និងពង្រីកមូលដ្ឋានវិនិយោគិនឱ្យបានទូលំទូលាយ, ស្ថាប័នបោះផ្សាយ ចាំបាច់ត្រូវមានមុខងារទំនាក់ទំនងវិនិយោគិន ដើម្បីផ្សព្វផ្សាយព័ត៌មានសំខាន់ៗជូនដល់វិនិយោគិន និងអ្នកចូលរួមទីផ្សារ, និងស្វែងយល់អំពីតម្រូវការជាក់ស្តែងក្នុងទីផ្សារ ព្រមទាំងឆ្លើយតបបានយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការរបស់វិនិយោគិន ក៏ដូចជា ស្ថានភាពប្រែប្រួលនៃទីផ្សារ។

### ង. ប្រព័ន្ធគាំទ្រទីផ្សារ

ការរៀបចំឱ្យមានប្រព័ន្ធគាំទ្រទីផ្សាររឹងមាំ និងគ្រប់ជ្រុងជ្រោយ គឺជាកត្តាមូលដ្ឋានដ៏សំខាន់មួយក្នុងការរួមចំណែកពង្រឹងប្រសិទ្ធភាពនៃកិច្ចដំណើរការក្នុងទីផ្សារ ក៏ដូចជា ជំរុញការអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ និងទីផ្សារហិរញ្ញវត្ថុផងដែរ។ ស្របតាមការវិវឌ្ឍជឿនលឿននៃបច្ចេកវិទ្យាបច្ចុប្បន្ន, មូលបត្ររដ្ឋស្ទើរតែទាំងស្រុង ត្រូវបានបោះផ្សាយក្នុងទម្រង់អេឡិចត្រូនិច ដែលតាមរយៈនេះ បណ្តាប្រទេសនានា បានប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាទំនើប ដើម្បីសម្រួលដល់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ ព្រមទាំងកាត់បន្ថយហានិភ័យពាក់ព័ន្ធ។

ប្រព័ន្ធគាំទ្រទីផ្សារដែលមានប្រសិទ្ធភាពខ្ពស់ ត្រូវតែមានការតភ្ជាប់គ្នា ដែលអនុញ្ញាតឱ្យប្រតិបត្តិការគាំទ្រនានាប្រព្រឹត្តទៅបានដោយស្វ័យប្រវត្តិ និងភ្លាមៗ ព្រមទាំងធានាបាននូវសុវត្ថិភាព, តម្លាភាព, និងទំនុកចិត្ត។ ប្រព័ន្ធគាំទ្រទីផ្សារសំខាន់ៗសម្រាប់ការបោះផ្សាយលក់មូលបត្ររដ្ឋ មានដូចខាងក្រោម៖

- **ប្រព័ន្ធគាំទ្រការបោះផ្សាយ**

ការបោះផ្សាយលក់មូលបត្ររដ្ឋនាពេលបច្ចុប្បន្ន ភាគច្រើន ធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិក ទាំងការ

ដេញថ្លៃ, ការបែងចែកលក់, ការចុះបញ្ជីមូលបត្ររដ្ឋ (Registration), និងការចុះបញ្ជី (Listing)។ ទន្ទឹមនេះ, ស្ថាប័នបោះផ្សាយ ត្រូវមានប្រព័ន្ធគាំទ្រសំខាន់ៗមួយចំនួន ដើម្បីពិនិត្យសម្រេចលើលទ្ធផលនៃការដេញថ្លៃ, តាមដានប្រតិបត្តិការទូទាត់សាច់ប្រាក់, គ្រប់គ្រងនិងរក្សាទុកទិន្នន័យ ជាដើម សំដៅធានាបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងការបោះផ្សាយលក់មូលបត្ររដ្ឋ។

– **ប្រព័ន្ធទូទាត់សាច់ប្រាក់ និងរក្សាទុកមូលបត្រ**

ជាការអនុវត្តនៅតាមបណ្តាប្រទេសនានា, ការទូទាត់សាច់ប្រាក់ ត្រូវបានធ្វើឡើងនៅលើប្រព័ន្ធទូទាត់ដុលភ្លាមៗ (Real-Time Gross Settlement System) ហើយប្រព័ន្ធនេះ ត្រូវមានការតភ្ជាប់គ្នា (Interconnected) ជាមួយប្រព័ន្ធរក្សាទុកមូលបត្ររដ្ឋ ដើម្បីអនុញ្ញាតឱ្យប្រតិបត្តិការទូទាត់សាច់ប្រាក់ និងរក្សាទុកមូលបត្ររដ្ឋ អាចអនុវត្តបានតាមគោលការណ៍ប្រគល់-ទទួល និងទូទាត់ក្នុងពេលតែមួយ ប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់។

– **ប្រព័ន្ធជួញដូរ**

ជាទូទៅ, បណ្តាប្រទេសភាគច្រើន បានរៀបចំឱ្យមានប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គាំទ្រការជួញដូរមូលបត្ររដ្ឋ ដែលប្រព័ន្ធនេះមានមុខងារផ្គូផ្គងការដាក់បញ្ជាទិញ/លក់ របស់អ្នកមានបំណងទិញ និងលក់។ នៅប្រទេសមួយចំនួន ប្រព័ន្ធនេះក៏មានមុខងារអនុញ្ញាតឱ្យអ្នកមានបំណងទិញ និងលក់មូលបត្រ ធ្វើការចរចាលើលក្ខខណ្ឌនៃការជួញដូរផងដែរ មុននឹងដាក់បញ្ជាទិញ/លក់។

– **ប្រព័ន្ធរបាយការណ៍ក្រោយជួញដូរ**

ក្នុងគោលបំណងធានាបាននូវតម្លាភាពនៃការជួញដូរ និងប្រសិទ្ធភាពនៃការកំណត់ថ្លៃមូលបត្ររដ្ឋនៅក្នុងទីផ្សារ, ប្រទេសភាគច្រើនបានរៀបចំឱ្យមាននូវប្រព័ន្ធរបាយការណ៍ក្រោយជួញដូរ (Post-Trade Reporting) ដែលរួមមានព័ត៌មានអំពីថ្លៃ និងទំហំនៃការជួញដូរ ដើម្បីអនុញ្ញាតឱ្យអ្នកពាក់ព័ន្ធក្នុងទីផ្សារ អាចពិនិត្យ និងតាមដានស្ថានភាពទីផ្សារបានទាន់ពេលវេលា។

### ៣.១.៤. ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ

#### ក. ទិដ្ឋភាពទូទៅ

សញ្ញាបណ្ណរដ្ឋតាមវិស័យ (Thematic Bonds) សំដៅដល់សញ្ញាបណ្ណរដ្ឋ ដែលត្រូវបានបោះផ្សាយ ដើម្បីកៀរគរទុនសម្រាប់អនុវត្តគម្រោងអភិវឌ្ឍដែលមានគោលដៅជាក់លាក់ ជាពិសេស ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព(Sustainable Development Goals - SDGs)។ ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ បានក្លាយជាប្រធានបទមួយដ៏ពេញនិយម ដែលប្រទេសជាច្រើនលើសកលលោក បានលើកយកមកពិភាក្សា ក្នុងបរិបទនៃការស្វែងរកទុនបន្ថែមទាំងពីទីផ្សារនៅក្នុងប្រទេស និងពីទីផ្សារអន្តរជាតិ។ ទំហំនៃការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ មានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងរយៈពេលមួយទសវត្សចុងក្រោយនេះ ដោយសារកត្តាមួយចំនួន ដូចជា៖ បម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់នៃបរិស្ថាន, ការកើនឡើងនូវសន្ទុះគាំទ្រពីវិនិយោគិន, និងការប្តេជ្ញាដើម្បីសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ តម្រូវឱ្យមានការបង្ហាញព័ត៌មាន និងរបាយការណ៍ជាប្រចាំដល់វិនិយោគិន និងទីផ្សារឱ្យបានទូលំទូលាយលើការប្រើប្រាស់ទុនពីការបោះផ្សាយ និងបច្ច័យនៃការអនុវត្តគម្រោង។ ជាទូទៅ, សញ្ញាបណ្ណរដ្ឋតាមវិស័យ អាចត្រូវបានបែងចែកជាប្រភេទ ដូចខាងក្រោម៖

– **សញ្ញាបណ្ណរដ្ឋបៃតង** (Green Government Bond) ដែលត្រូវបានបោះផ្សាយដើម្បីហិរញ្ញប្បទាន គម្រោងដែលផ្តល់គុណប្រយោជន៍ដល់បរិស្ថាន ដូចជាគម្រោងដែលពាក់ព័ន្ធនឹង៖ ថាមពលកកើតឡើងវិញ, ប្រសិទ្ធភាព

ថាមពល, ការទប់ស្កាត់ការបំពុល, ការគ្រប់គ្រងនៃធនធានធម្មជាតិ និងការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព, ការអភិរក្សជីវៈចម្រុះ, ការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ, និងអគារបៃតង។ល។

– **សញ្ញាបណ្ណរដ្ឋសង្គម** (Social Government Bond) ដែលត្រូវបានបោះផ្សាយដើម្បីហិរញ្ញប្បទានគម្រោងដែលផ្តល់គុណប្រយោជន៍ដល់សង្គម ដូចជាគម្រោងដែលពាក់ព័ន្ធនឹង៖ ការផ្តល់សេវាសាធារណៈល្អប្រសើរ, ការបង្កើតការងារ, ការធានាសន្តិសុខស្បៀង, និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតម្លៃសមរម្យសម្រាប់ការរស់នៅ ដោយរួមទាំងលំនៅឋានតម្លៃសមរម្យ។ល។

– **សញ្ញាបណ្ណរដ្ឋនិរន្តរភាព** (Sustainability Government Bond) ដែលត្រូវបានបោះផ្សាយដើម្បីហិរញ្ញប្បទានគម្រោងទាំងឡាយណាដែលផ្តល់គុណប្រយោជន៍ដល់សង្គម និងបរិស្ថាន។

– **សញ្ញាបណ្ណរដ្ឋផ្សារភ្ជាប់នឹងនិរន្តរភាព** (Sustainability-linked Government Bond) ដែលត្រូវបានបោះផ្សាយដើម្បីគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រដ្ឋាភិបាល ដោយត្រូវវាស់វែងតាមរយៈសូចនាករសមិទ្ធកម្មគន្លឹះ។

– **សញ្ញាបណ្ណរដ្ឋខៀវ** (Blue Government Bond) ដែលត្រូវបានបោះផ្សាយដើម្បីហិរញ្ញប្បទានគម្រោងដែលពាក់ព័ន្ធនឹងសមុទ្រ ហើយផ្តល់គុណប្រយោជន៍ដល់បរិស្ថាន ដូចជា៖ ការស្តារប្រព័ន្ធអេកូឡូស៊ី សមុទ្រ, ការកាត់បន្ថយការបំពុលដែលបង្កដោយការដឹកជញ្ជូនតាមផ្លូវសមុទ្រ, និងការគ្រប់គ្រងតំបន់ឆ្នេរ ប្រកបដោយចីរភាព។ល។

– **សញ្ញាបណ្ណរដ្ឋតាមវិស័យប្រភេទផ្សេងទៀត** ដែលត្រូវបានបោះផ្សាយ ដើម្បីដោះស្រាយ ឬគ្រប់គ្រងស្ថានការណ៍បន្ទាន់ណាមួយ ដូចជា៖ សញ្ញាបណ្ណជំងឺរាតត្បាត (Pandemic Bond) និងសញ្ញាបណ្ណគ្រោះមហន្តរាយ (Disaster Bond) ជាដើម។

**ដ្យាក្រាមទី១៖ ប្រភេទសញ្ញាបណ្ណរដ្ឋតាមវិស័យ**




## ខ. គោលការណ៍នៃការបោះផ្សាយ

ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ ទាមទារឱ្យមានគោលការណ៍ច្បាស់លាស់ក្នុងការ៖ i) កំណត់លក្ខខណ្ឌវិនិច្ឆ័យសម្រាប់គម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (Eligible Project), ii) វាយតម្លៃ និងជ្រើសរើសគម្រោង, iii) ចាត់ចែងទុនទទួលបានពីការបោះផ្សាយ, និង iv) រៀបចំរបាយការណ៍។ ដើម្បីបង្កើនតម្លាភាពនៃការបោះផ្សាយ និងទំនុកចិត្តរបស់វិនិយោគិន, ការកំណត់គោលការណ៍ទាំងនេះ ត្រូវស្របតាមគោលការណ៍ជាអន្តរជាតិណាមួយខាងក្រោម៖

– **គោលការណ៍របស់ International Capital Market Association (ICMA)** ដែលរួមមាននូវគោលការណ៍ក្នុងការបោះផ្សាយលក់សញ្ញាបណ្ណបៃតង (Green Bond Principles), សញ្ញាបណ្ណសង្គម (Social Bond Principles), សញ្ញាបណ្ណនិរន្តរភាព (Sustainability Bond Principles), និងសញ្ញាបណ្ណផ្សារភ្ជាប់នឹងនិរន្តរភាព (Sustainability-Linked Bond Principles)។ ជារួម, គោលការណ៍របស់ ICMA មានភាពទូលំទូលាយ ដែលអនុញ្ញាតឱ្យអ្នកបោះផ្សាយអាចមានភាពបត់បែនក្នុងការកំណត់ប្រភេទសញ្ញាបណ្ណរដ្ឋតាមវិស័យ និងលក្ខខណ្ឌវិនិច្ឆ័យសម្រាប់គម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

– **គោលការណ៍របស់ Climate Bonds Initiative (CBI)** ដែលត្រូវបានបង្កើតឡើងស្របតាមគោលការណ៍សញ្ញាបណ្ណបៃតងរបស់ ICMA និងកិច្ចព្រមព្រៀងអាកាសធាតុទីក្រុងប៉ារីស (Paris Climate Agreement)។ គោលការណ៍នេះ ផ្តោតតែលើការបោះផ្សាយលក់សញ្ញាបណ្ណបៃតងប៉ុណ្ណោះ ហើយមានលក្ខខណ្ឌវិនិច្ឆ័យតឹងរឹងក្នុងការចាត់ជាគម្រោងដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

– **គោលការណ៍របស់ ASEAN Capital Markets Forum (ACMF)** ដែលរួមមានគោលការណ៍ក្នុងការបោះផ្សាយលក់សញ្ញាបណ្ណបៃតង (ASEAN Green Bond Standards), សញ្ញាបណ្ណសង្គម (ASEAN Social Bond Standards), សញ្ញាបណ្ណនិរន្តរភាព (ASEAN Sustainability Bond Standards), និងសញ្ញាបណ្ណផ្សារភ្ជាប់នឹងនិរន្តរភាព (ASEAN Sustainability-Linked Bond Standards)។ គោលការណ៍នេះ ត្រូវបានបង្កើតឡើងស្របតាមគោលការណ៍របស់ ICMA និងសម្រាប់អនុវត្តនៅតាមបណ្តាប្រទេសជាសមាជិកអាស៊ាន (ASEAN Issuer) ឬសម្រាប់គម្រោងដែលស្ថិតក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន។ ទន្ទឹមនេះ, ក្នុងទិសដៅជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព (Sustainable Finance) និងធានាសង្គតិភាពនៃការចាត់ថ្នាក់គម្រោង ឬសកម្មភាពដែលឆ្លើយតបទៅនឹងរបៀបវារៈប្រកបដោយចីរភាព (Sustainability Agenda), វត្ថិករសាស្ត្រអាស៊ាន (ASEAN Taxonomy) ក៏ត្រូវបានរៀបចំបន្ថែមពីលើគោលការណ៍ និង/ឬស្តង់ដារបស់ ACMF ផងដែរ។

ជាការអនុវត្ត, ការកំណត់គោលការណ៍នៃការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យនៅតាមបណ្តាប្រទេសនានា អាចមានលក្ខណៈផ្សេងៗគ្នា ប៉ុន្តែជាទូទៅ មានមូលដ្ឋានស្របតាមគោលការណ៍ជាអន្តរជាតិខាងលើ (អាចមួយ ឬលើសពីមួយ) ក្នុងនោះ គោលការណ៍ដែលត្រូវបានប្រើប្រាស់ច្រើនជាងគេ គឺគោលការណ៍របស់ ICMA។

### គ. ដំណាក់កាលនៃការបោះផ្សាយ

ផ្អែកតាមឧត្តមានុវត្តន៍ជាអន្តរជាតិ, ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ ត្រូវបានបែងចែកជា ៤ ដំណាក់កាលសំខាន់ៗ រួមមាន៖ ដំណាក់កាលពិនិត្យសមិទ្ធលទ្ធភាព, ដំណាក់កាលមុនពេលបោះផ្សាយ, ដំណាក់កាលបោះផ្សាយ, និងដំណាក់កាលក្រោយពេលបោះផ្សាយ ដូចមានលម្អិតខាងក្រោម៖

– **ដំណាក់កាលពិនិត្យសមិទ្ធលទ្ធភាព** ដែលស្ថាប័នបោះផ្សាយ ត្រូវពិនិត្យអំពីតម្រូវការហិរញ្ញប្បទានគម្រោងគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព, សន្និទានភាពក្នុងការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ, ពិភាក្សាជាមួយភាគីពាក់ព័ន្ធដើម្បីកំណត់គម្រោងសក្តានុពល, និងបង្កើតយន្តការសម្របសម្រួលលើការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ។

– **ដំណាក់កាលមុនពេលបោះផ្សាយ** ដែលស្ថាប័នបោះផ្សាយត្រូវ៖ i) ចាត់ឱ្យមានភ្នាក់ងារជោនាទិញ និងទីប្រឹក្សាច្បាប់, ii) រៀបចំគោលការណ៍ណែនាំសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណតាមវិស័យ, iii) ស្នើសុំការវាយតម្លៃលើគោលការណ៍ណែនាំពីអ្នកត្រួតពិនិត្យឯករាជ្យ (Independent Verifier), iv) បង្កើនភាពជឿជាក់ដល់វិនិយោគិន (Credit Enhancement), v) ពង្រឹងទំនាក់ទំនងជាមួយវិនិយោគិន (Investor Outreach), vi) គ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (Financial Risk Management), vii) ពិនិត្យសម្រេចលើការចុះបញ្ជីជួញដូរ និងការធ្វើចំណាត់ថ្នាក់

ឥណទានសម្រាប់សញ្ញាបណ្ណដែលត្រូវបោះផ្សាយ (Listing and Credit Rating), និង viii) រៀបចំប្រព័ន្ធសម្រាប់ការតាមដាន និងរាយការណ៍លើការប្រើប្រាស់ទុន (Set up Tracking and Reporting)។

– **ដំណាក់កាលបោះផ្សាយ** ដែលក្នុងដំណាក់កាលនេះ កិច្ចការសំខាន់ៗដែលត្រូវបំពេញមានដូចជា៖ ផ្សព្វផ្សាយជូនសាធារណៈជនអំពីការបោះផ្សាយ, ស្វែងរកវិនិយោគិនមកទិញសញ្ញាបណ្ណ, រៀបចំកម្មវិធីផ្សព្វផ្សាយលក់ (Roadshow), និងកិច្ចការបច្ចេកទេសផ្សេងទៀតពាក់ព័ន្ធនឹងការបោះផ្សាយ, ទូទាត់ និងចុះបញ្ជី ដែលកិច្ចការទាំងនេះ ជាទូទៅ រៀបចំដោយអ្នកជានាទិញ។

– **ដំណាក់កាលក្រោយពេលបោះផ្សាយ** ដែលស្ថាប័នបោះផ្សាយត្រូវតាមដាន និងរៀបចំរបាយការណ៍លើការប្រើប្រាស់ទុនដែលទទួលបានពីការបោះផ្សាយ ព្រមទាំងរបាយការណ៍ស្ដីពីការវាយតម្លៃក្រោយបញ្ចប់គម្រោង (Impact Measurement)។

ជារួម, ដំណើរការនៃការបោះផ្សាយសញ្ញាបណ្ណរដ្ឋតាមវិស័យ មានលក្ខណៈបច្ចេកទេសស្មុគស្មាញ, ប្រើប្រាស់ពេលវេលាច្រើន និងចំណាយប្រតិបត្តិការខ្ពស់លើការធ្វើចំណាត់ថ្នាក់ឥណទានសម្រាប់សញ្ញាបណ្ណដែលត្រូវបោះផ្សាយ, ការរៀបចំកម្មវិធីផ្សព្វផ្សាយលក់, សេវាភ្នាក់ងារជានាទិញ, សេវាទីប្រឹក្សាច្បាប់, និងសេវាភ្នាក់ងារត្រួតពិនិត្យឯករាជ្យ ជាដើម។

### ៣.១.៥. ការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស

#### ក. ទិដ្ឋភាពទូទៅ

មូលបត្ររដ្ឋនៅក្រៅប្រទេស (International Bond) សំដៅដល់សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល នៅលើទីផ្សារអន្តរជាតិ។ ការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស អនុញ្ញាតឱ្យរដ្ឋាភិបាល មានលទ្ធភាពកៀរគរទុនបន្ថែមពីមូលដ្ឋានវិនិយោគិនផ្សេងៗបានកាន់តែទូលំទូលាយ ព្រមទាំងជួយជំរុញដល់ការអនុវត្តវិន័យម៉ាក្រូសេដ្ឋកិច្ច និងពង្រឹងតម្លាភាព ប៉ុន្តែមុននឹងសម្រេចបោះផ្សាយមូលបត្ររដ្ឋនៅក្រៅប្រទេស រដ្ឋាភិបាលត្រូវបំពេញនូវបុរេលក្ខខណ្ឌមួយចំនួន និងពិនិត្យលើទិដ្ឋភាពសំខាន់ៗ ជាពិសេស ទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និងបំណុលសាធារណៈ។

ជារួម, គុណសម្បត្តិ និងគុណវិបត្តិចម្បងៗ នៃការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស មានដូចក្នុងតារាងទី២ ខាងក្រោម៖

**តារាងទី២៖ គុណសម្បត្តិ និងគុណវិបត្តិនៃការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស**

| គុណសម្បត្តិ | គុណវិបត្តិ |
|---|---|
| - មិនពឹងផ្អែកទាំងស្រុងលើវិស័យឯកជនក្នុងប្រទេស ឬមិនដណ្ដើមចំណែកខ្ចីពីទីផ្សារក្នុងប្រទេស<br>- អនុញ្ញាតឱ្យរដ្ឋាភិបាលធ្វើពិពិធកម្មប្រភពហិរញ្ញប្បទាន និងកែលម្អចង្កោមបំណុល<br>- ជំរុញការអនុវត្តវិន័យម៉ាក្រូសេដ្ឋកិច្ច និងពង្រឹងតម្លាភាពនៃការអនុវត្តគោលនយោបាយសារពើពន្ធ<br>- ជួយពង្រីកមូលដ្ឋានវិនិយោគិន ហើយអត្រាគូប៉ុងអាចទាបជាងអត្រាគូប៉ុងក្នុងស្រុក<br>- បង្កើតឱ្យមានអត្រាការប្រាក់គោលក្នុងទីផ្សារអន្តរជាតិ សម្រាប់អ្នកខ្ចីក្នុងប្រទេសផ្សេងទៀត។ | - ត្រូវគោរពតាមទិដ្ឋភាពច្បាប់អន្តរជាតិ ហើយអាចប្រឈមនឹងការអនុវត្តលក្ខខណ្ឌហិរញ្ញវត្ថុអន្តរជាតិ<br>- ប្រឈមនឹងហានិភ័យរូបិយប័ណ្ណខ្ពស់ និងអាចធ្វើឱ្យប៉ះពាល់ដល់តម្លៃរូបិយវត្ថុជាតិ ព្រោះភាគច្រើនបោះផ្សាយជារូបិយប័ណ្ណបរទេស<br>- ត្រូវផ្ដល់ព័ត៌មានជាប្រចាំពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសបោះផ្សាយដល់ទីផ្សារ<br>- មានចំណាយប្រតិបត្តិការខ្ពស់ និងត្រូវការរយៈពេលច្រើនក្នុងការរៀបចំ<br>- ទាមទារឱ្យមានសមត្ថភាពក្នុងការតាមដានទីផ្សារអន្តរជាតិ ដែលមានភាពស្មុគស្មាញ និងប្រែប្រួលលឿន។ |

### ខ. បុរេលក្ខខណ្ឌសំខាន់ៗ

ដើម្បីអាចបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស ប្រកបដោយប្រសិទ្ធភាពខ្ពស់, ប្រទេសបោះផ្សាយត្រូវបំពេញនូវបុរេលក្ខខណ្ឌសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- មានទីផ្សារមូលបត្ររដ្ឋក្នុងប្រទេស ដំណើរការល្អ
- មានចំណាត់ថ្នាក់ឥណទានរបស់ប្រទេសល្អ តាមរយៈ៖ ការរក្សាបាននូវស្ថិរភាពនយោបាយ, ស្ថានភាពសេដ្ឋកិច្ចល្អប្រសើរ និងកំណើនរឹងមាំ, អតិផរណាទាប, ចីរភាពថវិកា, ចីរភាពបំណុលសាធារណៈ និងការទូទាត់សេវាបំណុលបានទៀងទាត់ ព្រមទាំងការចែករំលែក និងផ្សព្វផ្សាយព័ត៌មាន/ទិន្នន័យឱ្យបានទូលំទូលាយ ជាពិសេស ពាក់ព័ន្ធនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច, និង
- មានការគិតគូរបោះផ្សាយមូលបត្ររដ្ឋនៅក្រៅប្រទេស នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ និងត្រូវមានសមត្ថភាពស្ថាប័ននិងធនធានមនុស្សគ្រប់គ្រាន់ សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ។

ទន្ទឹមនេះ, ប្រទេសបោះផ្សាយ ក៏ត្រូវពិនិត្យផងដែរលើភាពអំណោយផលសម្រាប់ការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស ដូចជា៖ ស្ថានភាពទីផ្សារសកលមានស្ថិរភាព និងកម្រិតអតិផរណាសមស្រប, ទីផ្សារមានកម្រិតសន្ទនីយភាពខ្ពស់ និងលក្ខខណ្ឌល្អប្រសើរ (អត្រាការប្រាក់ទាប), និងតម្រូវការពីវិនិយោគិនលើមូលបត្ររបស់ប្រទេសបោះផ្សាយ។

ក្នុងចំណោមបុរេលក្ខខណ្ឌខាងលើ, ការមានចំណាត់ថ្នាក់ឥណទានរបស់ប្រទេសល្អ គឺជាបុរេលក្ខខណ្ឌចាំបាច់ជាងគេ។ ជាឧត្តមានុវត្តន៍, ដើម្បីអាចធានាបាននូវថ្លៃដើម និងហានិភ័យទាប (Low Cost and Risk) ប្រទេសបោះផ្សាយ ត្រូវមានចំណាត់ថ្នាក់ឥណទានរបស់ប្រទេស (Sovereign Credit Rating) ក្នុងកម្រិតវិនិយោគ (Investment Grade)។ ភាគច្រើន, ការវាយតម្លៃចំណាត់ថ្នាក់ឥណទានរបស់ប្រទេស ត្រូវបានធ្វើឡើងដោយក្រុមហ៊ុនអន្តរជាតិធំៗ ចំនួន ៣ គឺ៖ S&P (Standard & Poor's Ratings Services), Moody's (Moody's Investors Service), និង Fitch (Fitch Ratings, Ltd) ដែលប្រើប្រាស់វិធីសាស្ត្រ និងកម្រិតចំណាត់ថ្នាក់ផ្សេងៗគ្នា ដូចមានក្នុងតារាងទី៣ ខាងក្រោម៖

### តារាងទី៣៖ កម្រិតចំណាត់ថ្នាក់ឥណទាន

| កម្រិត | S&P | Moody's | Fitch |
|---|---|---|---|
| កម្រិតវិនិយោគ (Investment Grade) | AAA | Aaa | AAA |
| | AA+ | Aa1 | AA+ |
| | AA | Aa2 | AA |
| | AA- | Aa3 | AA- |
| | A+ | A1 | A+ |
| | A | A2 | A |
| | A- | A3 | A- |
| | BBB+ | Baa1 | BBB+ |
| | BBB | Baa2 | BBB |
| | BBB- | Baa3 | BBB- |
| កម្រិតមិនមែនវិនិយោគ (Non-Investment Grade) | BB+ | Ba1 | BB+ |
| | BB | Ba2 | BB |
| | BB- | Ba3 | BB- |
| | B+ | B1 | B+ |
| | B | B2 | B |
| | B- | B3 | B- |
| | CCC+ | Caa1 | CCC |
| | CCC | Caa2 | - |
| | CCC- | Caa3 | - |
| | CC | Ca | CC |
| | C | - | C |
| | D | C | D |

*ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)*

ជាទូទៅ, ការវាយតម្លៃចំណាត់ថ្នាក់ឥណទានរបស់ប្រទេសចែកចេញជា ២ ប្រភេទគឺ៖ ១) ការវាយតម្លៃចំណាត់ថ្នាក់ឥណទានមិនផ្លូវការ (Unsolicited Sovereign Credit Rating) ដែលធ្វើឡើងដោយក្រុមហ៊ុនវាយតម្លៃចំណាត់ថ្នាក់ឥណទាន ដោយពុំមានការស្នើសុំពីប្រទេសបោះផ្សាយ និង ២) ការវាយតម្លៃចំណាត់ថ្នាក់ឥណទានផ្លូវការ (Solicited Sovereign Credit Rating) ដែលធ្វើឡើងដោយក្រុមហ៊ុនវាយតម្លៃចំណាត់ថ្នាក់ឥណទាន ដោយមានការស្នើសុំពីប្រទេសបោះផ្សាយ ហើយត្រូវបង់កម្រៃសេវា និងផ្តល់ទិន្នន័យផ្លូវការ។ ការរៀបចំឱ្យមានការវាយតម្លៃចំណាត់ថ្នាក់ឥណទានផ្លូវការ ផ្តល់អត្ថប្រយោជន៍មួយចំនួន ដូចជា៖ i) ទទួលបានចំណាត់ថ្នាក់ខ្ពស់ជាងការវាយតម្លៃក្រៅផ្លូវការ ដោយហេតុថា ការវាយតម្លៃត្រូវបានធ្វើឡើងដោយផ្អែកលើទិន្នន័យផ្លូវការផ្តល់ដោយប្រទេសបោះផ្សាយ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយត្រូវឆ្លងកាត់យន្តការពិនិត្យបញ្ជាក់ទៅវិញទៅមកជាច្រើនលើកច្រើនសារអំពីដំណើរការ និងលទ្ធផលនៃការវាយតម្លៃ, ii) អាចបង្កើនទំនុកចិត្ត និងទាក់ទាញការចូលរួមពីវិនិយោគិន, និង iii) អាចកៀរគរទុនបានក្នុងថ្លៃដើមទាប ព្រោះមិនត្រូវចំណាយគូប៉ុង និងអប្បហារច្រើន។ ដោយឡែក, ក្នុងករណីដែលគ្មានការវាយតម្លៃចំណាត់ថ្នាក់ឥណទានផ្លូវការ ការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេសនៅតែរៀបចំទៅបាន ប៉ុន្តែ ប្រទេសបោះផ្សាយ នឹងត្រូវចំណាយធនធានហិរញ្ញវត្ថុកាន់តែច្រើន ព្រោះចាំបាច់ត្រូវបន្ថែមការចំណាយលើការប្រើប្រាស់សេវាធានាឥណទាន។ តាមរយៈនេះ, បណ្តាប្រទេសនានា ជាពិសេស ប្រទេសដែលត្រៀមឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេសជាលើកដំបូង តែងរៀបចំឱ្យមានយន្តការសម្របសម្រួលច្បាស់លាស់ ដើម្បីធានាបាននូវចំណាត់ឥណទានល្អ។

ទោះជាយ៉ាងនេះក្តី, ការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស ជាកិច្ចការដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញ ព្រមទាំងត្រូវចំណាយពេលវេលា និងធនធានច្រើន ទាំងធនធានមនុស្ស និងហិរញ្ញវត្ថុ ជាពិសេស ចំណាយលើការវាយតម្លៃចំណាត់ថ្នាក់ឥណទានផ្លូវការ (នេះមិនទាន់គិតដល់បន្ទុកចំណាយពាក់ព័ន្ធផ្សេងៗផង) ដែលការណ៍នេះ ទាមទារឱ្យមានការត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុន ព្រមទាំងថ្លឹងថ្លែងឱ្យបានម៉ត់ចត់អំពីគុណសម្បត្តិ និងគុណវិបត្តិ។

### គ. ជំហាននៃការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស

ជាការអនុវត្តទូទៅ, ការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស មាន ៦ ជំហានសំខាន់ៗ ដូចខាងក្រោម៖

– **ជំហានទី១៖** បង្កើតក្រុមការងារបច្ចេកទស ដើម្បីទទួលបន្ទុកលើការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស, សិក្សាសមិទ្ធិលទ្ធភាព, និងកំណត់ឧបករណ៍មូលបត្ររដ្ឋដែលត្រូវបោះផ្សាយ។

– **ជំហានទី២៖** ជ្រើសរើសក្រុមហ៊ុនជានាទិញនិងចាត់ចែងការបោះផ្សាយ និងទីប្រឹក្សាច្បាប់ ដែលជាតួអង្គសំខាន់បំផុត និងពុំអាចខ្វះបាន។ បន្ថែមលើនេះ, ប្រទេសបោះផ្សាយជាលើកដំបូង ឬមិនទាន់មានបទពិសោធន៍ក៏ជ្រើសរើសផងដែរនូវទីប្រឹក្សាផ្តល់យោបល់លើការជ្រើសរើសក្រុមហ៊ុនជានាទិញនិងចាត់ចែងការបោះផ្សាយ និងទីប្រឹក្សាផ្តល់យោបល់លើការជ្រើសរើសភ្នាក់ងារដើម្បីធ្វើការវាយតម្លៃចំណាត់ថ្នាក់ឥណទាន (Credit Rating)។

– **ជំហានទី៣៖** រៀបចំព្រឹត្តិបត្រព័ត៌មាន (Prospectus) ដើម្បីផ្សព្វផ្សាយជាសាធារណៈ និងឯកសារពាក់ព័ន្ធនានាដើម្បីបំពេញនីតិវិធីក្នុងការបោះផ្សាយ ហើយកិច្ចការនេះរៀបចំដោយក្រុមហ៊ុនជានាទិញនិងចាត់ចែងការបោះផ្សាយ និងទីប្រឹក្សាច្បាប់ដែលបានជ្រើសរើស។

– **ជំហានទី៤៖** រៀបចំកម្មវិធីផ្សព្វផ្សាយលក់មូលបត្ររដ្ឋ (Roadshow) ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនដល់វិនិយោគិនអំពីស្ថានភាពរបស់ប្រទេសបោះផ្សាយ និងលក្ខខណ្ឌចូលរួម។

– **ជំហានទី៥៖** ពិនិត្យពិភាក្សាជាមួយក្រុមហ៊ុនជានាទិញនិងចាត់ចែងការបោះផ្សាយ លើស្ថានភាពនិងតម្រូវការទីផ្សារជាក់ស្តែង ដើម្បីកំណត់កាលវិភាគ និងអនុវត្តការបោះផ្សាយ។

– **ជំហានទី៦៖** ទូទាត់សេវាបំណុលជូនវិនិយោគិនឱ្យបានទៀងទាត់ និងបន្តទាក់ទងជាប្រចាំជាមួយក្រុមហ៊ុនជានាទិញនិងចាត់ចែងការបោះផ្សាយ ដើម្បីតាមដានអំពីបម្រែបម្រួលតម្លៃមូលបត្រ។

## ៣.២. បរិការណ៍កម្ពុជា

### ៣.២.១. ក្របខ័ណ្ឌគតិយុត្ត, គោលនយោបាយ និងយុទ្ធសាស្ត្រ

### ក. ក្របខ័ណ្ឌគតិយុត្ត

តាមរយៈកិច្ចខិតខំប្រឹងប្រែងកន្លងមក, រាជរដ្ឋាភិបាលកសាងបាននូវក្របខ័ណ្ឌគតិយុត្តសំខាន់ៗមួយចំនួនដែលជាមូលដ្ឋានគ្រឹះ ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ប្រកបដោយចីរភាព ព្រមទាំងដើម្បីគាំទ្រ និងជំរុញដល់ការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា មានជាអាទិ៍៖

– **«ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ»** (ថ្មី) **ឆ្នាំ២០២៣** ដែលត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដើម្បីជំនួសច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈចាស់ ឆ្នាំ២០០៨។ ច្បាប់នេះ ជាច្បាប់គោលកំណត់ច្បាស់អំពីការគ្រប់គ្រងបំណុលសាធារណៈតាមប្រព័ន្ធមជ្ឈការ ដោយមាត្រា ៧៨ នៃច្បាប់នេះ បានបញ្ញត្តថា «ស្ថិតក្រោមលក្ខខណ្ឌ និងកម្រិតកំណត់នៃសិទ្ធិអំណាចដែលបានផ្តល់ក្នុងច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុម្នាក់គត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ រួមបញ្ចូលនូវការបោះផ្សាយលក់មូលបត្ររដ្ឋ ការទទួលហិរញ្ញប្បទានឥតសំណង ការវិនិយោគលើទ្រព្យសកម្មហិរញ្ញវត្ថុ ការធានា

និងការសន្យាផ្នែកហិរញ្ញវត្ថុនានា និងមានសិទ្ធិក្នុងការឱ្យប្រាក់គេខ្ចី ទាំងក្នុងនិងក្រៅប្រទេស។ ក្រៅពីនេះ គ្មានអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតណាមួយ មានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ ឬឱ្យប្រាក់គេខ្ចី ឬចេញជាលិខិតជានា ឬក៏ធ្វើទង្វើណាផ្សេងៗទៀត ដោយផ្ទាល់ឬដោយប្រយោល ដែលអាចនាំឱ្យកើតមាននូវបំណុល ឬបន្ទុកហិរញ្ញវត្ថុផ្សេងទៀត ដោយផ្ទាល់ ឬដោយប្រយោលដល់ព្រះរាជាណាចក្រកម្ពុជា បានទេ»។

– **«ច្បាប់ស្តីពីមូលបត្ររដ្ឋ»** (ថ្មី) ដែលត្រូវបានដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ ដើម្បីជំនួសច្បាប់ស្តីពីមូលបត្ររដ្ឋចាស់ ឆ្នាំ២០០៧។ ច្បាប់ស្តីពីមូលបត្ររដ្ឋឆ្នាំ២០២០ គឺជាមូលដ្ឋានគតិយុត្តគ្រប់ជ្រុងជ្រោយមួយ ដែលមានគោលបំណងផ្តល់នូវក្របខ័ណ្ឌរួមសម្រាប់គ្រប់គ្រងការបោះផ្សាយ, ការជួញដូរ, និងការគ្រប់គ្រងមូលបត្ររដ្ឋប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងសាច់ប្រាក់របស់រាជរដ្ឋាភិបាល ឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ព្រមទាំងអភិវឌ្ឍទីផ្សារមូលបត្រ និងទីផ្សារហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាដើម្បីគាំទ្រដល់គម្រោងអាទិភាព និងចាំបាច់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល។ អនុលោមតាមច្បាប់ស្តីពីមូលបត្ររដ្ឋឆ្នាំ២០២០, ការបោះផ្សាយលក់មូលបត្ររដ្ឋត្រូវកំណត់ឱ្យបានច្បាស់លាស់នូវមុខសញ្ញាចំណាយនៃតម្រូវការហិរញ្ញប្បទានរបស់រដ្ឋ ហើយចំនួនទឹកប្រាក់សរុបនៃការបោះផ្សាយមូលបត្ររដ្ឋ ត្រូវកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។ ជាមួយគ្នានេះ, រាល់ការងារបច្ចេកទេស និងប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្ររដ្ឋ អាចអនុវត្តដោយធនាគារជាតិនៃកម្ពុជា (ធ.ជ.ក.) និង/ឬទីផ្សារមូលបត្រប្រតិស្រុត តាមការសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយគណនីទោលរតនាគារ (Treasury Single Account – TSA) នឹងត្រូវបានប្រើប្រាស់សម្រាប់ការគ្រប់គ្រងប្រតិបត្តិការចំណូល-ចំណាយមូលបត្ររដ្ឋ។

– **«ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន»** ដែលត្រូវបានអនុម័ត និងដាក់ឱ្យប្រើនៅឆ្នាំ២០០៧ ក្នុងគោលដៅគ្រប់គ្រងទីផ្សារមូលបត្រ, ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់, ប្រតិបត្តិកររក្សាទុកមូលបត្រ, និងប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រដែលធ្វើការជួញដូរ ឬផ្តល់សេវាកម្មហិរញ្ញវត្ថុ, ព្រមទាំងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងនីតិបុគ្គលប្រតិស្រុតដែលបោះផ្សាយលក់មូលបត្រ សំដៅរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសង្គម តាមរយៈការកៀរមូលធនពីសាធារណជន ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុសម្រាប់ការវិនិយោគ។

– **«ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា»** ឆ្នាំ១៩៩៦ ដែលមាត្រា ២៣ នៃច្បាប់នេះបានបញ្ញត្តឱ្យ ធ.ជ.ក. ត្រូវជួយគ្រប់គ្រងការខ្ចីប្រាក់របស់រាជរដ្ឋាភិបាល ដោយធ្វើប្រតិបត្តិការលើមូលបត្រមានជាអាទិ៍ ជូនយោបល់លើកាលបរិច្ឆេទនៃការបោះផ្សាយមូលបត្រ និងជំរុញទីផ្សាររូបិយវត្ថុនិងទីផ្សារហិរញ្ញវត្ថុឱ្យរីកចម្រើន ព្រមទាំងអាចទទួលធ្វើជាអាណត្តិគាហក (ភ្នាក់ងារ) របស់រាជរដ្ឋាភិបាលចំពោះប្រតិបត្តិការៈ ១) ទិញ-លក់មូលបត្រដែលបោះផ្សាយដោយរាជរដ្ឋាភិបាល ព្រមទាំងកិច្ចការជាភ្នាក់ងារគណនេយ្យដើម្បីចុះបញ្ជី និងផ្ទេរនូវមូលបត្រនោះ និង ២) ទូទាត់សងដើម និងការប្រាក់ ព្រមទាំងកម្រៃផ្សេងៗលើមូលបត្រនោះ។

– **«ច្បាប់ស្តីពីរបបសន្តិសុខសង្គម»** ឆ្នាំ២០១៩ ដែលបង្កើតឡើងក្នុងគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាឱ្យមានសមធម៌ និងសាមគ្គីធម៌សង្គម និងដើម្បីលើកកម្ពស់សុខុមាលភាពនិងជីវភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះ បានដាក់ចេញនូវរបបភាគទានជាកាតព្វកិច្ចដែលរដ្ឋ និងបុគ្គលនៃវិស័យសាធារណៈមានកាតព្វកិច្ចរួមគ្នាក្នុងការបង់ភាគទាន ហើយក៏មានការកំណត់អំពីគោលការណ៍នៃការគ្រប់គ្រងមូលនិធិ, ការគ្រប់គ្រងផែនការវិនិយោគ, និងកញ្ចប់វិនិយោគផងដែរ។ បន្ថែមលើនេះ, **អនុក្រឹត្យស្តីពីគោលការណ៍**

**ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម** ដែលត្រូវបានរៀបចំ និងអនុម័ត កាលពីខែកុម្ភៈ ឆ្នាំ២០២៣ បានកំណត់នូវសមត្ថកិច្ចជាក់លាក់ដល់និយ័តករសន្តិសុខសង្គម ក្នុងការធ្វើនិយ័តកម្មនិងត្រួតពិនិត្យលើការវិនិយោគមូលនិធិសន្តិសុខសង្គមដោយបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាព, តម្លាភាព, គណនេយ្យភាព, ភាពរឹងមាំផ្នែកហិរញ្ញវត្ថុ, និងកាត់បន្ថយហានិភ័យជាអតិបរមានៃការវិនិយោគមូលនិធិសន្តិសុខសង្គមដោយ ប.ស.ស.។ អនុក្រឹត្យនេះ បានកំណត់អំពីគោលការណ៍នៃការវិនិយោគមូលនិធិសន្តិសុខសង្គមប្រចាំឆ្នាំ ក្នុងនោះ ក៏មានការកំណត់កម្រិតនៃការវិនិយោគលើមូលបត្រផងដែរ។

– **«អនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ»** ឆ្នាំ២០១១ ដែលជាអនុក្រឹត្យគោលសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានរៀបចំឡើងក្នុងគោលដៅកំណត់នូវគោលការណ៍ណែនាំ, គោលនយោបាយ, យុទ្ធសាស្ត្រ, មុខងារគ្រប់គ្រង, និងបទប្បញ្ញត្តិបន្ថែមនានាស្តីពីការគ្រប់គ្រងបំណុលសាធារណៈផងដែរ។ ទោះជាយ៉ាងនេះក្តី, អនុក្រឹត្យនេះ ត្រូវបាននិងកំពុងត្រួតពិនិត្យ និងកែសម្រួលឡើងវិញ ដើម្បីឱ្យស្របតាមច្បាប់ស្តីពីមូលបត្ររដ្ឋ (ថ្មី), ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ក៏ដូចជា បរិការណ៍ជាក់ស្តែងរបស់កម្ពុជា។

– **«អនុក្រឹត្យស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ»** ឆ្នាំ២០២២ ដែលមានវិសាលភាពអនុវត្តចំពោះ៖ ១) ក្រុមហ៊ុន/សហគ្រាសបោះផ្សាយមូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលលើកដំបូងជាសាធារណៈដែលទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត, ២) មូលបត្ររដ្ឋ ដែលសំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលបញ្ជាក់ពីការទទួលស្គាល់បំណុលដែលបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល, ៣) អ្នកវិនិយោគសាធារណៈ ដែលកាន់កាប់ និង/ឬ ទិញ - លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលដែលបានបោះផ្សាយ លក់ជាសាធារណៈ និងបានចុះបញ្ជីជួញដូរមូលបត្រនៅទីផ្សារមូលបត្រប្រតិស្រុត។

អនុក្រឹត្យនេះ បានកំណត់អំពីការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្រ ដែលអ្នកវិនិយោគសាធារណៈត្រូវទទួលបានការបន្ថយពន្ធកាត់ទុក **៥០ (ហាសិប) ភាគរយ** លើប្រាក់ និង/ឬ ភាគលាភដែលបានមកពីការកាន់កាប់ និង/ឬ ការទិញ - លក់មូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល និងត្រូវបានលើកលែងពន្ធលើចំណេញមូលធនចំពោះការទិញ និងការជួញដូរមូលបត្ររដ្ឋ មូលបត្រកម្មសិទ្ធិ និង/ឬ មូលបត្របំណុលសម្រាប់រយៈពេល **៣ (បី) ឆ្នាំ** គិតចាប់ពី**ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២** ដល់**ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥**។ បន្ថែមលើនេះ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដាក់ឱ្យអនុវត្ត **«ប្រកាសស្តីពីការណែនាំអនុវត្តការលើកទឹកចិត្តពន្ធកាត់ទុក និងពន្ធលើចំណេញមូលធនដល់អ្នកវិនិយោគមូលបត្ររដ្ឋ»** ដោយកំណត់អត្រាពន្ធកាត់ទុកលើការប្រាក់នៃមូលបត្ររដ្ឋ **៦ (ប្រាំមួយ) ភាគរយ** ចំពោះការទូទាត់ការប្រាក់ឱ្យដល់អ្នកជាប់ពន្ធនិវាសនជន និង **១៤ (ដប់បួន) ភាគរយ** ចំពោះការទូទាត់ការប្រាក់ឱ្យដល់អ្នកជាប់ពន្ធអនិវាសនជន។ បើទោះជាយ៉ាងនេះក្តី, វិនិយោគិនភាគច្រើន បានលើកឡើងថា គោលនយោបាយផ្តល់ការលើកទឹកចិត្តនេះ នៅមិនទាន់ផ្តល់ភាពទាក់ទាញខ្លាំងទេ ជាពិសេស ចំពោះវិនិយោគិនជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

– **«ប្រកាសស្តីពីការបោះផ្សាយមូលបត្ររដ្ឋ»** ឆ្នាំ២០២២ ដែលកំណត់អំពីអាណត្តិគាហក, កិច្ចការបច្ចេកទេស, និងអង្គភាពសម្របសម្រួលពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្ររដ្ឋ ក្នុងគោលបំណងគ្រប់គ្រងវដ្តនៃការបោះផ្សាយមូលបត្ររដ្ឋ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។

– **«ប្រកាសស្តីពីការអនុញ្ញាតលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង»** ឆ្នាំ២០២២ ដែលត្រូវបានរៀបចំដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងទ្រព្យសកម្ម និងការបំពេញកាតព្វកិច្ចបំណុលរបស់ក្រុមហ៊ុនធានារ៉ាប់រង

ដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប្រកាសនេះ បានអនុញ្ញាតឱ្យក្រុមហ៊ុនធានារ៉ាប់រងវិនិយោគមូលនិធិប្រចាំឆ្នាំនៃទ្រព្យសកម្មលើមូលបត្រក្រោមឈ្មោះរបស់ក្រុមហ៊ុន មិនឱ្យលើសពី ៦០%។

– **«ប្រកាសស្តីពីការប្រើប្រាស់មូលបត្ររដ្ឋក្នុងប្រតិបត្តិការរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា»** ឆ្នាំ២០២២ ដែលកំណត់អំពីការប្រើប្រាស់មូលបត្ររដ្ឋក្នុងប្រតិបត្តិការរូបិយវត្ថុ ក្នុងនោះ ធនាគារជាតិនៃកម្ពុជា អាចជួញដូរមូលបត្ររដ្ឋនៅក្នុងទីផ្សារបន្ទាប់ តាមរយៈផ្លែតហ្វមធនាគារជាតិនៃកម្ពុជា ឬ ផ្លែតហ្វមជួញដូរផ្លូវការផ្សេងទៀត តាមការចាំបាច់ ជាមួយអ្នកចូលរួមទីផ្សារទាំងអស់។ ទន្ទឹមនេះ, ធនាគារជាតិនៃកម្ពុជា អាចប្រើប្រាស់មូលបត្ររដ្ឋ ក្នុងប្រតិបត្តិការរូបិយវត្ថុជាមួយអ្នកចូលរួមទីផ្សារតាមរយៈប្រតិបត្តិការទីផ្សារចំហ។

– **«សារាចរណែនាំស្តីពីការអនុវត្តចំពោះមូលបត្ររដ្ឋដែលកាន់កាប់ដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ»** ឆ្នាំ២០២១ ត្រូវបានដាក់ចេញដោយ ធ.ជ.ក. ក្នុងគោលបំណងរួមចំណែកជំរុញការអភិវឌ្ឍមូលបត្ររដ្ឋ សំដៅអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុជំរុញការធ្វើពិពិធកម្មការកៀរគរប្រភពទុនក្នុងស្រុក និងពង្រឹងការអនុវត្តគោលនយោបាយរូបិយវត្ថុ។ សារាចរនេះ បានទទួលស្គាល់ការថ្លឹងហានិភ័យ 0% (Zero Risk Weighted) ចំពោះមូលបត្ររដ្ឋដែលចារឹកជារូបិយវត្ថុជាតិ ឬជារូបិយប័ណ្ណ ក្នុងការគណនាអនុបាតសាធនភាព (Solvency) និងបានទទួលស្គាល់ជាទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ (High Quality Liquid Asset) ចំពោះមូលបត្ររដ្ឋដែលចារឹកជារូបិយវត្ថុជាតិ ឬជារូបិយប័ណ្ណ នៅក្នុងការគណនាអនុបាតគ្របដណ្តប់សន្ទនីយភាព។ ទន្ទឹមនេះ, ក៏មានការអនុញ្ញាតឱ្យបញ្ចូលការវិនិយោគលើមូលបត្ររដ្ឋក្នុងសំពៀតឥណទានជារូបិយវត្ថុជាតិ ១០% (KHR Loan Portfolio 10%) ដែលកំណត់ដោយប្រកាសស្តីពីការផ្តល់ឥណទានជារូបិយវត្ថុជាតិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ តាមរយៈលិខិតចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ ធ.ជ.ក.។

ជារួម, គ្របខ័ណ្ឌគតិយុត្តខាងលើ គឺជាមូលដ្ឋានស្នូលមិនអាចខ្វះបានក្នុងការជំរុញដល់ការអភិវឌ្ឍមូលបត្ររដ្ឋនៅកម្ពុជា ប៉ុន្តែក៏ចាំបាច់ត្រូវជំរុញការរៀបចំបញ្ចប់នូវសេចក្តីព្រាងលិខិតបទដ្ឋានមួយចំនួនឱ្យបានឆាប់, ការគិតគូររៀបចំបទដ្ឋានគតិយុត្តបំពេញបន្ថែមតាមការចាំបាច់ ព្រមទាំងការពិនិត្យ និងកែសម្រួលឡើងវិញលើបទដ្ឋានគតិយុត្តមួយចំនួនផងដែរ ដើម្បីធានាបាននូវភាពគ្រប់ជ្រុងជ្រោយក្នុងការគ្រប់គ្រងការបោះផ្សាយ ការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, និងចីរភាព។

## ខ. គោលនយោបាយ និងយុទ្ធសាស្រ្ត

ក្រៅពីគ្របខ័ណ្ឌគតិយុត្តខាងលើ, រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្រ្តបញ្ចកោណ-ដំណាក់កាលទី១ ក៏ដូចជាគោលនយោបាយ និងយុទ្ធសាស្រ្តពាក់ព័ន្ធចាំបាច់នានា ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជា ដូចខាងក្រោម៖

– **«យុទ្ធសាស្រ្តបញ្ចកោណ-ដំណាក់កាលទី១»** ដែលបញ្ចកោណទី២ ស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង បានផ្តោតលើអាទិភាពចំនួន ៥ រួមមាន៖ ទី១- ការអភិវឌ្ឍវិស័យគន្លឹះ និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច, ទី២- ការលើកកម្ពស់ការតភ្ជាប់ និងការបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទីក, វិស័យថាមពល, វិស័យទឹកស្អាត និងវិស័យឌីជីថល, ទី៣- ការកែលម្អបរិយាកាសធុរកិច្ច និងការវិនិយោគ, ទី៤- ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញនៃតំបន់សេដ្ឋកិច្ចពិសេស, សួនឧស្សាហកម្ម, សួនកសិ-ឧស្សាហកម្ម និងតំបន់ពាណិជ្ជកម្មសេរីក្នុងស្រុក និងទី៥- ការធ្វើទំនើបកម្មនិងវានុវត្តន៍យន្តការហិរញ្ញប្បទាន និងផលិតផលហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការវិនិយោគ ដែលមានគោលដៅជាយុទ្ធសាស្រ្តក្នុងការរៀបចំ និងការកែលម្អក្របខ័ណ្ឌ និងយន្តការហិរញ្ញប្បទាន,

និងការធ្វើពិពិធកម្មផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ដែលធានាបានសន្ទនីយភាពក្នុងទីផ្សារ និងជម្រើសហិរញ្ញប្បទានសម្រាប់ការវិនិយោគ សំដៅរួមចំណែកជំរុញការវិនិយោគ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច។

– **«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០២៤ - ២០២៨»** ដែលជាផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។ ផែនការយុទ្ធសាស្ត្រនេះកំណត់អំពីតម្រូវការជាយុទ្ធសាស្ត្រនៃចំណាយវិនិយោគសាធារណៈ សំដៅជំរុញនិងទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិក៏ដូចជា ការអភិវឌ្ឍសង្គមជារួម។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលក៏បានដាក់ឱ្យអនុវត្តផងដែរនូវកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល ដើម្បីបង្ហាញពីទិន្នន័យគម្រោងវិនិយោគដែលមានអាទិភាពខ្ពស់របស់ក្រសួង ស្ថាប័ន ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងជាមូលដ្ឋានក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

– **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១ - ២០៣០»** ដែលបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការអនាគតនានា ក្នុងវិស័យធនាគារ និងវិស័យមិនមែនធនាគារ ក្នុងនោះក៏មានការជំរុញការអភិវឌ្ឍមូលបត្ររួមទាំងមូលបត្ររដ្ឋ ដែលជាធាតុដ៏សំខាន់ក្នុងការពង្រឹង និងជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងទីផ្សារ និងទីផ្សាររូបិយវត្ថុផងដែរ។

– **«យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ»** ដែលត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តចំនួន ៣លើករួចមកហើយ ក្នុងនោះ លើកទី១ សម្រាប់ឆ្នាំ២០១១ - ២០១៨, លើកទី២ សម្រាប់ឆ្នាំ២០១៥ - ២០១៨ និងលើកទី៣ សម្រាប់ឆ្នាំ២០១៩ - ២០២៣ ដែលកំពុងត្រូវបានអនុវត្តបច្ចុប្បន្ន។ គោលដៅមួយក្នុងចំណោមគោលដៅផ្សេងទៀតនៃយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩ - ២០២៣ គឺការជំរុញការអភិវឌ្ឍទីផ្សារមូលបត្រក្នុងប្រទេស ដើម្បីធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់ការវិនិយោគសាធារណៈ។ យុទ្ធសាស្ត្រនេះក៏បានកំណត់ផងដែរថា ទុនដែលទទួលបានពីការបោះផ្សាយលក់មូលបត្ររដ្ឋ នឹងត្រូវប្រើប្រាស់សម្រាប់តែហិរញ្ញប្បទានលើគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព ដែលមានសក្តានុពលសេដ្ឋកិច្ច (High Economic Rate of Return), ផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្មខ្ពស់ ឬអាចជាគម្រោងវិនិយោគសាធារណៈរបស់សហគ្រាសសាធារណៈដែលមានចំណូលខ្ពស់ (High Revenue Generated Project/SOE's Project)។

– **«ក្របខ័ណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ»** ដែលត្រូវបានអនុម័តកាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ក្នុងគោលបំណងរៀបចំ និងអនុវត្តផែនការសកម្មភាព ដើម្បីត្រៀមលក្ខណៈឱ្យបានរួចរាល់ក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋក្នុងទីផ្សារជាលើកដំបូងនៅឆ្នាំ២០២២ សំដៅរួមចំណែកបំពេញតម្រូវការហិរញ្ញប្បទានស្របតាម «ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១ - ២០២៣»។ ក្របខ័ណ្ឌគោលនយោបាយនេះ បានដាក់ចេញនូវវិធានការគោលនយោបាយជាអាទិភាពចំពោះមុខចំនួន ៤ រួមមាន ការកំណត់៖ ១) រូបិយប័ណ្ណ និងទំហំនៃការបោះផ្សាយ, ២) គោលការណ៍នៃការប្រើប្រាស់ទុនពីការបោះផ្សាយលក់មូលបត្ររដ្ឋ, ៣) យន្តការនៃការគ្រប់គ្រងចំណូល - ចំណាយពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្ររដ្ឋ, និង ៤) ជំហាននៃការបោះផ្សាយលក់មូលបត្ររដ្ឋ។

### ៣.២.២.យន្តការស្ថាប័ន/សម្របសម្រួល

ទន្ទឹមនឹងក្របខ័ណ្ឌគតិយុត្ត, គោលនយោបាយ និងយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលក៏មានយន្តការស្ថាប័នសម្រាប់ជំរុញការអភិវឌ្ឍមូលបត្ររដ្ឋផងដែរ មានជាអាទិ៍៖

**ក) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.)** ជាសេនាធិការរបស់រាជរដ្ឋាភិបាលតែមួយគត់ ដែលទទួលបានសិទ្ធិស្របតាមច្បាប់ក្នុងការបំពេញមុខងារជាអ្នកបោះផ្សាយលក់មូលបត្ររដ្ឋ។ ក.ស.ហ.វ. មានអគ្គនាយកដ្ឋានសហ-

ប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) ជាអង្គភាពទទួលបន្ទុកគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលសាធារណៈ ដោយរួមទាំងមូលបត្ររដ្ឋ។ ចំពោះការបោះផ្សាយលក់មូលបត្ររដ្ឋ, អ.ស.ប. មានតួនាទីជំរុញការអភិវឌ្ឍ និងគ្រប់គ្រងការបោះផ្សាយលក់មូលបត្ររដ្ឋ ដោយបំពេញភារកិច្ចចម្បងៗ ដូចជា៖ រៀបចំសម្របសម្រួល និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអភិវឌ្ឍមូលបត្ររដ្ឋ, សម្របសម្រួលលើរាល់កិច្ចការបច្ចេកទេសពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ជាមួយអាណត្តិគាហក និងតួអង្គពាក់ព័ន្ធផ្សេងទៀត, រៀបចំ និងផ្សព្វផ្សាយផែនការបោះផ្សាយលក់មូលបត្ររដ្ឋ, ពិគ្រោះយោបល់ជាមួយអ្នកចូលរួមក្នុងទីផ្សារ, គ្រប់គ្រងត្រួតពិនិត្យ តាមដាន និងសម្របសម្រួលការអនុវត្តគម្រោង/កម្មវិធីហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ, ពីការឱ្យខ្ចីផ្ទាល់, និងពីមូលបត្ររដ្ឋ។

**ខ) ធនាគារជាតិនៃកម្ពុជា (ធ.ជ.ក.)** ត្រូវបានចាត់តាំងជាអាណត្តិគាហករបស់ ក.ស.ហ.វ. សម្រាប់ការបោះផ្សាយលក់មូលបត្ររដ្ឋ ដោយត្រូវទទួលបន្ទុកអនុវត្តតួនាទី និងភារកិច្ចសំខាន់ៗ ដូចជា៖ អនុវត្តផែនការបោះផ្សាយលក់ប្រចាំឆ្នាំ, រៀបចំការបោះផ្សាយលក់មូលបត្ររដ្ឋ តាមវិធីសាស្ត្រដែលកំណត់ដោយ ក.ស.ហ.វ., ទូទាត់សាច់ប្រាក់នៃមូលបត្ររដ្ឋ, ទូទាត់ការប្រាក់ និងប្រាក់ដើមទៅអ្នកកាន់មូលបត្ររដ្ឋ, ចុះបញ្ជី និងរក្សាទុកមូលបត្ររដ្ឋ ព្រមទាំងអនុវត្តកិច្ចការបច្ចេកទេសផ្សេងទៀតពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្ររដ្ឋ ស្របតាមប្រកាសស្តីពីការបោះផ្សាយមូលបត្ររដ្ឋ។

**គ) អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** ដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងពង្រឹង និងធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុលើវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មាននិយ័តករចំនួន ៦ ជាសេនាធិការក្នុងការបំពេញមុខងារតាមវិស័យនីមួយៗក្នុងនោះ និយ័តករសំខាន់ៗ ដែលពាក់ព័ន្ធនឹងមូលបត្ររដ្ឋ មានចំនួន ៣ ដូចខាងក្រោម៖

- **និយ័តករមូលបត្រកម្ពុជា** អនុវត្តមុខងារ និងភារកិច្ចដូចមានចែងក្នុងច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យមូលបត្រ ជាអាទិ៍៖ ១) គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងទីផ្សារមូលបត្ររដ្ឋ, ២) ដាក់ឱ្យអនុវត្តគោលនយោបាយ ដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ, ៣) កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ និងដើម្បីផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ, ៤) ដើរតួជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាបណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម ឬ អ្នកវិនិយោគ។
- **និយ័តករសន្តិសុខសង្គម** អនុវត្តមុខងារ និងភារកិច្ចដូចមានចែងក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម, ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ជាអាទិ៍៖ ១) កំណត់បទប្បញ្ញត្តិប្រុងប្រយ័ត្ន, ស្តង់ដាប្រតិបត្តិការ, វិធានចាំបាច់នានា និងគោលការណ៍ណែនាំស្តីពីវិនិយោគមូលនិធិសន្តិសុខសង្គម ព្រមទាំងត្រួតពិនិត្យលើការវិនិយោគមូលនិធិសន្តិសុខសង្គម ដោយរួមទាំងការវិនិយោគលើមូលបត្ររដ្ឋ, ២) តាមដានស្ថានភាពហិរញ្ញវត្ថុរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម, ៣) បង្កើតយន្តការការពារសមាជិកនិងផ្សះផ្សាវិវាទនៅពេលមានទំនាស់, ៤) ត្រួតពិនិត្យអនុលោមភាព ដើម្បីធានាថាប្រតិបត្តិការនៅក្នុងការផ្តល់សេវាសន្តិសុខសង្គមប្រព្រឹត្តទៅដោយតម្លាភាព, គណនេយ្យភាព និងចីរភាពហិរញ្ញវត្ថុ ៥) ត្រួតពិនិត្យ

និងតាមដានអនុលោមភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធសន្តិសុខសង្គមជាធរមាន, ៦) ត្រួតពិនិត្យ, តាមដាន និងវាយតម្លៃលើការអនុវត្តរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម និងតួអង្គពាក់ព័ន្ធ, និង ៧) រៀបចំធ្វើបច្ចុប្បន្នភាព និងស្នើសុំការអនុម័តបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីធ្វើនិយ័តកម្មប្រតិបត្តិករសន្តិសុខសង្គម និងតួអង្គពាក់ព័ន្ធ។

- **និយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.)** អនុវត្តមុខងារ និងភារកិច្ចដូចមានចែងក្នុងច្បាប់ស្តីពីការធានារ៉ាប់រង និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យធានារ៉ាប់រង ជាអាទិ៍៖ ១) រៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃវិស័យធានារ៉ាប់រង និងសោធនឯកជន, ២) ត្រួតពិនិត្យ និងតាមដានអនុលោមភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ពាក់ព័ន្ធនឹងវិស័យធានារ៉ាប់រង និងសោធនជន, ៣) ត្រួតពិនិត្យ តាមដាន និងវាយតម្លៃស្ថានភាពអាជីវកម្ម និងហិរញ្ញវត្ថុដើម្បីធានាភាពរឹងមាំរបស់គ្រឹះស្ថានធានារ៉ាប់រង និងសោធនឯកជន និងកិច្ចការពាក់ព័ន្ធផ្សេងទៀត។ ទន្ទឹមនេះ, ន.ធ.ក. ក៏បំពេញតួនាទីសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍមូលបត្ររដ្ឋផងដែរ តាមរយៈការជួញជំរុញឱ្យវិនិយោគិនក្នុងវិស័យធានារ៉ាប់រងចូលរួមវិនិយោគលើមូលបត្ររដ្ឋ និងសម្របសម្រួលលើការស្វាបស្វង់ទីផ្សារ។

**ឃ) ផ្សារមូលបត្រកម្ពុជា (ផ.ម.ក.)** ជាសហគ្រាសសាធារណៈ ដែលមានទម្រង់ជាក្រុមហ៊ុនចម្រុះ ក្នុងនោះភាគហ៊ុន **៥៥%** កាន់កាប់ដោយរាជរដ្ឋាភិបាលកម្ពុជា (តំណាងដោយ ក.ស.ហ.វ.) និង **៤៥%** កាន់កាប់ដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ ភារកិច្ចចម្បងរបស់ ផ.ម.ក. គឺដើម្បីបង្កើត និងដាក់ឲ្យដំណើរការទីផ្សារមូលបត្រ, ប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ, និងប្រព័ន្ធរក្សាទុកមូលបត្រ ស្របតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។ នៅឆ្នាំ២០១១, ផ.ម.ក. ទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជាធ្វើជាប្រតិបត្តិករទីផ្សារ, ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ, និងប្រតិបត្តិកររក្សាទុកមូលបត្រ។

ដើម្បីឱ្យមូលបត្ររដ្ឋអាចអភិវឌ្ឍទៅបានប្រកបដោយប្រសិទ្ធភាព និងភាពប្រទាក់ក្រឡា, ក.ស.ហ.វ. បានបង្កើត"**ក្រុមការងារបច្ចេកទេសរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ**" ហៅកាត់ថា "**ក.ម.រ.**" ដែលមានសមាសភាពពីអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទ ក.ស.ហ.វ., និយ័តករពាក់ព័ន្ធនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, និង ផ.ម.ក. ព្រមទាំងមាននាយកដ្ឋានគ្រប់គ្រងបំណុល នៃ អ.ស.ប. ជាលេខាធិការដ្ឋាន។ ក្រុមការងារបច្ចេកទេសនេះ មានភារកិច្ចសិក្សា, ស្រាវជ្រាវ និងរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ សម្រាប់បង្កើតជាយន្តការសម្របសម្រួល, អនុវត្ត, គ្រប់គ្រង, តាមដាន និងចាត់ចែងការបោះផ្សាយលក់មូលបត្ររដ្ឋ និងការចុះបញ្ជីមូលបត្រនៅលើទីផ្សារមូលបត្រប្រតិស្រុត។

ទន្ទឹមនេះ, កម្ពុជាមានគណៈកម្មាធិការពាក់ព័ន្ធសំខាន់ចំនួន ២ ដែលត្រូវបានបង្កើតឡើងនាពេលកន្លងមកសម្រាប់ជាយន្តការសម្របសម្រួលកម្រិតគោលនយោបាយ និងជាយន្តការកម្រិតថ្នាក់ជាតិ ក្នុងនោះ រួមមាន៖

i) **គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ** បង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៥៧.សសរ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ និងត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ ស្របតាមការកែសម្រួលរចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាល ដោយមានរដ្ឋមន្ត្រី ក.ស.ហ.វ. ជាប្រធាន ព្រមទាំងមានថ្នាក់ដឹកនាំនៃ ក.ស.ហ.វ. និង ធ.ជ.ក. ជាសមាជិក។ ជារួម, គណៈកម្មាធិការនេះ គឺជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលគោលនយោបាយពាក់ព័ន្ធ សំដៅធានាឱ្យមានសង្គតិភាពរវាងកិច្ចដំណើរការនៃការគ្រប់គ្រងបំណុលសាធារណៈជាមួយនឹងគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថវិកា និងរូបិយវត្ថុ ដែលមានភារកិច្ចចម្បងក្នុងការរៀបចំ

និងត្រួតពិនិត្យការអនុវត្តចក្ខុវិស័យនិងគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ព្រមទាំងពិនិត្យយល់ព្រមលើយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ មុននឹងដាក់សុំការសម្រេចរបស់នាយករដ្ឋមន្ត្រី។

ii) **គណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា** ដឹកនាំដោយនាយករដ្ឋមន្ត្រី និងមានសមាសភាពចូលរួមជាថ្នាក់ដឹកនាំជាន់ខ្ពស់ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា៖ ក.ស.ហ.វ., ធ.ជ.ក., និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ដោយមានតួនាទី និងភារកិច្ចតាមដាន, បង្ការ, ទប់ស្កាត់, គ្រប់គ្រង, ដោះស្រាយវិបត្តិសេដ្ឋកិច្ច និង/ឬហិរញ្ញវត្ថុ ជាយថាហេតុ ដើម្បីធានាឱ្យបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព។

ក្រៅពីយន្តការស្ថាប័នខាងលើ, កម្ពុជាក៏មានតួអង្គពាក់ព័ន្ធផ្សេងទៀតផងដែរ នៅក្នុងវិស័យមូលបត្រជាអាទិ៍៖ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ (Cash Settlement Agent), ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (Registrar, Transfer Agent, and Paying Agent), និងភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល (Bondholder Representative) ព្រមទាំងមូលដ្ឋានវិនិយោគិនសក្តានុពល ដូចជា៖ ធនាគារពាណិជ្ជ, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ, ក្រុមហ៊ុនមូលបត្រ, ក្រុមហ៊ុនធានារ៉ាប់រង, និង ប.ស.ស.។

### ៣.២.៣. ទីផ្សារ

#### ក. ទីផ្សារដំបូង

រាជរដ្ឋាភិបាល ដែលមាន ក.ស.ហ.វ. ជាសេនាធិការ និងដោយមានកិច្ចសហការពី ធ.ជ.ក. ព្រមទាំងការពិគ្រោះយោបល់ជាមួយដៃគូពាក់ព័ន្ធនានា បានចាប់ផ្តើមបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូងនាខែកញ្ញា ឆ្នាំ២០២២។ ការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូង ត្រូវបានរៀបចំដោយគ្មានពាណិជ្ជករ/ភ្នាក់ងារធានាទិញ និងមានកិច្ចដំណើរការ ដូចខាងក្រោម៖

- **ច្រកនៃការបោះផ្សាយ៖** ធ្វើឡើងតាមរយៈ ធ.ជ.ក. ក្នុងនាមជាអាណត្តិគាហក (Fiscal agent) ដោយប្រើប្រាស់ផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (National Bank of Cambodia Platform - NBCP) ដែលបច្ចុប្បន្នប្រព័ន្ធនេះមានសមាជិកតែជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុប៉ុណ្ណោះ។ ដោយឡែក, វិនិយោគិនស្ថាប័នមិនមែនជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អាចចូលរួមវិនិយោគលើមូលបត្ររដ្ឋដែរ ប៉ុន្តែ ត្រូវធ្វើឡើងតាមរយៈភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ (Custodian Agent)។
- **វិធីសាស្ត្របោះផ្សាយ៖** អនុវត្តតាមវិធីសាស្ត្រដេញថ្លៃតម្លៃតែមួយ (Single Price Auction)។
- **ឧបករណ៍មូលបត្ររដ្ឋ៖** មាន ៣ប្រភេទ គឺ ឥណប្រតិទាន ១ឆ្នាំ, ៣ឆ្នាំ, និង ៥ឆ្នាំ។
- **វិនិយោគិនគោលដៅ៖** ផ្តោតលើវិនិយោគិនស្ថាប័ន ដូចជា៖ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ, ប.ស.ស., និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ប៉ុន្តែ តាមការបោះផ្សាយជាក់ស្តែង គឺមានតែគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុប៉ុណ្ណោះ ដែលបានចូលរួមវិនិយោគលើមូលបត្ររដ្ឋ។
- **ការចុះបញ្ជីព័ត៌មាន (Profile listing)៖** ត្រូវបានធ្វើឡើងនៅ ផ.ម.ក.។
- **ការទូទាត់សាច់ប្រាក់ និងការរក្សាទុកមូលបត្ររដ្ឋ៖** ត្រូវបានធ្វើឡើងដោយ ធ.ជ.ក.។

នៅក្នុងឆ្នាំ២០២២, រាជរដ្ឋាភិបាលបានបោះផ្សាយលក់មូលបត្ររដ្ឋសរុបចំនួន **៧២ ប៊ីលានរៀល** (សមមូល នឹងប្រមាណ **១៨ លានដុល្លារអាម៉េរិក**) ស្មើនឹងប្រមាណ **៦%** ធៀបនឹងផែនការបោះផ្សាយប្រចាំឆ្នាំ ដែលអនុញ្ញាតដោយច្បាប់ (១,២ ទ្រីលានរៀល)។ ដោយឡែក, សម្រាប់ឆ្នាំ២០២៣ គិតត្រឹមដំណាច់ត្រីមាសទី១ រាជរដ្ឋាភិបាលបានបោះផ្សាយលក់មូលបត្ររដ្ឋសរុបចំនួន **៩៩,៨០ ប៊ីលានរៀល** (សមមូលនឹងប្រមាណជិត **២៥ លាន**

**ដុល្លារអាម៉េរិក**) ធៀបនឹងផែនការបោះផ្សាយប្រចាំឆ្នាំ ដែលអនុញ្ញាតដោយច្បាប់ (៨១៣ ប៊ីលានរៀល) ពោលគឺសម្រេចបានប្រមាណ **១២%**។

ជារួម, ការរៀបចំបោះផ្សាយមូលបត្ររដ្ឋជាលើកដំបូងរបស់កម្ពុជា បានជួបប្រទះនូវបញ្ហាប្រឈម និងមានភាពខ្វះចន្លោះច្រើន ដែលទាមទារឱ្យរាជរដ្ឋាភិបាល ចាំបាច់ត្រូវគិតគូរដាក់ចេញនូវវិធានការគោលនយោបាយពាក់ព័ន្ធបន្ថែមទៀត ដើម្បីជំរុញឱ្យដំណើរការអភិវឌ្ឍទីផ្សារដំបូងកាន់តែមានវឌ្ឍនភាពល្អប្រសើរ។

**រូបភាពទី១៖ ការអនុវត្តផែនការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូងរបស់កម្ពុជា ក្នុងឆ្នាំ២០២២**




## ខ. ទីផ្សារបន្ទាប់

បច្ចុប្បន្ន, មូលបត្ររដ្ឋដែលត្រូវបានបោះផ្សាយកន្លងមក អាចត្រូវបានជួញដូរតែក្នុងចំណោមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិក នៃផ្លែតហ្វមធនាគារជាតិនៃកម្ពុជា ប៉ុណ្ណោះ។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលបាន និងកំពុងបន្តជំរុញការរៀបចំទីផ្សារបន្ទាប់ឱ្យបានឆាប់ និងពេញលេញ ឬគ្រប់ជ្រុងជ្រោយ តាមរយៈការពន្លឿនការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងការរៀបចំប្រព័ន្ធគាំទ្រទីផ្សារហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់ដំណើរការជួញដូរមូលបត្ររដ្ឋ។

## គ. ទីផ្សាររូបិយវត្ថុ

ដើម្បីអាចបង្កើនលទ្ធភាព និងប្រសិទ្ធភាពរបស់ធនាគារកណ្តាលក្នុងការគ្រប់គ្រងរំហូររូបិយវត្ថុ ជាពិសេសការគ្រប់គ្រងសន្ទនីយភាពក្នុងសេដ្ឋកិច្ច, ការជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ឬទីផ្សាររូបិយវត្ថុ គឺពិតជាមានសារៈសំខាន់បំផុត ហើយការណ៍នេះ ទាមទារជាចាំបាច់នូវវត្តមាននៃមូលបត្ររដ្ឋក្នុងទីផ្សារ ព្រោះមូលបត្ររដ្ឋជាឧបករណ៍ហិរញ្ញវត្ថុគោល ដែលអាចជំរុញការអនុវត្តឧបករណ៍គោលនយោបាយរូបិយវត្ថុឱ្យបានកាន់តែមានប្រសិទ្ធភាពបន្ថែម

ទៀត។ អាស្រ័យដោយអវត្តមាននៃមូលបត្ររដ្ឋនាពេលកន្លងមក, ស្ថានភាពនៃការអភិវឌ្ឍទីផ្សាររូបិយវត្ថុរបស់កម្ពុជា គឺកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ ដោយ ធ.ជ.ក. បានដាក់ឱ្យដំណើរការឧបករណ៍គាំទ្រគោលនយោបាយរូបិយវត្ថុ ក្នុងកម្រិតតិចតួចប៉ុណ្ណោះ តាមរយៈការចេញផ្សាយនូវឧបករណ៍មួយចំនួន មានជាអាទិ៍៖

– **«មូលបត្រអាចជួញដូរបាន (Negotiable Certificate of Deposits - NCD)»** ដែលត្រូវបានចេញផ្សាយដំបូង កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងគោលបំណង ដើរតួនាទីជាវត្ថុធានា ដើម្បីបង្កើន និងពង្រីកការផ្តល់ប្រាក់កម្ចីអន្តរធនាគារប្រកបដោយសុវត្ថិភាព និងហានិភ័យទាប ព្រមទាំងដើម្បីឆ្លើយតបទៅនឹងតម្រូវការវិនិយោគរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយប្រើប្រាស់សន្ទនីយភាពនៅសល់ទំនេរក្នុងរយៈពេលខ្លី និងមធ្យម។

NCD ជាឧបករណ៍ដែលអាចត្រូវបានជួញដូរនៅក្នុងទីផ្សារបន្ទាប់ដែលមានកម្រិតសន្ទនីយភាពខ្ពស់ ហើយអាចត្រូវបានទទួលយកសម្រាប់ប្រតិបត្តិការទទួលទិញវិញ (Repo) នៅក្នុងទីផ្សាររូបិយវត្ថុ។ ស្ថិតក្នុងដំណាក់កាលបណ្តោះអាសន្ន, ធ.ជ.ក. អាចសម្រេចទទួលទិញ NCD មកវិញមុនកាលវសានតាមថ្លៃអប្បហារ ប្រសិនបើអ្នកកាន់កាប់មូលបត្រ មានការលំបាកក្នុងការស្វែងរកអ្នកទិញ នៅក្នុងទីផ្សាររូបិយវត្ថុ ហើយតម្លៃមូលបត្រដែល ធ.ជ.ក. នឹងត្រូវទិញត្រឡប់វិញ នឹងត្រូវអាស្រ័យលើរយៈពេលកាន់កាប់ និងអត្រាអប្បហាររបស់ ធ.ជ.ក.។

NCD ត្រូវបានចេញផ្សាយជាទម្រង់អរូបិយ (Dematerialized) និងចុះបញ្ជីនៅលើផ្ទៃតហ្វមធនាគារជាតិនៃកម្ពុជា ដែលជាប្រព័ន្ធអេឡិចត្រូនិចគ្រប់គ្រងដោយ ធ.ជ.ក. សម្រាប់សម្រាប់រក្សាទុកមូលបត្រ និងធ្វើប្រតិបត្តិការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ កន្លងមក, ធនាគារជាតិនៃកម្ពុជាចេញផ្សាយ NCD តាមសំណើរបស់អ្នកទិញ (Subscription) ដែលអាចជាប្រាក់រៀល (មានឥណប្រតិទានពី ២សប្តាហ៍ ដល់ ៣៦៤ថ្ងៃ) និងជាដុល្លារអាម៉េរិក (មានឥណប្រតិទានពី ១សប្តាហ៍ ដល់ ៣៦៤ថ្ងៃ) ដោយផ្តល់អត្រាការប្រាក់ថេរដែលកំណត់នៅពេលមានការបញ្ជាទិញ ហើយការកំណត់អត្រាការប្រាក់នេះ នឹងប្រែប្រួលអាស្រ័យទៅតាមលក្ខខណ្ឌទីផ្សារ ហើយបែបបទនៃការចុះបញ្ជី និងការផ្ទេរកម្មសិទ្ធិមូលបត្រ ត្រូវធ្វើឡើងដោយ ធ.ជ.ក.។ បើទោះជាយ៉ាងនេះក្តី, ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ ធ.ជ.ក. បានធ្វើការផ្លាស់ប្តូរយន្តការ និងលក្ខខណ្ឌជាវ NCD ទាំងជាប្រាក់រៀល និងដុល្លារអាម៉េរិក គ្រប់ឥណប្រតិទានតាមវិធីសាស្ត្រដេញថ្លៃរៀងរាល់ ២សប្តាហ៍ម្តង ដើម្បីឆ្លុះបញ្ចាំងពីការកំណត់អត្រាការប្រាក់តាមយន្តការទីផ្សារ។

– **«ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (Liquidity Providing Collateralized Operation-LPCO)»** ដែលត្រូវបានដាក់ឱ្យដំណើរការក្នុងអំឡុងខែកញ្ញា ឆ្នាំ២០១៦ គឺជាឧបករណ៍ហិរញ្ញវត្ថុមួយ សម្រាប់ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចទទួលបាននូវកម្ចីជាប្រាក់រៀល ដោយប្រើប្រាស់ NCD ជាវត្ថុធានាតាមរយៈប្រតិបត្តិការទទួលទិញវិញ តាមអត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

– **«ឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី (Marginal Lending Facility-MLF)»** ដែលត្រូវបានដាក់ឱ្យដំណើរការក្នុងអំឡុងខែកញ្ញា ឆ្នាំ២០២១ ដោយធ.ជ.ក.ក្នុងគោលបំណងបន្តអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុ និងជំរុញទីផ្សារអន្តរធនាគារឱ្យកាន់តែមានភាពល្អប្រសើរ។ MLF ជាឧបករណ៍ផ្តល់សន្ទនីយភាពរយៈពេលខ្លី ដែលជួយបំពេញតម្រូវការសន្ទនីយភាពចាំបាច់ជាប្រាក់រៀលសម្រាប់រយៈពេលមួយយប់ (Overnight) និងអាចពន្យារពេលបានតិចជាង ឬស្មើប្រាំថ្ងៃ ដោយមានវត្ថុធានាជា NCD ជាប្រាក់រៀល ឬប្រាក់ដុល្លារអាម៉េរិក និងមូលបត្ររដ្ឋ។

ជារួម, ដើម្បីជំរុញការអភិវឌ្ឍទីផ្សាររូបិយវត្ថុឱ្យបានកាន់តែស៊ីជម្រៅ និងមានសន្ទុះលឿនបន្ថែមទៀត គឺចាំបាច់ត្រូវពឹងផ្អែកខ្លាំងលើវត្តមាន និងភាពរលូននៃដំណើរការទីផ្សារមូលបត្ររដ្ឋ (បណ្ណរតនាគារដែលមានឥណប្រតិទានតិចជាង ១ឆ្នាំ និងសញ្ញាបណ្ណរដ្ឋ) ដោយហេតុថា ការបោះផ្សាយមូលបត្ររដ្ឋឱ្យបានទៀងទាត់ អាចផ្តល់នូវអត្ថប្រយោជន៍សំខាន់ៗជាច្រើន ដែលគាំទ្រដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា។

### ឃ. មូលដ្ឋានវិនិយោគិន

វិនិយោគិនសក្តានុពល នៅក្នុងទីផ្សារមូលបត្ររដ្ឋរបស់កម្ពុជា រួមមាន៖ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, ក្រុមហ៊ុនធានារ៉ាប់រង, ក្រុមហ៊ុនមូលបត្រ, ប.ស.ស., និងវិនិយោគិនបុគ្គល រួមទាំងវិនិយោគិនបរទេស។ ក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូងរបស់កម្ពុជា វិនិយោគិនគោលដៅ ដែលចូលរួមវិនិយោគលើមូលបត្ររដ្ឋ រួមមាន៖ ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ដោយឡែក, ចំពោះការបោះផ្សាយនៅជំហានជាបន្តបន្ទាប់, មូលដ្ឋានវិនិយោគិនគោលដៅ នឹងត្រូវពង្រីកដល់វិនិយោគិនស្ថាប័នដទៃផ្សេងទៀត ក្រៅពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ ដូចជា៖ ក្រុមហ៊ុនធានារ៉ាប់រង និងប្រតិបត្តិករសោធនឯកជន, ប.ស.ស., ក្រុមហ៊ុនមូលបត្រ, មូលនិធិសន្សំ/ វិនិយោគ (Collective investment scheme) និង/ឬ វិនិយោគិនបុគ្គល។

ក្នុងការបោះផ្សាយមូលបត្ររដ្ឋកន្លងមក, រាជរដ្ឋាភិបាល បានធ្វើការស្ទាបស្ទង់អំពីតម្រូវទីផ្សារ និងផ្សព្វផ្សាយនូវផែនការបោះផ្សាយលក់មូលបត្ររដ្ឋ និងគោលនយោបាយនានា ដោយរៀបចំឡើងក្រោមទម្រង់ជាកិច្ចពិគ្រោះយោបល់ និងតាមរយៈកម្មវិធីផ្លូវការនានា (ដូចជា សន្និសីទជាតិស្តីពីទីផ្សារមូលបត្រកម្ពុជា) ដែលសកម្មភាពទាំងនេះ ជាមូលដ្ឋានក្នុងការកសាង និងពង្រឹងទំនាក់ទំនងវិនិយោគិន និងអ្នកចូលរួមទីផ្សារ។

### ង. ប្រព័ន្ធគាំទ្រទីផ្សារ

បច្ចុប្បន្ន, ប្រព័ន្ធគាំទ្រទីផ្សារសម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ មានដូចខាងក្រោម៖

– **«ផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា** (National Bank of Cambodia Platform - NBCP)**»** ដែលត្រូវបានដាក់ឱ្យដំណើរការ ក្នុងគោលបំណងជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ និងផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ (អ្នកទទួលសេវា) ធ្វើប្រតិបត្តិការជួញដូរអនឡាញ ជាមួយអ្នកទទួលសេវាដទៃទៀត ឬជាមួយធនាគារជាតិនៃកម្ពុជា។ ប្រព័ន្ធនេះ មានសមាជិកជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សរុបចំនួន ៦៩ ក្នុងនោះ៖ ធនាគារពាណិជ្ជ ៥០, ធនាគារឯកទេស ៤, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ១០, និងអាជីវកម្មប្តូរប្រាក់ចំនួន ៥។ បច្ចុប្បន្ន, NBCP មានមុខងារគាំទ្រដល់ការដេញថ្លៃមូលបត្ររដ្ឋ, ការចុះបញ្ជីមូលបត្ររដ្ឋ (Registration), ការជួញដូរមូលបត្ររដ្ឋរវាងសមាជិកក្នុងផ្លែតហ្វម, ការរក្សាទុកមូលបត្ររដ្ឋ, ការទូទាត់សាច់ប្រាក់, ចែករំលែកព័ត៌មានជូនវិនិយោគិន។

– **«ប្រព័ន្ធបាគង»** ដែលជាហេដ្ឋារចនាសម្ព័ន្ធទូទាត់ប្រាក់ជំនាន់ថ្មីដ៏ទំនើបមួយ ត្រូវបានអភិវឌ្ឍ និងដាក់ឱ្យដំណើរការដោយ ធ.ជ.ក. ដើម្បីសម្រួលដល់ប្រតិបត្តិការឆ្លងគ្រឹះស្ថាន, បង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់, លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, និងសម្រួលប្រតិបត្តិការទូទាត់ជាប្រាក់រៀល។ បច្ចុប្បន្ន, ប្រព័ន្ធនេះបានសម្រួលដល់ការទូទាត់របស់អាជីវករខ្នាតតូចនិងមធ្យម និងទទួលបានការគាំទ្រកាន់តែច្រើនពីអ្នកប្រើប្រាស់ ជាពិសេស ពីសំណាក់យុវវ័យ ដែលនិយមធ្វើការទូទាត់ និងផ្ទេរប្រាក់តាមរយៈទូរស័ព្ទចល័ត ហើយនាពេលខាងមុខ ប្រព័ន្ធនេះ អាចនឹងត្រូវបានប្រើប្រាស់សម្រាប់ការទូទាត់ឌីជីថលកាន់តែមានភាពទូលំទូលាយ តាមរយៈការចូលរួមពីគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាសមាជិក ដែលការណ៍នេះអាចជំរុញឱ្យសម្រេចបាននូវអន្តរប្រតិបត្តិការពេញលេញសម្រាប់ប្រព័ន្ធទូទាត់នៅប្រទេសកម្ពុជា។

ប្រព័ន្ធនេះ អាចបំពេញមុខងារចម្បងៗ ដូចជា៖ (១) ជាមជ្ឈមណ្ឌលទូទាត់សម្រាប់សម្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថាន ប្រកបដោយភាពងាយស្រួល រហ័ស សុវត្ថិភាព និងមានកម្រៃប្រតិបត្តិការទាប តាមរយៈ KHQR Code ដែលមានលក្ខណៈស្តង់ដា, (២) ជាប្រព័ន្ធសម្រាប់ការផ្ទេរប្រាក់និងទូទាត់ឆ្លងដែន ដែលនឹងជំរុញការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងក្នុងពិភពលោក, (៣) ជាប្រព័ន្ធទូទាត់តម្លៃធំ តាមរយៈការប្រើប្រាស់បច្ចេក-វិទ្យា Distributed Ledger Technology (DLT) ដើម្បី រួមចំណែកលើកកម្ពស់ប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការទូទាត់តម្លៃធំឱ្យកាន់តែប្រសើរឡើងស្របតាមការអភិវឌ្ឍប្រព័ន្ធទូទាត់របស់ប្រទេសក្នុងតំបន់ និងសកល, និង (៤)

ជាផ្លែតហ្វមធនាគារបើកចំហសម្រាប់មុខងារផ្ទៀងផ្ទាត់គណនីអ្នកទទួលផល (Recipient Account Inquiry) និងមុខងារ ភ្ជាប់ទៅគណនីធនាគារតាមរយៈកម្មវិធីប្រព័ន្ធបាគង ដែលមុខងារនេះ នឹងកាត់បន្ថយនូវហានិភ័យ ក្នុងការផ្ទេរប្រាក់ខុសគណនី ដែលនឹងបង្កើនភាពងាយស្រួល និងជំនឿទុកចិត្តមកលើប្រព័ន្ធ។

ផ្អែកតាមលក្ខណៈ, មុខងារ, និងការនិយមប្រើប្រាស់នាពេលបច្ចុប្បន្ន ប្រព័ន្ធបាគងត្រូវបានចាត់ទុកជាប្រព័ន្ធសក្តានុពលមួយ ដែលអាចគាំទ្រដល់ការបោះផ្សាយលក់មូលបត្ររដ្ឋទៅវិនិយោគិនបុគ្គល នាពេលខាងមុខ។ ទន្ទឹមនេះ, ធ.ជ.ក. ក៏បានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាច្រើនប្រភេទ រួមមាន៖ ប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System), ប្រព័ន្ធសេវាទូទាត់រហ័ស (Fast Payment System), ប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch System), ប្រព័ន្ធធនាគារអនឡាញ (Online Banking System), និងប្រព័ន្ធរីធែលផេ (Retail Pay System) ដើម្បីសម្រួលការទូទាត់អន្តរធនាគារប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

# ជំពូកទី៤
# បញ្ហាប្រឈម និងកាលានុវត្តភាព

## ៤.១.បញ្ហាប្រឈម

តាមរយៈការសាកល្បងបោះផ្សាយលក់មូលបត្ររដ្ឋនៅលើទីផ្សារមួយរយៈកន្លងមក, រាជរដ្ឋាភិបាលពិនិត្យឃើញថា ដំណើរការនៃការអភិវឌ្ឍមូលបត្ររដ្ឋនៅកម្ពុជា បាននិងកំពុងប្រឈមនូវបញ្ហាមួយចំនួន ដូចខាងក្រោម៖

### ៤.១.១. ប្រព័ន្ធគាំទ្រទីផ្សារសម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ

រាជរដ្ឋាភិបាលបានអភិវឌ្ឍប្រព័ន្ធគាំទ្រទីផ្សារ សម្រាប់ការបោះផ្សាយលក់មូលបត្ររដ្ឋនាពេលកន្លងមក ក៏ប៉ុន្តែ ប្រព័ន្ធទាំងនេះនៅមានកម្រិតនៅឡើយ ដោយអាចគាំទ្របានតែការចូលរួមរបស់វិនិយោគិនជាគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើប៉ុណ្ណោះ ទាំងការដេញថ្លៃ និងជួញដូរ ពោលគឺ ពុំទាន់អាចអនុញ្ញាតឱ្យមានការចូលរួមផ្ទាល់ពីក្រុមហ៊ុនធានារ៉ាប់រង, បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.), ក្រុមហ៊ុនមូលបត្រ, និងវិនិយោគិនផ្សេងទៀតនៅឡើយទេ ហើយការជួញដូរក៏អាចអនុវត្តបានតែត្រឹមកម្រិតអន្តរធនាគារដែរ (Interbank) ដែលកត្តានេះធ្វើឱ្យរាំងស្ទះដល់ការពង្រីកមូលដ្ឋានវិនិយោគិន ព្រមទាំងការអភិវឌ្ឍទីផ្សារបន្ទាប់ផងដែរ។

### ៤.១.២. ស្ថានភាពទីផ្សារ

ឥទ្ធិពលនៃសភាពការណ៍មិនប្រាកដប្រជា និងវិបត្តិភូមិសាស្ត្រនយោបាយនៅកម្រិតសកល ក៏ដូចជាការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ បានធ្វើឱ្យនិន្នាការនៃអតិផរណានៅបណ្តាប្រទេសមួយចំនួន កើនឡើងដល់កម្រិតខ្ពស់បំផុត។ ដើម្បីទប់ទល់នឹងវិបត្តិអតិផរណា, ធនាគារកណ្តាលអាម៉េរិកបានដាក់ចេញនូវគោលនយោបាយដំឡើងអត្រាការប្រាក់គោល (Benchmark interest rate) ដែលបណ្តាលឱ្យអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិននៃមូលបត្ររដ្ឋសហរដ្ឋអាម៉េរិក គ្រប់ប្រភេទឥណប្រតិទាន មានការកើនឡើង។ ការណ៍នេះបានធ្វើឱ្យរង្គោះរង្គើដល់ទីផ្សារមូលធនសកល ដោយទាញឱ្យអត្រាការប្រាក់គោលអន្តរជាតិ (International Benchmark Rate) ក៏មានការកើនឡើងផងដែរ ហើយបានជះឥទ្ធិពលដល់ស្ថានភាពទីផ្សារក្នុងប្រទេស ជាក់ស្តែង, អត្រាការប្រាក់នៃឧបករណ៍ហិរញ្ញវត្ថុគន្លឹះៗ ដូចជា៖ មូលបត្រអាចជួញដូរបាន (Negotiatable Certificate of Deposits – NCD) និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (Liquidity-Providing Collateralized Operation – LPCO) របស់ធនាគារជាតិនៃកម្ពុជា (ធ.ជ.ក.) និងប្រាក់បញ្ញើមានកាលកំណត់ (Fixed deposit) បានកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងឆ្នាំ២០២២ កន្លងមកនេះ។ បើធៀបនឹងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗនៅលើទីផ្សារទាំងក្នុងប្រទេស និងក្រៅប្រទេស ឃើញថា កម្រិតអត្រាគូប៉ុងនៃមូលបត្ររដ្ឋរបស់កម្ពុជា នៅមិនទាន់មានភាពប្រកួតប្រជែងនៅឡើយ ដែលពិបាកនឹងទទួលបានភាពទាក់ទាញខ្លាំងពីវិនិយោគិន ជាពិសេស ប្រភេទមូលបត្ររដ្ឋដែលមានឥណប្រតិទានលើសពី ១ឆ្នាំ។

### ៤.១.៣. អតិរេកនៃប្រាក់រៀលសម្រាប់វិនិយោគលើមូលបត្ររដ្ឋ

បើទោះជាប្រាក់រៀលមានសន្ទនីយភាពខ្ពស់នៅក្នុងទីផ្សារក៏ដោយ ក៏ប៉ុន្តែ អតិរេកសម្រាប់យកមកវិនិយោគលើមូលបត្ររដ្ឋ មានភាពស្ដួចស្ដើងនៅឡើយ ដោយហេតុថា ប្រភពទុនចម្បងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងក្រុមហ៊ុនធានារ៉ាប់រង គឺជារូបិយប័ណ្ណដុល្លារអាមេរិក ដែលអាចប្រឈមនឹងហានិភ័យអត្រាប្ដូរប្រាក់ នៅពេលដែលតម្លៃនៃរូបិយវត្ថុ ឬរូបិយប័ណ្ណប្រែប្រួល។ កត្តានេះ ធ្វើឱ្យវិនិយោគិនសក្តានុពលទាំងនេះ មានភាពរារែកក្នុងការវិនិយោគលើមូលបត្ររដ្ឋជាប្រាក់រៀល។

### ៤.១.៤. ភាពមិនទាន់ពេញលេញនៃទីផ្សារបន្ទាប់

ថ្វីត្បិតតែមូលបត្ររដ្ឋដែលរាជរដ្ឋាភិបាលបានបោះផ្សាយលក់កន្លងមក អាចត្រូវបានជួញដូរក្នុងចំណោមសមាជិក នៃផ្លែតហ្វមធនាគារជាតិនៃកម្ពុជា ជាលក្ខណៈអន្តរធនាគារក្តី ក៏ប៉ុន្តែ រហូតមកទល់បច្ចុប្បន្ន ពុំទាន់មានប្រតិបត្តិការជួញដូរណាមួយកើតឡើងនៅឡើយទេ។ ទន្ទឹមនេះ, ភាពមិនទាន់ពេញលេញនៃទីផ្សារបន្ទាប់ ក៏ជាបញ្ហាប្រឈមមួយផងដែរ ដែលធ្វើឱ្យការជួញដូរមូលបត្ររដ្ឋពុំទាន់មានភាពទូលំទូលាយ។ កត្តាទាំងនេះ អាចជះឥទ្ធិពលដល់ការសម្រេចចិត្តរបស់វិនិយោគិនក្នុងការចូលរួមវិនិយោគលើមូលបត្ររដ្ឋ ជាពិសេស ធ្វើឱ្យវិនិយោគិនភាគច្រើនមានការរារែកក្នុងការវិនិយោគលើមូលបត្ររដ្ឋដែលមានឥណប្រតិទានលើសពី ១ឆ្នាំ។

### ៤.១.៥. យន្តការសម្របសម្រួល

ក្នុងដំណាក់កាលដំបូងនៃការកសាងក្របខ័ណ្ឌគោលនយោបាយ និងបោះផ្សាយលក់សាកល្បងមូលបត្ររដ្ឋនៅលើទីផ្សារ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ក.ស.ហ.វ.) មានយន្តការសម្របសម្រួលរួចហើយ ទាំងក្នុងរង្វង់អគ្គនាយកដ្ឋាន, និយ័តករ និងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទ ក.ស.ហ.វ. / អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងទាំងជាមួយ ធ.ជ.ក. ដែលជាអាណត្តិគាហកលើការងារបោះផ្សាយលក់មូលបត្ររដ្ឋ។ ទោះជាយ៉ាងនេះក្តី, អាស្រ័យដោយមានការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងនៃ ក.ស.ហ.វ. និង ធ.ជ.ក. ព្រមទាំងដើម្បីឆ្លើយតបបានទៅនឹងតម្រូវការការងារក្នុងដំណាក់កាលបន្តបន្ទាប់នៃការអភិវឌ្ឍមូលបត្ររដ្ឋ ចាំបាច់ត្រូវមានការពិនិត្យ និងធ្វើបច្ចុប្បន្នភាពយន្តការសម្របសម្រួលនេះឡើងវិញ ទាំងលើសមាសភាព និងទាំងលើតួនាទីភារកិច្ច។

### ៤.១.៦. ចំណាត់ថ្នាក់ឥណទានរបស់ប្រទេសនៅមានកម្រិតទាប

គិតមកទល់បច្ចុប្បន្ន, ប្រទេសកម្ពុជា ពុំទាន់រៀបចំឱ្យមានយន្តការវាយតម្លៃចំណាត់ថ្នាក់ឥណទានផ្លូវការ (Solicited Sovereign Credit Rating) នៅឡើយទេ។ ផ្អែកតាមលទ្ធផលនៃការវាយតម្លៃក្រៅផ្លូវការ (Unsolicited Sovereign Credit Rating), ចំណាត់ថ្នាក់ឥណទានរបស់កម្ពុជា នៅមានកម្រិតទាប ពោលគឺ ក្រោមកម្រិតវិនិយោគ (Investment Grade)។ ការណ៍នេះ ទាមទារឱ្យមានការដាក់ចេញនូវវិធានការជាក់លាក់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណាត់ថ្នាក់ឥណទានរបស់ប្រទេសដល់កម្រិតសមស្របណាមួយ សំដៅកាត់បន្ថយថ្លៃដើម និងហានិភ័យនៃការបោះផ្សាយ, បង្កើនទំនុកចិត្ត និងទាក់ទាញការចូលរួមរបស់វិនិយោគិន។

### ៤.១.៧. សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ក្នុងកិច្ចការមូលបត្ររដ្ឋ

កន្លងមក, រាជរដ្ឋាភិបាលបានកសាងនូវយន្តការស្ថាប័ន និងធនធានមនុស្សមួយចំនួន សម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ។ ទោះជាយ៉ាងនេះក្តី, ចំពោះមុខ និងក្នុងដំណាក់កាលបន្តបន្ទាប់ទៀត កិច្ចការនេះនឹងកាន់តែរីកធំ និងស្មុគស្មាញ ដែលនាំឱ្យសមត្ថភាពបច្ចុប្បន្ន ទាំងបរិមាណ ទាំងកម្រិតជំនាញ ពុំអាចឆ្លើយតបបានទៅនឹងតម្រូវការការងារ។ ទន្ទឹមនេះ, ចំណេះដឹង និងបទពិសោធន៍របស់បុគ្គលិកនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលជាវិនិយោគិនសក្តានុពលមួយចំនួន ក៏នៅមានកម្រិតផងដែរ ដោយសារជាកិច្ចការបច្ចេកទេសថ្មី។

## ៤.២. កាលានុវត្តភាព

បើទោះជាដំណើរចាប់ផ្តើមនៃការអភិវឌ្ឍមូលបត្ររដ្ឋនៅកម្ពុជា ប្រឈមនូវបញ្ហាដូចបានរៀបរាប់ខាងលើក្តី ក៏ប៉ុន្តែ រាជរដ្ឋាភិបាលសម្លឹងឃើញកាលានុវត្តភាពជាច្រើន ដែលជាមូលដ្ឋានគ្រឹះក្នុងការជួយជំរុញដល់ការអភិវឌ្ឍមូលបត្ររដ្ឋ ដូចខាងក្រោម៖

### ៤.២.១. ឆន្ទៈរបស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលមានឆន្ទៈមោះមុតក្នុងការអភិវឌ្ឍមូលបត្ររដ្ឋ ដែលស្តែងឱ្យឃើញតាមរយៈការអនុម័ត និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការដាក់ចេញ និងអនុវត្តយ៉ាងសកម្មនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងគោលនយោបាយជាបន្តបន្ទាប់ ដូចជា៖ យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ, យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ, យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥, ក្របខ័ណ្ឌគោលនយោបាយបឋមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ, យុទ្ធសាស្ត្រ និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ដែលគាំទ្រ និងជំរុញដល់ការកសាងប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយ សម្រាប់ការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស។ ទន្ទឹមនេះដែរ, រាជរដ្ឋាភិបាល ក៏មានឆន្ទៈខ្ពស់ក្នុងការជំរុញការអភិវឌ្ឍបៃតង និងការសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ដែលជាកាលានុវត្តភាពដល់ការបោះផ្សាយសញ្ញាបណ្ណរដ្ឋតាមវិស័យ។

### ៤.២.២. កម្មវិធីកែទម្រង់គន្លឹះៗរបស់រាជរដ្ឋាភិបាល

កម្ពុជាមានវឌ្ឍនភាពល្អប្រសើរក្នុងការកែទម្រង់ស្ថាប័ន, ការលើកកម្ពស់អភិបាលកិច្ចល្អ និងការជំរុញការផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរ តាមរយៈកម្មវិធីកែទម្រង់គន្លឹះៗនានា មានជាអាទិ៍៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, និង ៣) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ។ សមិទ្ធផលជាទីមោទនៈនៃកម្មវិធីកែទម្រង់ទាំងនេះ គឺជាកត្តារួមចំណែកដ៏សំខាន់ក្នុងការបង្កើតបរិយាកាសអំណោយផលសម្រាប់ជំរុញការអភិវឌ្ឍមូលបត្ររដ្ឋនៅកម្ពុជា និងបង្កើនទំនុកចិត្តចំពោះវិនិយោគិន។

### ៤.២.៣. ភាពរីកចម្រើននៃវិស័យធនាគារ និងហិរញ្ញវត្ថុ

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, វិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដែលស្តែងឱ្យឃើញតាមរយៈការកើនឡើងនៃចំនួនធនាគារពាណិជ្ជ, ធនាគារឯកទេស, គ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ, ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ, ក្រុមហ៊ុនធានារ៉ាប់រងថ្មីៗជាច្រើន។ ភាពរីកចម្រើននេះ បាននិងកំពុងជំរុញដល់ការគ្រប់គ្រងសន្ទនីយភាពក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ឱ្យកាន់តែប្រយ័ត្នប្រយែងជាងមុន ព្រមទាំងបង្កើតបរិយាកាសអនុគ្រោះដល់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងប្រទេស ខណៈដែលវិស័យនេះត្រូវបានចាត់ទុកជាវិនិយោគិនសក្តានុពលដ៏សំខាន់ក្នុងការចូលរួមវិនិយោគលើមូលបត្ររដ្ឋ។ ទន្ទឹមនេះ, មូលនិធិសំខាន់ៗផ្សេងទៀត ជាពិសេស ប.ស.ស. ក៏មានអតិរេកមូលនិធិសម្រាប់យកទៅធ្វើការវិនិយោគមូលបត្ររដ្ឋ ផងដែរ។

### ៤.២.៤. ភាពរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល

ការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល នឹងជួយគាំទ្រដល់ការធ្វើឌីជីថលូបនីយកម្ម ឬការធ្វើទំនើបកម្មប្រព័ន្ធគាំទ្រសម្រាប់ការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ ដែលអាចធានាបាននូវប្រសិទ្ធភាព, សុវត្ថិភាព និងភាពជឿទុកចិត្ត។ ទន្ទឹមនេះ, ភាពរីកចម្រើននៃបច្ចេកវិទ្យាឌីជីថលនឹងរួមចំណែកសម្រេចបាននូវកំណើនសេដ្ឋកិច្ចដែលនឹងជួយជំរុញដល់ការអភិវឌ្ឍទីផ្សារបន្ទាប់ផងដែរ។

### ៤.២.៥. លទ្ធភាពពិពិធកម្មប្រភពហិរញ្ញប្បទាន

រាជរដ្ឋាភិបាលយល់ឃើញថា ភាពរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា និងការរក្សាបាននូវស្ថានភាពបំណុលសាធារណៈ មាន «**ចីរភាព**» និង «**ហានិភ័យកម្រិតទាប**» មិនត្រឹមតែផ្តល់លទ្ធភាពដល់រាជរដ្ឋាភិបាលក្នុងការបង្កើនសមត្ថភាពខ្ចីបានខ្ពស់ជាងមុនប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជាកាលានុវត្តភាពដ៏ប្រសើរក្នុងការធ្វើពិពិធកម្មប្រភព

ហិរញ្ញប្បទានពីប្រភពផ្សេងទៀតឱ្យកាន់តែទូលំទូលាយ ជាពិសេស ការកៀរគរហិរញ្ញប្បទានពីទីផ្សារមូលបត្រក្នុងប្រទេស និងក្រៅប្រទេស តាមរយៈការបោះផ្សាយលក់មូលបត្ររដ្ឋ ដើម្បីយកមកបំពេញតម្រូវការវិនិយោគសាធារណៈប្រកបដោយភាពជាម្ចាស់ និងឯករាជ្យជាងមុន។

### ៤.២.៦. ការគាំទ្រពីដៃគូអភិវឌ្ឍ

តាមរយៈកិច្ចសហប្រតិបត្តិការកន្លងមក ឃើញថា រាជរដ្ឋាភិបាលទទួលបាននូវសន្ទុះនៃការគាំទ្រពីដៃគូអភិវឌ្ឍយ៉ាងខ្លាំង ដែលជួយគាំទ្រជាអាទិភាពលើការអភិវឌ្ឍមូលបត្ររដ្ឋនៅកម្ពុជា។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានទទួលជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍនានាជាច្រើន រួមមាន៖ ធនាគារពិភពលោក (World Bank), មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយរួមទាំងលេខាធិការដ្ឋានអាស៊ាន (ASEAN Secretariat), កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP), មូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ (UNCDF), កម្មវិធីភាពជាដៃគូកម្ពុជា - អូស្ត្រាលី សម្រាប់ការអភិវឌ្ឍ ប្រកបដោយភាពធន់ (CAPRED), វិទ្យាស្ថានកំណើនបៃតងសកល (GGGI), គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (UNESCAP), និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ជាដើម ហើយនៅថ្ងៃខាងមុខ ដៃគូអភិវឌ្ឍទាំងនេះក៏នៅតែបង្ហាញឆន្ទៈ ក្នុងការជួយគាំទ្រដល់កម្ពុជាក្នុងការអភិវឌ្ឍមូលបត្ររដ្ឋឱ្យបានពេញលេញ ផងដែរ។ ជំនួយបច្ចេកទេសភាគច្រើនទាំងនេះ ផ្តោតសំខាន់លើ៖ ការកសាងសមត្ថភាពលើការរៀបចំក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធផ្សេងៗ, ការងារវិភាគ, ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, ការងារបច្ចេកទេសពាក់ព័ន្ធនឹងការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ។ល។

# ជំពូកទី៥
# វិធានការគោលនយោបាយ

ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការគោលនយោបាយជា ២ ដំណាក់កាល រួមមាន៖

- **ដំណាក់កាលទី១** (ឆ្នាំ២០២៣ - ២០២៦) បង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយពេញលេញសម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស; និង
- **ដំណាក់កាលទី២** (ឆ្នាំ២០២៧ - ២០២៨) ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធគ្រប់គ្រងសម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស ព្រមទាំងចាប់ផ្តើមសិក្សា និងត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុនក្នុងការឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេសក្នុងកាលៈទេសៈចាំបាច់។

វិធានការលម្អិតក្នុងដំណាក់កាលនីមួយៗ មានដូចខាងក្រោម៖

## ៥.១. វិធានការគោលនយោបាយដំណាក់កាលទី១ (ឆ្នាំ២០២៣ - ២០២៦)

### ៥.១.១. បន្តពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ជាអាទិ៍៖

- ការធ្វើអាជីវកម្មមូលបត្ររដ្ឋ និងការអនុញ្ញាតលើអាជីវកម្មមូលបត្ររដ្ឋដល់អន្តរការី (Eligible Intermediary), និងពាណិជ្ជករ (Dealers)/ភ្នាក់ងារធានាទិញមូលបត្រ (Underwriters)
- នីតិវិធី និងដំណើរការនៃការស្នើទិញ (Subscription), ការជួញដូរ និងការទូទាត់មូលបត្ររដ្ឋ ព្រមទាំងការកាត់ទុកពន្ធ
- ការធ្វើបច្ចុប្បន្នកម្មការលើកទឹកចិត្តពន្ធដារ សម្រាប់ការវិនិយោគលើមូលបត្ររដ្ឋ
- នីតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងមូលបត្ររដ្ឋ ដោយរំលេចនូវកិច្ចដំណើរការនៃការងារ, នីតិវិធី និងលំហូរការងារ, និងអ្នកទទួលបន្ទុក
- គោលការណ៍ក្នុងការកំណត់ទំហំ និងរូបិយប័ណ្ណនៃការបោះផ្សាយ ដោយក្នុងនោះ៖
    - ការកំណត់ទំហំនៃការបោះផ្សាយលក់មូលបត្ររដ្ឋ ត្រូវអនុលោមតាមគោលការណ៍នៃការគ្រប់គ្រងបំណុលសាធារណៈ ពោលគឺ ត្រូវស្ថិតក្នុងកម្រិតសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន ជាពិសេស ធានាបាននូវចីរភាពបំណុលសាធារណៈ។ ទន្ទឹមនេះ, ក.ស.ហ.វ. ត្រូវបន្តរៀបចំផែនការបោះផ្សាយលក់មូលបត្ររដ្ឋប្រចាំឆ្នាំ ដោយរួមបញ្ចូលនូវព័ត៌មាន ដូចជា៖ ទំហំ, រូបិយប័ណ្ណ, ប្រភេទមូលបត្រ, វិធីសាស្ត្របោះផ្សាយ, កាលវិភាគបោះផ្សាយ, និងព័ត៌មានសំខាន់ៗផ្សេងទៀតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្ររដ្ឋ។
    - ការបោះផ្សាយលក់មូលបត្ររដ្ឋ ត្រូវធ្វើឡើងជារូបិយវត្ថុជាតិ (ប្រាក់រៀល)។ ទោះជាយ៉ាងនេះក្តី, រូបិយប័ណ្ណនៃការបោះផ្សាយ អាចនឹងត្រូវបានពិនិត្យ និងកំណត់ឡើងវិញ អាស្រ័យលើតម្រូវការហិរញ្ញប្បទានជាក់ស្តែងរបស់រាជរដ្ឋាភិបាល, វិវឌ្ឍនាការម៉ាក្រូសេដ្ឋកិច្ចជាក់ស្តែងរបស់កម្ពុជា, និងតម្រូវការជាក់ស្តែងនៃទីផ្សារ។
- យន្តការស្ថាប័ន និងយន្តការសម្របសម្រួល ក្នុងការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ ដើម្បីធានាបាននូវភាពប្រទាក់ក្រឡាក្នុងការអភិវឌ្ឍមូលបត្ររដ្ឋ ព្រមទាំងភាពរលូនក្នុងការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ។
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ តាមតម្រូវការជាក់ស្តែង។

**៥.១.២. រៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទុនពីការបោះផ្សាយលក់មូលបត្ររដ្ឋ** ដោយរួមបញ្ចូលទាំងយន្តការនៃការសិក្សា និងជ្រើសរើសគម្រោងសម្រាប់អនុវត្តដោយប្រើប្រាស់ចំណូលពីការបោះផ្សាយលក់មូលបត្ររដ្ឋ ស្របតាម «យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ - ២០២៥» សំដៅជានានូវប្រសិទ្ធភាពនៃការវិនិយោគ និងចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ និងថវិកាជាតិ។ ជាគោលការណ៍, ការប្រើប្រាស់ទុនពីការបោះផ្សាយលក់មូលបត្ររដ្ឋ ត្រូវអនុលោមតាមមាត្រា ៤ នៃច្បាប់ស្តីពីមូលបត្ររដ្ឋ និងគោលការណ៍គ្រឹះនៃការគ្រប់គ្រងបំណុលសាធារណៈ។ ចំណូលមូលធនបានពីការបោះផ្សាយមូលបត្ររដ្ឋត្រូវប្រើប្រាស់សម្រាប់ហិរញ្ញប្បទានតែលើចំណាយមូលធននៃគម្រោងវិនិយោគសាធារណៈ ឆ្លើយតបតាមតម្រូវការបន្ទាន់របស់រាជរដ្ឋាភិបាល ហើយត្រូវតែជាគម្រោង/កម្មវិធីដែលមានលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម៖

- គាំទ្រដោយផ្ទាល់ដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ ក្នុងវិស័យអាទិភាពរបស់រាជរដ្ឋាភិបាល ដូចមានកំណត់ក្នុងឯកសារក្របខណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងតាមវិស័យ
- វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈក្នុងវិស័យអាទិភាព ឬវិនិយោគក្នុងវិស័យសេដ្ឋកិច្ច ដែលមានផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់
- មានអត្រាផលចំណេញសេដ្ឋកិច្ចខ្ពស់ (Economic Rate of Return) ដែលយ៉ាងហោចក្នុងកម្រិត i) ខ្ពស់ជាងអត្រាការប្រាក់នៃការខ្ចី (សម្រាប់រាល់គម្រោង/កម្មវិធី) និង ii) ខ្ពស់ជាងកម្រិតអត្រាអប្បបរមា ២០% (លើកលែងតែគម្រោង/កម្មវិធីផ្តល់ឥណទានផ្ទាល់ដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ)
- មានរយៈពេលអនុវត្តខ្លី និងផ្តល់ផលសង្គម-សេដ្ឋកិច្ចលឿន ដែលចរិតលក្ខណៈនៃគម្រោងបែបនេះទាមទារឱ្យមាននីតិវិធីប្រតិបត្តិការដោយឡែក ដែលមានស្តង់ដា និងប្រសិទ្ធផលខ្ពស់
- មានរចនាសម្ព័ន្ធស្ថាប័នច្បាស់លាស់ និងមានភាពរួចរាល់ក្នុងការចាប់ផ្តើមអនុវត្ត។

**៥.១.៣. បន្តអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ** ដោយផ្តោតលើកិច្ចការសំខាន់ៗ បន្ថែមពីលើការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដូចខាងក្រោម៖

**ក. អភិវឌ្ឍទីផ្សារដំបូង** ដោយត្រូវបន្តរៀបចំយន្តការបោះផ្សាយក្នុងទីផ្សារដំបូង តាមរយៈផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា (NBCP) សំដៅបង្កើនឱ្យមានការចូលរួមពេញលេញ និងទូលំទូលាយពីរាល់វិនិយោគិនសក្តានុពល។

**ខ. អភិវឌ្ឍទីផ្សារបន្ទាប់** ដោយត្រូវរៀបចំយន្តការជួញដូរមូលបត្ររដ្ឋ តាមរយៈ NBCP សំដៅបង្កើតឱ្យបាននូវទីផ្សារបន្ទាប់មួយដែលមានលក្ខណៈពេញលេញ, សន្ទនីយភាពខ្ពស់, ថ្លៃប្រតិបត្តិការនិងហានិភ័យទាប។

**គ. ពង្រឹងទំនាក់ទំនងវិនិយោគិន** ដោយ ក.ស.ហ.វ. សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវ៖

- បន្តរៀបចំកិច្ចពិគ្រោះយោបល់ដើម្បីស្ទាបស្ទង់ទីផ្សារ (Market Sounding) ជាមួយវិនិយោគិនជាប្រចាំ ដែលជាមូលដ្ឋានក្នុងការរៀបចំផែនការបោះផ្សាយលក់មូលបត្ររដ្ឋ
- បន្តផ្សព្វផ្សាយជាទៀងទាត់នូវផែនការបោះផ្សាយលក់មូលបត្ររដ្ឋ
- រៀបចំកម្មវិធីផ្សព្វផ្សាយលក់មូលបត្ររដ្ឋ (Roadshow)
- រៀបចំសិក្ខាសាលាដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល, គោលការណ៍ណែនាំ, ឬព័ត៌មានចាំបាច់នានា តាមតម្រូវការជាក់ស្តែង
- សិក្សាបង្កើតខ្សែកោងអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន (Yield Curve)។

ឃ. រៀបចំប្រព័ន្ធគាំទ្រទីផ្សារ ដោយអភិវឌ្ឍបន្ថែមនូវមុខងារនៃប្រព័ន្ធ NBCP ដែលមានស្រាប់ សំដៅគាំទ្រដល់ដំណើរការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ, ការទូទាត់, ការរក្សាទុកមូលបត្ររដ្ឋ, ការកត់ត្រា និងផលិតរបាយការណ៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

៥.១.៤. រៀបចំយន្តការសម្របសម្រួលដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណាត់ថ្នាក់ឥណទានរបស់ប្រទេស ដល់កម្រិតវិនិយោគ (Investment Grade) សំដៅកាត់បន្ថយថ្លៃដើមនិងហានិភ័យ ព្រមទាំងបង្កើនភាពទាក់ទាញដល់វិនិយោគិន ដោយត្រូវបង្កើតក្រុមការងារមួយ ដែលដឹកនាំដោយ ក.ស.ហ.វ. និងមានសមាសភាពចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបំពេញភារកិច្ចចម្បង ជាអាទិ៍៖ i) សម្របសម្រួលជាមួយតួអង្គពាក់ព័ន្ធក្នុងការវាយតម្លៃចំណាត់ថ្នាក់ឥណទានរបស់ប្រទេស, ii) ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃលទ្ធផលនៃចំណាត់ថ្នាក់ឥណទានរបស់ប្រទេស, និង iii) សិក្សាអំពីចំណុចខ្វះខាតដែលត្រូវកែលម្អ។

៥.១.៥. សិក្សារៀបចំយន្តការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ៖ ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ (Thematic bonds) ទាមទារឱ្យមានការកំណត់នូវគោលការណ៍បន្ថែម។ ក្នុងន័យនេះ, ក.ស.ហ.វ. ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ចាំបាច់ត្រូវធ្វើកិច្ចការអាទិភាពចម្បងៗ ដូចខាងក្រោម៖

- ធ្វើការសិក្សា និងវិភាគលើគោលការណ៍របស់៖ International Capital Market Association (ICMA), ASEAN Capital Markets Forum (ACMF), Climate Bond Initiative (CBI) និងគោលការណ៍ជាអន្តរជាតិផ្សេងទៀត ដើម្បីជាមូលដ្ឋានកំណត់គោលការណ៍នៃការបោះផ្សាយសញ្ញាបណ្ណតាមវិស័យ ស្របតាមបរិការណ៍កម្ពុជា
- រៀបចំគោលការណ៍ណែនាំសម្រាប់ការបោះផ្សាយសញ្ញាបណ្ណរដ្ឋតាមវិស័យ ដោយគ្របដណ្តប់លើគ្រប់ដំណាក់កាល គឺទាំងដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាព (Feasibility Stage), ដំណាក់កាលមុនពេលបោះផ្សាយ (Pre-Issuance Stage), ដំណាក់កាលបោះផ្សាយ (Issuance Stage), និងទាំងដំណាក់កាលក្រោយពេលបោះផ្សាយ (Post-Issuance Stage)។

៥.១.៦. ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ដោយ ក.ស.ហ.វ. ត្រូវយកចិត្តទុកដាក់ក្នុងការអនុវត្តផែនការសកម្មភាពដែលបានដាក់ចេញនៅក្នុង **«ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ»** ដែលជាឧបសម្ព័ន្ធទី៣ នៃក្របខ័ណ្ឌគោលនយោបាយនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។

## ៥.២. វិធានការគោលនយោបាយដំណាក់កាលទី២ (ឆ្នាំ២០២៧ - ២០២៨)

៥.២.១. ពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីរួមប្រតិបត្តិការ តាមការចាំបាច់ ដើម្បីបន្តពង្រឹងប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និងចីរភាពនៃប្រព័ន្ធគ្រប់គ្រងសម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ។

៥.២.២. ពិនិត្យ និងកែលម្អទីផ្សារមូលបត្ររដ្ឋ ឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងបរិការណ៍ជាក់ស្តែង។

៥.២.៣. សិក្សាសមិទ្ធិលទ្ធភាព និងយន្តការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស ដោយ ក.ស.ហ.វ. ត្រូវ៖

- សិក្សា និងពិនិត្យលើបែបបទ, នីតិវិធី, និងការបំពេញបុរេលក្ខខណ្ឌក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស ដោយរួមទាំងការវាយតម្លៃចំណាត់ថ្នាក់ឥណទានរបស់ប្រទេស (Sovereign Credit Rating), និង

- សិក្សាសមិទ្ធិលទ្ធភាព ដោយរួមបញ្ចូលទាំងការវិភាគទីផ្សារអន្តរជាតិចំពោះមូលបត្ររដ្ឋរបស់កម្ពុជា, ការវិភាគថ្លៃ និងហានិភ័យ, ការសិក្សាជ្រើសរើសភ្នាក់ងារគាំទ្រចាំបាច់មួយចំនួន។

**៥.២.៤. ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស** សម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ។

ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តវិធានការគោលនយោបាយខាងលើ ក.ស.ហ.វ. ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកជាស្ថាប័នដឹកមុខ លើការសម្របសម្រួលអនុវត្តផែនការសកម្មភាព ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃក្របខ័ណ្ឌគោលនយោបាយនេះ។ ទន្ទឹមនេះ, អភិក្រមនៃការអនុវត្ត ត្រូវធ្វើឡើងដោយប្រយ័ត្នប្រយែង, សន្សឹមៗ, ឈរលើគោលការណ៍ប្រាកដនិយម, ទន់ភ្លន់, និង **«រៀនផង-ធ្វើផង»**។

# ជំពូកទី៦
# យន្តការតាមដាន, ត្រួតពិនិត្យ, វាយតម្លៃ, និងដោះស្រាយបញ្ហាប្រឈម

ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្ត «**ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨**», រាជរដ្ឋាភិបាលសម្រេចដាក់ចេញយន្តការតាមដាន, ត្រួតពិនិត្យ, វាយតម្លៃ, និងដោះស្រាយបញ្ហាប្រឈម ដូចខាងក្រោម៖

## ៦.១. យន្តការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃ

ក្រុមការងារបច្ចេកទេសរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ (ក.ម.រ.) ដែលមានលេខាធិការដ្ឋាន ជាសេនាធិការ មានភារកិច្ចតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃក្របខ័ណ្ឌគោលនយោបាយនេះ។ ក្នុងន័យនេះ, អង្គភាពទទួលបន្ទុកអនុវត្តសកម្មភាពនីមួយៗ ត្រូវផ្តល់របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ មកលេខាធិការដ្ឋាន នៃ ក.ម.រ. ដើម្បីបូកសរុប និងរាយការណ៍ជូនរដ្ឋមន្ត្រី ក.ស.ហ.វ.។

### ដ្យាក្រាមទី២៖ យន្តការតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃ




## ៦.២. យន្តការដោះស្រាយបញ្ហាប្រឈម

ក.ម.រ. មានភារកិច្ចសម្របសម្រួលដោះស្រាយបញ្ហាប្រឈម ដែលអាចកើតឡើងជាយថាហេតុ ក្នុងពេលអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃក្របខ័ណ្ឌគោល-នយោបាយនេះ។ ក្នុងករណីចាំបាច់, ត្រូវស្នើវិធានការដោះស្រាយ ដើម្បីសុំគោលការណ៍សម្រេចពីរដ្ឋមន្ត្រី ក.ស.ហ.វ. ឬ គណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ (គ.គ.ប.) ឬ គណៈកម្មការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ក.ហ.) ឬ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស) ឬ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.)។ ក្នុងករណីមានវេទយិតភាពខ្ពស់, ត្រូវស្នើវិធានការដោះស្រាយពីគណៈកម្មាធិការជាតិស្ថិរភាពហិរញ្ញវត្ថុកម្ពុជា (គ.ជ.ស) ឬ សុំគោលការណ៍សម្រេចដ៏ខ្ពង់ខ្ពស់ពីនាយករដ្ឋមន្ត្រី។

### ដ្យាក្រាមទី៣៖ យន្តការដោះស្រាយបញ្ហាប្រឈម



# ជំពូកទី៧
# សេចក្តីសន្និដ្ឋាន

ជារួម, ក្នុងបរិការណ៍ថ្មីនៃការអភិវឌ្ឍរបស់កម្ពុជា និងក្នុងកាលៈទេសៈជាក់ស្តែង រាជរដ្ឋាភិបាលពិនិត្យឃើញថា ការអភិវឌ្ឍមូលបត្ររដ្ឋ ពិតជាមានសារៈសំខាន់ក្នុងការរួមចំណែកជំរុញកំណើនសេដ្ឋកិច្ច ដោយមិនត្រឹមតែផ្តល់ជាយន្តការថ្មី ក្នុងការកៀគរទុនសម្រាប់បំពេញតម្រូវការហិរញ្ញប្បទានប៉ុណ្ណោះទេ តែក៏ជាមូលដ្ឋានសម្រាប់ជំរុញការអភិវឌ្ឍទីផ្សាររូបិយវត្ថុ និងទីផ្សារមូលធន ផងដែរ។

ជាតថភាព, **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ ឆ្ពោះទៅបង្កើតប្រព័ន្ធគ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយមួយ។ ក្នុងទិសដៅនេះ, រាជរដ្ឋាភិបាលបានដាក់ចេញវិធានការគោលនយោបាយ ដោយញែកជា **២** ដំណាក់កាល ដែលក្នុងនោះ៖ ដំណាក់កាលទី១ ពីឆ្នាំ២០២៣ - ២០២៦ បង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងមួយពេញលេញ សម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ នៅក្នុងប្រទេស, និងដំណាក់កាលទី២ ពីឆ្នាំ២០២៧ - ២០២៨ ពិនិត្យឡើងវិញ និងកែលម្អប្រព័ន្ធគ្រប់គ្រង សម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋនៅក្នុងប្រទេស ព្រមទាំងចាប់ផ្តើមសិក្សា និងត្រៀមលក្ខណៈឱ្យបានរួចរាល់ជាមុនក្នុងការឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេសក្នុងកាលៈទេសៈចាំបាច់។

រាជរដ្ឋាភិបាល ចាត់ទុកក្របខ័ណ្ឌគោលនយោបាយនេះជា **«ឯកសាររស់»** ដែលអាចនឹងត្រូវបានកែសម្រួលជាយថាហេតុ ក្នុងករណីចាំបាច់ ដើម្បីធានាសង្គតិភាព និងការឆ្លើយតបទៅនឹងការវិវឌ្ឍនៃបរិការណ៍ចំពោះមុខជាក់ស្តែង ទាំងក្នុង និងក្រៅប្រទេស។ ទន្ទឹមនេះ, រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងមុតមាំថា ការអនុវត្តដោយជោគជ័យនូវ **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** នឹងរួមចំណែក៖ ១) បង្កើនល្បឿននៃការអភិវឌ្ឍទីផ្សារមូលបត្រនៅកម្ពុជា ក៏ដូចជា ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង និង ២) ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ តាមរយៈការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានសម្រាប់ការវិនិយោគសាធារណៈ ដែលទាំងនេះគឺជាមូលដ្ឋានគ្រឹះក្នុងការរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូន ក.ស.ហ.វ. ទទួលបន្ទុកជាស្ថាប័នដឹកមុខ ក្នុងការសម្របសម្រួលលើការអនុវត្ត **«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** ដោយត្រូវមានការចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពីសំណាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល៕

ឧបសម្ព័ន្ធទី១

# សន្ធានុក្រម

# សទ្ទានុក្រម

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
| --- | --- | --- | --- |
| ១ | ASEAN Taxonomy | វគ្គីករសាស្ត្រអាស៊ាន | សំដៅដល់គោលការណ៍ណែនាំរួម សម្រាប់ប្រទេសជាសមាជិកអាស៊ាន ដើម្បីធ្វើអត្តសញ្ញាណកម្ម និងចាត់ថ្នាក់គម្រោង និងសកម្មភាពសេដ្ឋកិច្ច ដែលឆ្លើយតបទៅនឹងគោលដៅនិរន្តរភាព។ |
| ២ | Benchmark bonds | សញ្ញាបណ្ណគោល | សំដៅដល់សញ្ញាបណ្ណដែលមានសកម្មភាពជួញដូរច្រើន និងទំហំធំនៅក្នុងទីផ្សារ ហើយតម្លៃរបស់សញ្ញាបណ្ណនេះ អាចយកមកធ្វើជាមូលដ្ឋាន សម្រាប់ការបោះផ្សាយមូលបត្រផ្សេងៗទៀតដែលមានផលប្រតិទានប្រហាក់ប្រហែលគ្នា។ |
| ៣ | Blue Government Bond | សញ្ញាបណ្ណរដ្ឋខៀវ | សំដៅដល់សញ្ញាបណ្ណរដ្ឋដែលត្រូវបានបោះផ្សាយ ដើម្បីហិរញ្ញប្បទានគម្រោង ដែលពាក់ព័ន្ធនឹងសមុទ្រ ហើយផ្តល់គុណប្រយោជន៍ដល់បរិស្ថាន ដូចជា៖ ការស្តារប្រព័ន្ធអេកូឡូស៊ីសមុទ្រ, ការកាត់បន្ថយការបំពុលដែលបង្កដោយការដឹកជញ្ជូនតាមផ្លូវសមុទ្រ, និងការគ្រប់គ្រងតំបន់ឆ្នេរ ប្រកបដោយចីរភាព។ល។ |
| ៤ | Central Securities Depository (CSD) | ប្រតិបត្តិកររក្សាទុកមូលបត្ររួម | សំដៅដល់ស្ថាប័នស្វ័យនិយ័តករ ដែលមានមុខងារទូទាត់ និងរក្សាទុកមូលបត្រជារួម ទាំងមូលបត្ររដ្ឋ និងទាំងមូលបត្រសាជីវកម្ម បន្ទាប់ពីមូលបត្រត្រូវបានបោះផ្សាយ ឬជួញដូរ។ |
| ៥ | Competitive bids | ការដេញថ្លៃដោយប្រកួតប្រជែង | សំដៅដល់នីតិវិធីនៃការដេញថ្លៃ ដោយតម្រូវឱ្យវិនិយោគិនដាក់ស្នើនូវបរិមាណ និងអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន (Yield) ឬថ្លៃ (Price)។ បន្ទាប់មក Yield ឬ Price នឹងត្រូវតម្រៀបតាមលំដាប់ (ពីទាបទៅខ្ពស់ ករណីដាក់ស្នើជា Yield ឬពីខ្ពស់មកទាប ករណីដាក់ស្នើជា (Price) ដើម្បីជាមូលដ្ឋានកំណត់អ្នកឈ្នះ។ |
| ៦ | Custodian Agent | ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ | សំដៅដល់ភ្នាក់ងារដែលទទួលស្គាល់ដោយអាជ្ញាធរ (និយ័តករក្នុងវិស័យមូលបត្រ) ក្នុងការផ្តល់សេវារក្សាសុវត្ថិភាពនៃការវិនិយោគមូលបត្រ ជូនវិនិយោគិន។ |
| ៧ | Delivery Versus Payment (DVP) | គោលការណ៍ប្រគល់ - ទទួល និងទូទាត់ក្នុងពេលតែមួយ | សំដៅដល់ទំនាក់ទំនងរវាងប្រព័ន្ធផ្ទេរសាច់ប្រាក់ និងប្រព័ន្ធផ្ទេរមូលបត្រ ដើម្បីធានាថា ការប្រគល់-ទទួលមូលបត្រ ត្រូវបានធ្វើឡើងក្នុងពេលដំណាលគ្នានឹងការទូទាត់សាច់ប្រាក់។ |
| ៨ | Dematerialized | ទម្រង់អរូបិយ | សំដៅដល់ទម្រង់ចុះបញ្ជី ឬទម្រង់ជាគណនីមូលបត្រ ដែលមិនមែនជាក្រដាសមួយសន្លឹក ឬវិញ្ញាបនបត្រនោះទេ។ |

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ៩ | Derivative Instruments | ឧបករណ៍និស្សន្ទ | សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុ ដែលថ្លៃរបស់វាផ្សារភ្ជាប់ទៅនឹងថ្លៃនៃឧបករណ៍ហិរញ្ញវត្ថុជាក់លាក់ណាមួយ ដូចជា៖ មូលបត្រកម្មសិទ្ធិ មូលបត្របំណុល រូបិយប័ណ្ណ ទំនិញ (ប្រេងឆៅ ឧស្ម័នធម្មជាតិ ផលិតផលកសិកម្ម ជាដើម) ដែលត្រូវបានជួញដូរក្នុងទីផ្សារ។ |
| ១០ | Green Government Bonds | សញ្ញាបណ្ណរដ្ឋបៃតង | សំដៅដល់សញ្ញាបណ្ណរដ្ឋ ដែលត្រូវបានបោះផ្សាយ ដើម្បីហិរញ្ញប្បទាន គម្រោងដែលផ្ដល់គុណប្រយោជន៍ដល់បរិស្ថាន ដូចជាគម្រោងដែលពាក់ព័ន្ធនឹង៖ ថាមពលកកើតឡើងវិញ, ប្រសិទ្ធភាពថាមពល, ការទប់ស្កាត់ការបំពុល, ការគ្រប់គ្រងនៃធនធានធម្មជាតិ និងការប្រើប្រាស់ដីធ្លីប្រកបដោយនិរន្តរភាព, ការអភិរក្សជីវៈចម្រុះ, ការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ, និងអគារបៃតង។ល។ |
| ១១ | Government Securities | មូលបត្ររដ្ឋ | សំដៅដល់បណ្ណ សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀត ដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល នៅក្រោមច្បាប់ស្ដីពីមូលបត្ររដ្ឋ រួមមាន៖<br>ក- បណ្ណរតនាគារដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ។<br>ខ- សញ្ញាបណ្ណរតនាគារដែលមានឥណប្រតិទាន ចាប់ពីមួយឆ្នាំឡើងទៅ។<br>គ- មូលបត្ររដ្ឋផ្សេងៗទៀត។<br>មូលបត្ររដ្ឋទាំងអស់ខាងលើនេះ មិនរួមបញ្ចូលនូវមូលបត្រដែលបោះផ្សាយដោយសហគ្រាសសាធារណៈ ឬការសុំខ្ចីផ្សេងៗរបស់រាជរដ្ឋាភិបាល ដែលមិនស្ថិតក្រោមវិសាលភាពនៃច្បាប់ស្ដីពីមូលបត្ររដ្ឋទេ។ |
| ១២ | Independent Verifier | អ្នកត្រួតពិនិត្យឯករាជ្យ | សំដៅដល់បុគ្គល ឬក្រុមហ៊ុនឯករាជ្យ ដែលមានតួនាទីវាយតម្លៃ និងបញ្ជាក់អំពីលក្ខណៈសម្បត្តិសមស្របនៃគម្រោង ឬទ្រព្យសកម្មដែលហិរញ្ញប្បទានពីការបោះផ្សាយលក់សញ្ញាបណ្ណ។ |
| ១៣ | Inflation-linked bonds | សញ្ញាបណ្ណផ្សារភ្ជាប់នឹងអតិផរណា | សំដៅដល់សញ្ញាបណ្ណ ដែលផលចំណូលជាតម្លៃចារឹក (Nominal Return) ត្រូវបានប្រែប្រួលទៅតាមអត្រាអតិផរណា។ |
| ១៤ | International bond | មូលបត្ររដ្ឋនៅក្រៅប្រទេស | សំដៅដល់សញ្ញាបណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមរាជរដ្ឋាភិបាល នៅលើទីផ្សារអន្តរជាតិ។ |
| ១៥ | Intermediary | អន្តរការី | សំដៅដល់គ្រឹះស្ថាន/ក្រុមហ៊ុន ដែលត្រូវបានទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា ក្នុងការទិញ និងជួញដូរមូលបត្រជំនួសអតិថិជន។ |

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ១៦ | Legal Advisor | ទីប្រឹក្សាច្បាប់ | សំដៅដល់បុគ្គល ឬក្រុមហ៊ុនដែលផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ ពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងផ្លូវច្បាប់។ |
| ១៧ | Money market | ទីផ្សាររូបិយវត្ថុ | សំដៅដល់ទីផ្សារ សម្រាប់ជួញដូរឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី ដែលមានសន្ទនីយភាពខ្ពស់ អាចដោះដូរជាសាច់ប្រាក់បានយ៉ាងឆាប់រហ័ស ដូចជា៖ វិញ្ញាបនបត្រសន្សំ, កម្ចីអន្តរធនាគារ, បណ្ណរតនាគារ, ការឱ្យខ្ចីមូលបត្រ ជាដើម។ |
| ១៨ | Multiple price auction | ការដេញថ្លៃតាមអភិក្រមពហុតម្លៃ | សំដៅដល់អភិក្រមកំណត់តម្លៃមូលបត្ររដ្ឋ នៅក្នុងការដេញថ្លៃ ដោយតម្លៃមូលបត្ររដ្ឋនឹងត្រូវកំណត់ខុសៗគ្នា ទៅតាមអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន ឬថ្លៃ ដែលអ្នកឈ្នះបានដាក់ស្នើ។ |
| ១៩ | Negotiable Certificate of Deposits | មូលបត្រអាចជួញដូរបាន | សំដៅដល់ប័ណ្ណបំណុលរយៈពេលខ្លីមានការប្រាក់ ដែលបោះផ្សាយដោយធនាគារជាតិនៃកម្ពុជា។ ប័ណ្ណបំណុលនេះ ត្រូវបានបោះផ្សាយជាប្រាក់រៀល និងដុល្លារអាមេរិក។ |
| ២០ | Non-competitive bidding | ការដេញថ្លៃដោយមិនប្រកួតប្រជែង | សំដៅដល់នីតិវិធីនៃការដេញថ្លៃ ដោយតម្រូវឱ្យវិនិយោគិនដាក់ស្នើតែបរិមាណប៉ុណ្ណោះ ហើយជាទូទៅ មូលបត្ររដ្ឋនឹងលក់ឱ្យវិនិយោគិនក្នុងតម្លៃមួយ ដែលអាចជាមធ្យមភាគនៃតម្លៃដេញថ្លៃឈ្នះ ឬជាតម្លៃដេញថ្លៃឈ្នះទាបជាងគេ នៅក្នុងការដេញថ្លៃដោយប្រកួតប្រជែង។ |
| ២១ | Normal Listing | ការចុះបញ្ជីជួញដូរ | សំដៅដល់ការចុះបញ្ជីនៅផ្សារមូលបត្រ ដើម្បីឱ្យមូលបត្ររដ្ឋដែលបានបោះផ្សាយ អាចជួញដូរបាននៅលើផ្សារមូលបត្រ។ |
| ២២ | Over-the-counter (OTC) | រលែងបញ្ជរ | សំដៅដល់ការជួញដូរមូលបត្ររដ្ឋ នៅក្រៅទីផ្សារមូលបត្រផ្លូវការ ដែលអាចជាការចរចាគ្នាដោយផ្ទាល់រវាងអ្នកលក់ និងអ្នកទិញ ឬតាមរយៈឈ្មួញកណ្តាល។ |
| ២៣ | Primary Dealer | ពាណិជ្ជករដំបូង | សំដៅដល់ក្រុមអ្នកជួញដូរមូលបត្ររដ្ឋ ដែលត្រូវបានតែងតាំងដោយស្ថាប័នបោះផ្សាយ ដើម្បីដើរតួជាអន្តរការីរវាងស្ថាប័នបោះផ្សាយ និងទីផ្សារនៅក្នុងការជួញដូរមូលបត្ររដ្ឋ។ ជាទូទៅ, ពាណិជ្ជករដំបូងមានសិទ្ធិពិសេស ដើម្បីធ្វើប្រតិបត្តិការជួញដូរជាមួយធនាគារកណ្តាលក្នុងប្រតិបត្តិការទីផ្សារចំហ និង/ឬ មានបុព្វសិទ្ធិក្នុងការដេញថ្លៃមូលបត្ររដ្ឋជំបូងគេបង្អស់។ ដើម្បីជាថ្នូរនឹងបុព្វសិទ្ធិខាងលើ, ពាណិជ្ជករដំបូងមានកាតព្វកិច្ចចូលរួមក្នុងទីផ្សារដំបូង និងបំពេញមុខងារបង្កើតតម្លៃទីផ្សារ (ថ្លៃទិញ-លក់) ក្នុងទីផ្សារបន្ទាប់។ បន្ថែមលើនេះ, ពាណិជ្ជករដំបូង មានកាតព្វកិច្ចរក្សាឱ្យបាននូវដើមទុនអប្បបរមា និងស្តង់ដាជំនាញរបស់បុគ្គលិក។ |

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ២៤ | Primary Market | ទីផ្សារដំបូង | សំដៅដល់ទីផ្សារដែលមូលបត្ររដ្ឋ ត្រូវបានបោះផ្សាយលក់ជាលើកដំបូង។ |
| ២៥ | Private Placement | ការលក់ជាលក្ខណៈឯកជន | សំដៅដល់វិធីសាស្ត្របោះផ្សាយលក់មូលបត្ររដ្ឋ ដោយផ្ទាល់ទៅឱ្យវិនិយោគិនគោលដៅ តាមរយៈការចរចា។ |
| ២៦ | Professional Investor | វិនិយោគិនជំនាញ | សំដៅដល់វិនិយោគិនស្ថាប័ន និង/ឬ បុគ្គល ដែលមានបទពិសោធន៍ ចំណេះដឹង និងជំនាញវិជ្ជាជីវៈ លើការវាយតម្លៃហានិភ័យនានា ដើម្បីជាមូលដ្ឋានក្នុងការវិនិយោគ។ |
| ២៧ | Profile Listing | ការចុះបញ្ជីព័ត៌មាន | សំដៅដល់ការចុះបញ្ជីនៅផ្សារមូលបត្រ ដើម្បីបង្ហាញព័ត៌មានជាសាធារណៈអំពីមូលបត្ររដ្ឋដែលបានបោះផ្សាយ ដោយមិនមានការជួញដូរនោះឡើយ។ |
| ២៨ | Quantitative easing | ការចាក់បញ្ចូលសាច់ប្រាក់ | សំដៅដល់ឧបករណ៍គោលនយោបាយរូបិយវត្ថុ ដែលត្រូវបានអនុវត្តដោយធនាគារកណ្តាល ដើម្បីកាត់បន្ថយអត្រាការប្រាក់ និងបង្កើនសាច់ប្រាក់ តាមរយៈការទិញមូលបត្ររដ្ឋដោយផ្ទាល់ពីទីផ្សារចំហ។ |
| ២៩ | Real-Time Gross Settlement System ( RTGS ) | ប្រព័ន្ធទូទាត់ដុលភ្លាមៗ | សំដៅដល់ប្រព័ន្ធដែលអនុញ្ញាតឱ្យការទូទាត់សាច់ប្រាក់ និងការទូទាត់មូលបត្រអាចប្រព្រឹត្តទៅបានភ្លាមៗតាមការបញ្ជាជាក់ស្តែង។ |
| ៣០ | Registration | ការចុះបញ្ជីមូលបត្ររដ្ឋ | សំដៅដល់កត់ត្រា និងគ្រប់គ្រងបញ្ជីឈ្មោះវិនិយោគិនដែលបានទិញមូលបត្ររដ្ឋ។ |
| ៣១ | Retail bonds | សញ្ញាបណ្ណរាយ | សំដៅដល់សញ្ញាបណ្ណដែលមានតម្លៃចារឹក (Par Value) តូចហើយដែលបោះផ្សាយលក់ផ្ទាល់ទៅវិនិយោគិនបុគ្គល។ |
| ៣២ | Retail Investor | វិនិយោគិនបុគ្គល | សំដៅដល់វិនិយោគិនទិញសញ្ញាបណ្ណរាយ ដែលជាទូទៅ ជារូបវន្តបុគ្គល។ |
| ៣៣ | Secondary Market | ទីផ្សារបន្ទាប់ | សំដៅដល់ទីផ្សារជួញដូរមូលបត្ររដ្ឋ ដែលបានបោះផ្សាយលក់រួចហើយ។ |
| ៣៤ | Self-regulatory organization ( SRO ) | ស្ថាប័នស្វ័យនិយ័តករ | សំដៅដល់ស្ថាប័នស្វយ័តមិនមែនសាធារណៈ ដែលចេញបទប្បញ្ញត្តិគ្រប់គ្រងត្រួតពិនិត្យ ឬតាមដានឥរិយាបថរបស់ក្រុមអ្នកចូលរួមក្នុងទីផ្សារហិរញ្ញវត្ថុ។ ស្ថាប័នស្វ័យនិយ័តករអាចមានអំណាចជាផ្លូវការដែលត្រូវបានផ្តល់ឱ្យដោយអាជ្ញាធរហិរញ្ញវត្ថុសាធារណៈ។ ស្ថាប័នស្វ័យនិយ័តករជារឿយៗ មានទំនាក់ទំនងជាមួយអាជ្ញាធរហិរញ្ញវត្ថុសាធារណៈទាំងនោះ។ |

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ៣៥ | Single price auction | ការដេញថ្លៃតាមអតិក្រមតម្លៃតែមួយ | សំដៅដល់អតិក្រមកំណត់តម្លៃមូលបត្ររដ្ឋនៅក្នុងការដេញថ្លៃ ដែលតម្លៃមូលបត្ររដ្ឋនឹងត្រូវកំណត់ដូចគ្នា ដោយយកអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន (Yield) ខ្ពស់ជាងគេ ឬថ្លៃ (Price) ទាបជាងគេ ក្នុងចំណោម Yield ឬ Price ដែលអ្នកឈ្នះបានដាក់ស្នើ។ |
| ៣៦ | Social Government bonds | សញ្ញាបណ្ណរដ្ឋសង្គម | សំដៅដល់សញ្ញាបណ្ណរដ្ឋដែលត្រូវបានបោះផ្សាយ ដើម្បីហិរញ្ញប្បទានគម្រោងដែលផ្តល់គុណប្រយោជន៍ដល់សង្គម ដូចជា គម្រោងដែលពាក់ព័ន្ធនឹង៖ ការផ្តល់សេវាសាធារណៈល្អប្រសើរ, ការបង្កើតការងារ, ការធានាសន្តិសុខស្បៀង, និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតម្លៃសមរម្យសម្រាប់ការរស់នៅ ដោយរួមទាំងលំនៅឋានតម្លៃសមរម្យ។ល។ |
| ៣៧ | Solicited Sovereign Credit Rating | ការវាយតម្លៃចំណាត់ថ្នាក់ឥណទានរបស់ប្រទេសផ្លូវការ | សំដៅដល់ការវាយតម្លៃ ដែលធ្វើឡើងដោយក្រុមហ៊ុនវាយតម្លៃចំណាត់ថ្នាក់ឥណទាន ដោយមានការស្នើសុំពីប្រទេសបោះផ្សាយ ហើយត្រូវបង់កម្រៃសេវា និងផ្តល់ទិន្នន័យផ្លូវការ។ |
| ៣៨ | Sustainability Government bonds | សញ្ញាបណ្ណរដ្ឋនិរន្តរភាព | សំដៅដល់សញ្ញាបណ្ណរដ្ឋដែលដែលត្រូវបានបោះផ្សាយ ដើម្បីហិរញ្ញប្បទានគម្រោងទាំងឡាយណា ដែលផ្តល់គុណប្រយោជន៍ដល់សង្គម និងបរិស្ថាន។ |
| ៣៩ | Sustainability-linked Government bonds | សញ្ញាបណ្ណរដ្ឋផ្សារភ្ជាប់នឹងនិរន្តរភាព | សំដៅដល់សញ្ញាបណ្ណរដ្ឋ ដែលត្រូវបានបោះផ្សាយដើម្បីគាំទ្រដល់ការសម្រេចបាននូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals – SDGs) របស់រដ្ឋាភិបាល ដោយត្រូវវាស់វែងតាមរយៈសូចនាករសមិទ្ធកម្មគន្លឹះ។ |
| ៤០ | Syndication | ការធ្វើសហជីព | សំដៅដល់វិធីសាស្ត្របោះផ្សាយលក់មូលបត្ររដ្ឋ ដោយមានស្ថាប័នមួយក្រុម ជាអ្នកធានាទិញ និងចាត់ចែងលក់មូលបត្ររដ្ឋបន្តទៅវិនិយោគិន ទាំងវិនិយោគិនស្ថាប័ន និងវិនិយោគិនបុគ្គលដែលមានទ្រព្យច្រើន (High-Net-Worth Investor)។ |
| ៤១ | Tap Sales | ការលក់មូលបត្រដោយកំណត់មុន | សំដៅដល់វិធីសាស្ត្របោះផ្សាយលក់មូលបត្ររដ្ឋ ដោយបើកលក់ឡើងវិញនូវប្រភេទមូលបត្ររដ្ឋ ដែលធ្លាប់បានដាក់ឱ្យដេញថ្លៃកន្លងមកតែមិនទាន់ដល់កាលបរិច្ឆេទសង (ប្រភេទមូលបត្រដដែល ទាំងកាលបរិច្ឆេទសង, តម្លៃចារឹក, អត្រាគូប៉ុង, និងលេខកូដស្តង់ដា) តាមរយៈការអនុញ្ញាតឱ្យវិនិយោគិនដាក់ពាក្យស្នើសុំទិញក្នុងរយៈពេលកំណត់។ ជាទូទៅ, មូលបត្ររដ្ឋដែលបើកលក់ឡើងវិញ នឹងមានរយៈពេលសងដើមដាក់ស្តែង ខ្លីជាងឥណប្រតិទាន។ |

| ល.រ. | ភាសាអង់គ្លេស | ភាសាខ្មែរ | និយមន័យ |
|---|---|---|---|
| ៤២ | Thematic bonds | សញ្ញាបណ្ណរដ្ឋតាមវិស័យ | សំដៅដល់សញ្ញាបណ្ណរដ្ឋ ដែលត្រូវបានបោះផ្សាយ ដើម្បីកៀរគរទុនសម្រាប់អនុវត្តគម្រោងអភិវឌ្ឍ ដែលមានគោលដៅជាក់លាក់ជាពិសេស ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs)។ |
| ៤៣ | Underwriter | ភ្នាក់ងារធានាទិញមូលបត្រ | សំដៅដល់ក្រុមហ៊ុនដែលធានាទិញមូលបត្រ តាមតម្លៃកំណត់ពីរដ្ឋាភិបាល ឬ ក្រុមហ៊ុនបោះផ្សាយ និងចាត់ចែងលក់មូលបត្រនោះបន្តទៅវិនិយោគិន។ |
| ៤៤ | Unsolicited Sovereign Credit Rating | ការវាយតម្លៃចំណាត់ថ្នាក់ឥណទានរបស់ប្រទេសមិនផ្លូវការ | សំដៅដល់ការវាយតម្លៃ ដែលធ្វើឡើងដោយក្រុមហ៊ុនវាយតម្លៃចំណាត់ថ្នាក់ឥណទាន ដោយពុំមានការស្នើសុំពីប្រទេសបោះផ្សាយ។ |
| ៤៥ | Yield | អត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន | សំដៅដល់អត្រាចំណូល ដែលវិនិយោគិននឹងទទួលបានត្រឡប់មកវិញពីការកាន់កាប់មូលបត្រ រហូតដល់ថ្ងៃឥណប្រតិទាន។ |
| ៤៦ | Yield Curve | ខ្សែកោងអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន | សំដៅដល់ខ្សែកោង/ក្រាហ្វ ដែលបង្ហាញអំពីទំនាក់ទំនងរវាងអត្រាទិន្នផល/អត្រាចំណូលរបស់វិនិយោគិន និងប្រភេទឥណប្រតិទានផ្សេងៗគ្នា។ |
| ៤៧ | Winner's Curse | ហេតុការណ៍អាក្រក់របស់អ្នកឈ្នះ | សំដៅដល់ហេតុការណ៍មិនល្អដែលវិនិយោគិនឈ្នះការដេញថ្លៃ ត្រូវប្រឈម ដោយសារមិនមានព័ត៌មានច្បាស់លាស់ក្នុងការចូលរួមដេញថ្លៃ។ ឧទាហរណ៍៖ វិនិយោគិនទិញមូលបត្រក្នុងបរិមាណច្រើន និងក្នុងតម្លៃខ្ពស់ជាងវិនិយោគិនផ្សេងទៀតដែលមានព័ត៌មានច្បាស់លាស់។ |

ឧបសម្ព័ន្ធទី២

# ផែនការសកម្មភាព

# «ផែនការសកម្មភាព
# សម្រាប់អនុវត្តក្របខ័ណ្ឌគោលនយោបាយស្ដីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ដំណាក់កាលទី១ | | | | ដំណាក់កាលទី២ | |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ១ | បន្តពិនិត្យ និងរៀបចំលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ | | | | | | | | |
| ១.១ | ការធ្វើអាជីវកម្មលើមូលបត្ររដ្ឋ និងការអនុញ្ញាតលើអាជីវកម្មមូលបត្ររដ្ឋ (Securities Business) ដល់អន្តរការី ( Eligible Intermediary), និងពាណិជ្ជករ (Dealers)/ភ្នាក់ងារធានាទិញមូលបត្រ (Underwriters) | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធ្វើអាជីវកម្មលើមូលបត្ររដ្ឋ និងការអនុញ្ញាតលើអាជីវកម្មមូលបត្ររដ្ឋដល់អន្តរការី ( Eligible Intermediary), និងពាណិជ្ជករ/ភ្នាក់ងារធានាទិញមូលបត្រ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ក.ស.ហ.វ. (អ.ស.ប.) ធ.ជ.ក. ន.ម.ក. | X | X | X | X | | |
| ១.២ | នីតិវិធី និងដំណើរការនៃការស្នើទិញ (Subscription), ការជួញដូរ, ការទូទាត់ និងការកាត់ទុកពន្ធ | នីតិវិធី និងដំណើរការនៃការស្នើទិញ, ការជួញដូរ, ការទូទាត់ និងការកាត់ទុកពន្ធ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | | X | X | X | X | | |
| ១.៣ | ការធ្វើបច្ចុប្បន្នកម្មការលើកទឹកចិត្តពន្ធដារ សម្រាប់ការវិនិយោគលើមូលបត្ររដ្ឋ | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធ្វើបច្ចុប្បន្នកម្មការលើកទឹកចិត្តពន្ធដារ សម្រាប់ការវិនិយោគលើមូលបត្ររដ្ឋ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ក.ស.ហ.វ. (អ.ព.ដ.) | | X | X | | | |
| ១.៤ | នីតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងមូលបត្ររដ្ឋ (Standard Operating Procedures for Government Securities Management) | នីតិវិធីរួមប្រតិបត្តិការសម្រាប់ការគ្រប់គ្រងមូលបត្ររដ្ឋ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តដោយប្រកាស | ក.ស.ហ.វ. (អ.ស.ប.) | | X | X | X | | |
| ១.៥ | គោលការណ៍ក្នុងការកំណត់ទំហំ និងរូបិយប័ណ្ណនៃការបោះផ្សាយ ដោយរួមទាំងការរៀបចំផែនការបោះផ្សាយលក់មូលបត្ររដ្ឋ | គោលការណ៍ក្នុងការកំណត់ទំហំ និងរូបិយប័ណ្ណនៃការបោះផ្សាយ ដោយរួមទាំងការរៀបចំផែនការបោះផ្សាយលក់មូលបត្ររដ្ឋ ត្រូវបានបញ្ចូលទៅក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ | ក.ស.ហ.វ. (អ.ស.ប.) | | X | X | X | | |

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ដំណាក់កាលទី១ | | | | ដំណាក់កាលទី២ | |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ១.៦ | យន្តការស្ថាប័ន និងយន្តការសម្របសម្រួល ក្នុងការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ | - យន្តការស្ថាប័ន ត្រូវបានបញ្ចូល ទៅក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈ<br>- យន្តការសម្របសម្រួល ត្រូវបានបង្កើត | ក.សហវ.<br>ធ.ជ.ក.<br>ន.ម.ក.<br>ន.ធ.ក.<br>ន.ស.ស. | | X | X | X | | |
| ១.៧ | លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេងទៀត តាមតម្រូវការជាក់ស្តែង | លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេងទៀត ត្រូវបានរៀបចំ | ក.សហវ.<br>ធ.ជ.ក.<br>ន.ម.ក.<br>ន.ធ.ក.<br>ន.ស.ស. | X | X | X | X | | |
| ២. | **រៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទុនពីការបោះផ្សាយលក់មូលបត្ររដ្ឋ** | | | | | | | | |
| ២.១ | រៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទុនទទួលបានពីការបោះផ្សាយលក់មូលបត្ររដ្ឋ ព្រមជាមួយនឹងយន្តការនៃការសិក្សា និងជ្រើសរើសគម្រោងសម្រាប់អនុវត្តដោយប្រើប្រាស់ចំណូលពីការបោះផ្សាយលក់មូលបត្ររដ្ឋ | គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទុនទទួលបានពីការបោះផ្សាយលក់មូលបត្ររដ្ឋ ព្រមជាមួយនឹងយន្តការនៃការសិក្សា និងជ្រើសរើសគម្រោងសម្រាប់អនុវត្តដោយប្រើប្រាស់ចំណូលពីការបោះផ្សាយលក់មូលបត្ររដ្ឋ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ក.ស.ហ.វ.<br>(អ.ស.ប.) | X | X | | | | |
| ៣ | **បន្តអភិវឌ្ឍទីផ្សារមូលបត្ររដ្ឋ** | | | | | | | | |
| ក | **ទីផ្សារដំបូង** | | | | | | | | |
| ៣.១ | បន្តរៀបចំយន្តការបោះផ្សាយក្នុងទីផ្សារដំបូង ដើម្បីឱ្យគ្រឹះស្ថានមិនមែនធនាគារ និងហិរញ្ញវត្ថុ (Eligible Non-Banks) អាចចូលរួមវិនិយោគដោយផ្ទាល់តាមផ្លែតហ្វមរបស់ធនាគារជាតិនៃកម្ពុជា (NBCP) | គ្រឹះស្ថានមិនមែនធនាគារ និងហិរញ្ញវត្ថុ (Eligible Non-Banks) អាចចូលរួមវិនិយោគដោយផ្ទាល់តាម NBCP | ក.សហវ.<br>ធ.ជ.ក.<br>ន.ម.ក. | X | X | X | X | | |

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ដំណាក់កាលទី១ | | | | ដំណាក់កាលទី២ | |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ៣.២ | រៀបចំនីតិវិធីរួមប្រតិបត្តិការសម្រាប់ការងារបោះផ្សាយក្នុងទីផ្សារដំបូង | នីតិវិធីរួមប្រតិបត្តិការសម្រាប់ការងារបោះផ្សាយក្នុងទីផ្សារដំបូង ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ធ.ជ.ក. | X | X | | | | |
| **ខ** | **ទីផ្សារបន្ទាប់** | | | | | | | | |
| ៣.៣ | រៀបចំយន្តការជួញដូរមូលបត្ររដ្ឋក្នុងទីផ្សារបន្ទាប់ តាមរយៈ NBCP សំដៅបង្កើតឱ្យបាននូវទីផ្សារបន្ទាប់ដែលមានលក្ខណៈពេញលេញ, សន្ទនីយភាពខ្ពស់, ថ្លៃប្រតិបត្តិការនិងហានិភ័យទាប | យន្តការជួញដូរមូលបត្ររដ្ឋក្នុងទីផ្សារបន្ទាប់ តាមរយៈ NBCP ត្រូវបានរៀបចំ | ក.ស.ហ.វ. (អ.ស.ប.)<br>ធ.ជ.ក.<br>ន.ម.ក. | X | X | X | | | |
| ៣.៤ | រៀបចំនីតិវិធីរួមប្រតិបត្តិការសម្រាប់ការងារជួញដូរមូលបត្ររដ្ឋក្នុងទីផ្សារបន្ទាប់ | នីតិវិធីរួមប្រតិបត្តិការសម្រាប់ការងារជួញដូរមូលបត្ររដ្ឋក្នុងទីផ្សារបន្ទាប់ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ធ.ជ.ក. | X | X | X | | | |
| ៣.៥ | សិក្សាលើការកំណត់កម្រៃសេវាសម្រាប់ការជួញដូរក្នុងទីផ្សារបន្ទាប់ តាមរយៈ NBCP | កម្រៃសេវាសម្រាប់ការជួញដូរក្នុងទីផ្សារបន្ទាប់ ត្រូវបានសិក្សា | ក.ស.ហ.វ.<br>ធ.ជ.ក. | | | | X | | |
| **គ** | **ពង្រឹងទំនាក់ទំនងវិនិយោគិន** | | | | | | | | |
| ៣.៦ | បន្តរៀបចំកិច្ចពិគ្រោះយោបល់ដើម្បីស្ទាបស្ទង់ទីផ្សារ ( Market Sounding ) ជាមួយវិនិយោគិនជាប្រចាំ | កិច្ចពិគ្រោះយោបល់ជាមួយវិនិយោគិន ត្រូវបានបន្តរៀបចំជាប្រចាំ | ក.ស.ហ.វ. (អ.ស.ប.)<br>ធ.ជ.ក.<br>ន.ម.ក.<br>ន.ធ.ក. | X | X | X | X | X | X |
| ៣.៧ | បន្តផ្សព្វផ្សាយជាទៀងទាត់នូវផែនការបោះផ្សាយលក់មូលបត្ររដ្ឋ | ផែនការបោះផ្សាយលក់មូលបត្ររដ្ឋ ត្រូវបានបន្តផ្សព្វផ្សាយជាទៀងទាត់ | ក.ស.ហ.វ. (អ.ស.ប.)<br>ធ.ជ.ក. | X | X | X | X | X | X |
| ៣.៨ | រៀបចំកម្មវិធីផ្សព្វផ្សាយលក់មូលបត្ររដ្ឋ ( Roadshow ) | កម្មវិធីផ្សព្វផ្សាយលក់មូលបត្ររដ្ឋ ត្រូវបានរៀបចំ | ក.ស.ហ.វ. (អ.ស.ប.) | X | X | X | X | X | X |

| លរ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ដំណាក់កាលទី១ | | | | ដំណាក់កាលទី២ | |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ៣.៩ | រៀបចំសិក្ខាសាលាដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល, គោលការណ៍ណែនាំ, ឬព័ត៌មានចាំបាច់នានា តាមតម្រូវការជាក់ស្តែង | សិក្ខាសាលាដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាល, គោលការណ៍ណែនាំ, ឬព័ត៌មានចាំបាច់នានា ត្រូវបានរៀបចំ តាមតម្រូវការជាក់ស្តែង | ក.ស.ហ.វ. (អ.ស.ប.)<br>អង្គភាពពាក់ព័ន្ធ | X | X | X | X | X | X |
| ៣.១០ | សិក្សាបង្កើតខ្សែកោងអត្រាទិន្នផល/ខ្សែកោងអត្រាចំណូលរបស់វិនិយោគិន (Yield Curve) | ខ្សែកោងអត្រាទិន្នផល/ខ្សែកោងអត្រាចំណូលរបស់វិនិយោគិន ត្រូវបានសិក្សាបង្កើត | ក.ស.ហ.វ. (អ.ស.ប.)<br>ធ.ជ.ក.<br>ន.ម.ក. | | X | X | X | | |
| **ឃ** | **រៀបចំប្រព័ន្ធគាំទ្រទីផ្សារ** | | | | | | | | |
| ៣.១១ | អភិវឌ្ឍបន្ថែមនូវមុខងារនៃប្រព័ន្ធ NBCP ដែលមានស្រាប់ សំដៅគាំទ្រដល់ដំណើរការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ, ការទូទាត់, ការរក្សាទុកមូលបត្ររដ្ឋ, ការកត់ត្រា និងផលិតរបាយការណ៍ | ប្រព័ន្ធ NBCP ដែលមានស្រាប់ ត្រូវបានអភិវឌ្ឍបន្ថែមនូវមុខងារ សំដៅគាំទ្រដល់ដំណើរការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ, ការទូទាត់, ការរក្សាទុកមូលបត្ររដ្ឋ, ការកត់ត្រា និងផលិតរបាយការណ៍ | ក.ស.ហ.វ. (អ.ស.ប.)<br>ធ.ជ.ក. | X | X | X | X | | |
| **៤** | **រៀបចំយន្តការសម្របសម្រួលដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណាត់ថ្នាក់ឥណទានរបស់ប្រទេស** | | | | | | | | |
| ៤.១ | បង្កើតក្រុមការងារ ដើម្បីសម្របសម្រួលជាមួយតួអង្គពាក់ព័ន្ធលើការវាយតម្លៃចំណាត់ថ្នាក់ឥណទាន; ត្រួតពិនិត្យ, ផ្ទៀងផ្ទាត់, និងវាយតម្លៃលទ្ធផលនៃចំណាត់ថ្នាក់ឥណទាន; និងសិក្សាអំពីចំណុចដែលត្រូវកែលម្អ ដើម្បីធ្វើឱ្យប្រសើរឡើងនូវចំណាត់ថ្នាក់ឥណទាន | ក្រុមការងារ ត្រូវបានបង្កើតដោយសេចក្តីសម្រេចរបស់ ក.ស.ហ.វ. | ក.ស.ហ.វ. | | | X | X | | |
| **៥** | **សិក្សារៀបចំយន្តការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ** | | | | | | | | |
| ៥.១ | សិក្សា និងវិភាគលើគោលការណ៍សម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ (Thematic Bonds) | របាយការណ៍ស្តីពីការសិក្សា និងវិភាគលើស្តង់ដាគោលការណ៍សម្រាប់ការបោះផ្សាយលក់សញ្ញា-បណ្ណរដ្ឋតាមវិស័យ ត្រូវបានរៀបចំ | ក.ស.ហ.វ.<br>(អ.ស.ប.) | | X | X | | | |

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ដំណាក់កាលទី១ | | | | ដំណាក់កាលទី២ | |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ៥.២ | រៀបចំគោលការណ៍ណែនាំសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ | គោលការណ៍ណែនាំសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋតាមវិស័យ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ក.សហវ.(អ.ស.ប.)<br>ធ.ជ.ក.<br>ន.ម.ក. | | | X | X | | |
| ៦ | **ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស** | | | | | | | | |
| ៦.១ | អនុវត្ត «ផែនការអភិវឌ្ឍន៍សមត្ថភាព ស្ថាប័ន និងធនធានមនុស្សសម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ» | របាយការណ៍វឌ្ឍនភាពស្ដីពីការអនុវត្ត «ផែនការអភិវឌ្ឍន៍សមត្ថភាព ស្ថាប័ន និងធនធានមនុស្សសម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ» ត្រូវបានរៀបចំ | ក.ស.ហ.វ.<br>(អ.ស.ប.) | X | X | X | X | X | X |
| ៧ | **ពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីរួមប្រតិបត្តិការ** | | | | | | | | |
| ៧.១ | ពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីរួមប្រតិបត្តិការ តាមការចាំបាច់ | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីរួមប្រតិបត្តិការត្រូវបានពិនិត្យ និងកែសម្រួល តាមការចាំបាច់ | ក.ស.ហ.វ.<br>អង្គភាពពាក់ព័ន្ធ | | | | | X | X |
| ៨ | **ពិនិត្យ និងកែលម្អទីផ្សារមូលបត្ររដ្ឋ** | | | | | | | | |
| ៨.១ | ពិនិត្យឡើងវិញ និងកែលម្អទីផ្សារមូលបត្ររដ្ឋ ដែលរួមមាន៖ ទីផ្សារដំបូង, ទីផ្សារបន្ទាប់, ទំនាក់ទំនងវិនិយោគិននិងអ្នកចូលរួមទីផ្សារ, និងប្រព័ន្ធគាំទ្រទីផ្សារ តាមការចាំបាច់ | ទីផ្សារមូលបត្ររដ្ឋ ត្រូវបានពិនិត្យឡើងវិញ និងកែលម្អតាមការចាំបាច់ | ក.សហវ.(អ.ស.ប.)<br>ន.ម.ក.<br>ធ.ជ.ក. | | | | | X | X |
| ៨.២ | ពិនិត្យឡើងវិញលើនិម្មាបនកម្មទីផ្សារ (Market Architecture) និងសិក្សាលើការចូលរួមរបស់ ផ.ម.ក. តាមការចាំបាច់ | និម្មាបនកម្មទីផ្សារ ត្រូវបានពិនិត្យឡើងវិញ | ក.សហវ.(អ.ស.ប.)<br>ធ.ជ.ក.<br>ន.ម.ក.<br>ផ.ម.ក. | | | | | | X |

| ល.រ. | ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្មគន្លឹះ | អង្គភាពទទួលបន្ទុក | ដំណាក់កាលទី១ | | | | ដំណាក់កាលទី២ | |
|---|---|---|---|---|---|---|---|---|---|
| | | | | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ |
| ៩ | **សិក្សាសមិទ្ធិលទ្ធភាព និងយន្តការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស** | | | | | | | | |
| ៩.១ | សិក្សា និងពិនិត្យលើបែបបទ, នីតិវិធី, និងការបំពេញបុរេលក្ខខណ្ឌក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស (International Bond) | របាយការណ៍ស្ដីពីការសិក្សា និងពិនិត្យលើបែបបទ, នីតិវិធី, និងការបំពេញបុរេលក្ខខណ្ឌក្នុងការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស ត្រូវបានរៀបចំ | ក.ស.ហ.វ. (អ.ស.ប.) | | | | | X | |
| ៩.២ | សិក្សាសមិទ្ធិលទ្ធភាពលើការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស | របាយការណ៍ស្ដីពីការសិក្សាសមិទ្ធិលទ្ធភាពលើការបោះផ្សាយលក់មូលបត្ររដ្ឋនៅក្រៅប្រទេស ត្រូវបានរៀបចំ | | | | | | X | X |
| ១០ | **ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស** | | | | | | | | |
| ១០.១ | ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ តាមការចាំបាច់ | ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ ត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នកម្ម តាមការចាំបាច់ | ក.ស.ហ.វ. (អ.ស.ប.) | | | | | X | X |
| | **សរុប** | | | ១៤ | ២០ | ២០ | ១៧ | ១០ | ១០ |

***បញ្ចប់ត្រឹម ១០ ចង្កោមសកម្មភាព ស្មើនឹង ២៩ សកម្មភាព។***

** ផែនការសកម្មភាពនេះ អាចនឹងត្រូវបានពិនិត្យ និងកែសម្រួល តាមការចាំបាច់។*

**កំណត់សម្គាល់**

- ក.ស.ហ.វ.៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធ.ជ.ក.៖ ធនាគារជាតិនៃកម្ពុជា
- ផ.ម.ក.៖ ផ្សារមូលបត្រកម្ពុជា
- អ.ព.ជ.៖ អគ្គនាយកដ្ឋានពន្ធដារ
- ន.ម.ក.៖ និយ័តករមូលបត្រកម្ពុជា
- ន.ស.ស.៖ និយ័តករសន្តិសុខសង្គម
- អ.ស.ប.៖ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល
- ន.ធ.ក.៖ និយ័តករធានារ៉ាប់រងកម្ពុជា

ឧបសម្ព័ន្ធទី៣

# ផែនការអភិវឌ្ឍន៍សមត្ថភាព ស្ថាប័ន និងធនធានមនុស្ស

# មាតិកា

**ជំពូកទី១៖ សេចក្តីផ្តើម** ........ ១
**ជំពូកទី២៖ គោលបំណង, គោលដៅ, និងវិសាលភាព** ........ ២
២.១. គោលបំណង និងគោលដៅ ........ ២
២.២. វិសាលភាព ........ ២
**ជំពូកទី៣៖ ការវិភាគចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព, និងការគំរាមកំហែង** .. ៣
៣.១. ចំណុចខ្លាំង ........ ៣
៣.២. ចំណុចខ្សោយ ........ ៤
៣.៣. កាលានុវត្តភាព ........ ៤
៣.៤. ការគំរាមកំហែង ........ ៥
**ជំពូកទី៤៖ ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០២៣ - ២០២៨** ........ ៦
៤.១. ផែនការសកម្មភាពក្នុងការពង្រឹងសមត្ថភាពស្ថាប័ន ........ ៦
៤.២. ផែនការសកម្មភាពក្នុងការពង្រឹងសមត្ថភាពធនធានមនុស្ស ........ ៦
**ជំពូកទី៥៖ គម្រោងប៉ាន់ស្មានថវិកាចំណាយ សម្រាប់ការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ២០២៣ - ២០២៨** ........ ៩

# ជំពូកទី១
# សេចក្តីផ្តើម

នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងបំណុលសាធារណៈកម្ពុជាកន្លងមក មានមុខងារសំខាន់ៗទាំង ៣ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិរួចហើយ រួមមាន៖ ការិយាល័យជួរមុខ (Front Office), ការិយាល័យកណ្តាល (Middle Office), និងការិយាល័យជួរក្រោយ (Back Office) ដែលស្ថិតក្រោមឆ័ត្ររួមនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ប៉ុន្តែមុខងារការិយាល័យជួរមុខនៅមានការបែកខ្ញែកគ្នា ដោយក្នុងនោះ ការិយាល័យជួរមុខសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈក្រៅប្រទេស ស្ថិតក្រោមសមត្ថកិច្ចអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) រីឯការិយាល័យជួរមុខសម្រាប់គ្រប់គ្រងបំណុលសាធារណៈក្នុងប្រទេស ស្ថិតក្រោមអតីតអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ។

បន្ទាប់ពី **"ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"** និង **"ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម"** ចូលជាធរមាន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការកែសម្រួលរចនាសម្ព័ន្ធស្ថាប័នឡើងវិញ និងបានផ្ទេរមុខងារការិយាល័យជួរមុខសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈក្នុងប្រទេស មកស្ថិតក្រោមសមត្ថកិច្ចរបស់ អ.ស.ប.។ តាមរយៈនេះ និងឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ចំពោះមុខ, មុខងារការិយាល័យជួរមុខសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈក្នុងប្រទេស ត្រូវបានរៀបចំជាការិយាល័យថ្មីក្រោមឱវាទនាយកដ្ឋានគ្រប់គ្រងបំណុល នៃ អ.ស.ប. កាលពីខែមិថុនា ឆ្នាំ២០២២ ដើម្បីបំពេញភារកិច្ចសម្របសម្រួលលើរាល់កិច្ចការបច្ចេកទេសពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ហើយបន្ទាប់មក កាលពីខែកក្កដា ឆ្នាំ២០២៣ ការិយាល័យនេះត្រូវបានដំឡើងទៅជានាយកដ្ឋានមូលបត្ររដ្ឋ បំពេញមុខងារជាសេនាធិការឱ្យ អ.ស.ប. លើការងារគ្រប់គ្រងមូលបត្ររដ្ឋ។

ថ្វីត្បិតតែយន្តការស្ថាប័ននេះ បានគាំទ្រដល់ការបោះផ្សាយលក់មូលបត្ររដ្ឋកន្លងមកក្តី ក៏ប៉ុន្តែ ចំពោះមុខ, សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការអភិវឌ្ឍមូលបត្ររដ្ឋ ចាំបាច់ត្រូវមានការពង្រឹងបន្ថែមទៀត ដើម្បីអាចឆ្លើយតបទៅនឹងការអភិវឌ្ឍមូលបត្ររដ្ឋនៅដំណាក់កាលបន្តបន្ទាប់ទៀត ដោយហេតុថា កិច្ចការនេះមានទំហំកាន់តែរីកធំ និងស្មុគស្មាញ ហើយក៏ជាកិច្ចការថ្មីស្រឡាងសម្រាប់កម្ពុជាផងដែរ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវ **"ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨"** សម្រាប់ប្រើប្រាស់ជាត្រីវិស័យក្នុងការពង្រឹងសមត្ថភាព និងធនធានមនុស្សពាក់ព័ន្ធនឹងការអភិវឌ្ឍមូលបត្ររដ្ឋ ដើម្បីគាំទ្រដល់ការកសាងនូវប្រព័ន្ធគ្រប់គ្រងមួយដ៏រឹងមាំ និងគ្រប់ជ្រុងជ្រោយសម្រាប់ការបោះផ្សាយនិងការជួញដូរមូលបត្ររដ្ឋ សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព នៃការគ្រប់គ្រងការបោះផ្សាយនិងការជួញដូរមូលបត្ររដ្ឋ ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។

**"ផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨"** ជាឯកសារមូលដ្ឋានដ៏មានសារៈសំខាន់ និងមិនអាចខ្វះបាន ដើម្បីគាំទ្រដល់ការអនុវត្ត **"ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣-២០២៨"** ហើយផែនការនេះគឺជា **"ឯកសាររស់"** ដែលអាចនឹងត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្ម តាមការចាំបាច់។

# ជំពូកទី២
# គោលបំណង, គោលដៅ, និងវិសាលភាព

## ២.១. គោលបំណង និងគោលដៅ

**"ផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨"** មានគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការអភិវឌ្ឍមូលបត្ររដ្ឋ សំដៅគ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ, ផែនការនេះ មានគោលដៅដាក់ចេញនូវផែនការសកម្មភាពក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការអភិវឌ្ឍមូលបត្ររដ្ឋ។

## ២.២. វិសាលភាព

ផែនការនេះ មានវិសាលភាពគ្របដណ្តប់លើការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការអភិវឌ្ឍមូលបត្ររដ្ឋរបស់កម្ពុជា។

# ជំពូកទី៣
# ការវិភាគចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព, និងការគំរាមកំហែង

ការអភិវឌ្ឍមូលបត្ររដ្ឋជាកិច្ចការបច្ចេកទេសស្មុគស្មាញ និងថ្មីស្រឡាងសម្រាប់កម្ពុជា ដូចនេះ ការអនុវត្តការងារកន្លងមក ត្រូវធ្វើឡើងតាមអភិក្រម **"រៀនផង-ធ្វើផង"** ហើយកិច្ចការសំខាន់ៗមួយចំនួន ត្រូវការជាតុចូល និងជំនួយបច្ចេកទេសច្រើនពីដៃគូអភិវឌ្ឍនានា ដើម្បីអាចឈានទៅបោះផ្សាយលក់មូលបត្ររដ្ឋជាលើកដំបូងនៅឆ្នាំ២០២២ និងជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងមក។ ចំពោះមុខ, រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សបន្ថែមទៀត ដើម្បីកសាងបាននូវសមត្ថភាពស្ថាប័នមួយដែលរឹងមាំ ព្រមទាំងធនធានមនុស្សប្រកបដោយសមត្ថភាពជំនាញវិជ្ជាជីវៈ ដែលអាចឆ្លើយតបបានទៅនឹងការអភិវឌ្ឍមូលបត្ររដ្ឋនៅដំណាក់កាលបន្តបន្ទាប់។

ក្នុងស្មារតីនេះ, ដើម្បីជាមូលដ្ឋានក្នុងការដាក់ចេញនូវផែនការសកម្មភាពសម្រាប់ការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ឆ្នាំ២០២៣ - ២០២៨ ប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ, ប្រាកដនិយម, និងស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ, រាជរដ្ឋាភិបាលបានវិភាគលើចំណុចខ្លាំង, ចំណុចខ្សោយ, កាលានុវត្តភាព, និងការគំរាមកំហែង (SWOT Analysis) ដូចខាងក្រោម៖

## ៣.១. ចំណុចខ្លាំង

- រាជរដ្ឋាភិបាលមានរបៀបវារៈគោលនយោបាយច្បាស់លាស់ ក្នុងការកសាង និងអភិវឌ្ឍប្រទេស ជាពិសេសការអភិវឌ្ឍធនធានមនុស្ស ដែលជាអាទិភាពទី១ នៃយុទ្ធសាស្ត្រចតុកោណ តាំងពីដំណាក់កាលទី៣ និងទី៤ មកម្ល៉េះ ហើយនៅតែបន្តជាអាទិភាពទី១ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។
- រាជរដ្ឋាភិបាលមានឆន្ទៈគោលនយោបាយខ្ពស់ក្នុងការបន្តសកម្មភាពអនុវត្តកម្មវិធីកែទម្រង់គន្លឹះៗ ទាំង ៤ រួមមាន៖ ១) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ២) កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, ៣) កម្មវិធីកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ, និង ៤) កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលក្នុងនោះក៏ផ្តោតសំខាន់លើការបន្តពង្រឹងគុណភាពស្ថាប័ន និងធនធានមនុស្សនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធផងដែរ។
- រចនាសម្ព័ន្ធស្ថាប័នបច្ចុប្បន្ននៃអង្គភាពគ្រប់គ្រងបំណុលសាធារណៈ មានភាពរឹងមាំ ដោយគ្របដណ្តប់នូវមុខងារសំខាន់ទាំង៣ នៃការគ្រប់គ្រងបំណុលសាធារណៈ ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ រួមមាន៖ ១) ការិយាល័យជួរមុខ (Front Office) ក្នុងនោះ ការិយាល័យថ្មី ដែលមានភារកិច្ចសម្របសម្រួលរាល់កិច្ចការបច្ចេកទេសពាក់ព័ន្ធនឹងមូលបត្ររដ្ឋ ត្រូវបានបង្កើតឡើងនៅក្នុងខែមិថុនា ឆ្នាំ២០២២ ហើយត្រូវបានដំឡើងទៅជានាយកដ្ឋាននៅក្នុងខែកក្កដា ឆ្នាំ២០២៣, ២) ការិយាល័យជួរកណ្តាល (Middle Office), និង ៣) ការិយាល័យជួរក្រោយ (Back Office)។
- សមត្ថភាពធនធានមនុស្សក្នុងកិច្ចការគ្រប់គ្រងបំណុលសាធារណៈ មានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយមានភាពជាម្ចាស់ធ្វើកិច្ចការសំខាន់ៗជាច្រើនបាន ដូចជា៖ ការរៀបចំឯកសារបទដ្ឋានគតិយុត្ត, គោលនយោបាយ និងយុទ្ធសាស្ត្រនានា, ព្រមទាំងការវិភាគ និងកិច្ចការពាក់ព័ន្ធជាច្រើនផ្សេងៗទៀត។
- មន្ត្រីពាក់ព័ន្ធភាគច្រើន មានទំនួលខុសត្រូវខ្ពស់ចំពោះតួនាទី និងភារកិច្ចរបស់ខ្លួន ព្រមទាំងមានឆន្ទៈមោះមុតក្នុងការអភិវឌ្ឍសមត្ថភាពជំនាញបន្ថែម។

## ៣.២. ចំណុចខ្សោយ

- បរិមាណធនធានមនុស្សបច្ចុប្បន្ន មិនទាន់អាចគាំទ្រដល់ការអភិវឌ្ឍមូលបត្ររដ្ឋបានពេញលេញនៅឡើយ ជាពិសេស នៅពេលដែលទំហំការងារនេះកាន់តែរីកធំ និងស្មុគស្មាញនាដំណាក់កាលបន្តបន្ទាប់។
- សមត្ថភាពបច្ចេកទេស ជាពិសេស ការអភិវឌ្ឍឧបករណ៍មូលបត្ររដ្ឋ, ការពង្រឹងទំនាក់ទំនងវិនិយោគិន, ការវិភាគទីផ្សារ និងហានិភ័យ ពុំទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការការងារ។
- ភាគច្រើននៃមន្ត្រីថ្មី ដែលទើបត្រូវបានជ្រើសរើសឱ្យមកបំពេញការងារ មានតែចំណេះដឹងទូទៅ ពោលគឺពុំធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងមូលបត្ររដ្ឋនៅឡើយ។
- ចំណេះដឹង និងបទពិសោធន៍លើការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ ព្រមទាំងការចូលរួមវិនិយោគមូលបត្ររដ្ឋ នៅមានកម្រិត។

## ៣.៣. កាលានុវត្តភាព

- **ផ្នែកបច្ចេកទេស៖** កម្ពុជាមានជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍនានាជាច្រើន ដូចជា៖ ធនាគារពិភពលោក (World Bank), មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដោយរួមទាំងលេខាធិការដ្ឋានអាស៊ាន (ASEAN Secretariat), កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP), មូលនិធិអភិវឌ្ឍន៍មូលធនរបស់អង្គការសហប្រជាជាតិ (UNCDF), កម្មវិធីភាពជាដៃគូកម្ពុជា - អូស្ត្រាលីសម្រាប់ការអភិវឌ្ឍ ប្រកបដោយភាពធន់(CAPRED), វិទ្យាស្ថានកំណើនបៃតងសកល (GGGI), គណៈកម្មការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (UNESCAP), និង ទីភ្នាក់ងារបារាំងសម្រាប់ ការអភិវឌ្ឍ (AFD) ជាដើម។ ជាការអនុវត្តកន្លងមក, ដៃគូអភិវឌ្ឍទាំងនោះផ្តល់ជំនាញការអន្តរជាតិ ឬអ្នកជំនាញបច្ចេកទេស ដើម្បី៖ ១) ជួយសិក្សា និងផ្តល់ជាតុចូលសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត, គោលនយោបាយ, និងកិច្ចការបច្ចេកទេសពាក់ព័ន្ធ និង ២) ចែករំលែកចំណេះដឹងជំនាញ និងបទពិសោធន៍លើការងារអភិវឌ្ឍមូលបត្ររដ្ឋ និងការងារបច្ចេកទេសពាក់ព័ន្ធនានា។ ទៅថ្ងៃមុខ, ដៃគូអភិវឌ្ឍទាំងនេះក៏នៅតែបង្ហាញឆន្ទៈក្នុងការជួយគាំទ្រដល់កម្ពុជា ក្នុងការកសាងប្រព័ន្ធពេញលេញសម្រាប់ការគ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋផងដែរ។
- **ផ្នែកហិរញ្ញវត្ថុ៖** រាជរដ្ឋាភិបាលអាចប្រើប្រាស់ជំនួយហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍ និងពីប្រភពផ្សេងទៀត សម្រាប់ហិរញ្ញប្បទានមន្ត្រីពាក់ព័ន្ធទៅចូលរួមសិក្ខាសាលា, វគ្គបណ្តុះបណ្តាល, ទស្សនកិច្ចសិក្សា, សន្និសីទ, វេទិកាទាំងក្នុងស្រុក និងក្រៅប្រទេស, និងសម្រាប់ផ្តល់ការលើកទឹកចិត្តដល់មន្ត្រីដែលមានសមត្ថភាព និងឆន្ទៈវិជ្ជាជីវៈខ្ពស់។
- **ផ្នែកបច្ចេកវិទ្យាឌីជីថល៖** ការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល និងបទពិសោធន៍នៃការរស់នៅក្នុងបរិបទជំងឺកូវីដ-១៩ កន្លងមក បាននិងកំពុងជំរុញឱ្យស្ថាប័ននានាអាចប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់អនុវត្តកិច្ចការរដ្ឋបាលធុរកិច្ច និងទំនាក់ទំនងការងារបានកាន់តែមានប្រសិទ្ធភាព។ កត្តានេះផ្តល់ជាបរិយាកាសអំណោយផលដល់ការអនុវត្តកិច្ចការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ ដោយសារកិច្ចការនេះភាគច្រើនផ្សារភ្ជាប់ទៅនឹងប្រព័ន្ធបច្ចេកវិទ្យា។ ទន្ទឹមនេះ, អភិក្រមក្នុងការសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត ក៏មានប្រសិទ្ធភាពច្រើនជាងមុនផងដែរ។

## ៣.៤. ការគំរាមកំហែង

- ភាពទាក់ទាញខ្លាំងនៃការងារនៅតាមវិស័យឯកជន និងអង្គការ ស្ថាប័ននានា ដែលអាចជាបញ្ហាប្រឈមដ៏ចម្បង ក្នុងការរក្សាទុក និងស្រូបយកនូវធនធានមនុស្សល្អៗ ឱ្យនៅបន្ត និងមកបម្រើការងារ។
- ការផ្លាស់ប្តូរគោលនយោបាយជាយថាហេតុរបស់ដៃគូអភិវឌ្ឍ ក្នុងការផ្តល់ជំនួយបច្ចេកទេសដល់កម្ពុជា ខណៈដែលស្ថានភាពសេដ្ឋកិច្ចសកលបាននិងកំពុងទទួលរងនូវឥទ្ធិពលពីសង្គ្រាមពាណិជ្ជកម្មនិងបច្ចេកវិទ្យា និងភាពតានតឹងនៃភូមិសាស្ត្រនយោបាយ។
- ភាពវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យាព័ត៌មានវិទ្យា និងភាពកាន់តែស្មុគស្មាញនៃវិស័យហិរញ្ញវត្ថុ ដែលអាចនឹងពិបាកក្នុងការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ឱ្យស្របទៅតាមការវិវត្តជាក់ស្តែង។

# ជំពូកទី៤
# ផែនការសកម្មភាពក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស
# ២០២៣ - ២០២៨

ក្នុងគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ពាក់ព័ន្ធនឹងការអភិវឌ្ឍមូលបត្ររដ្ឋ សំដៅគ្រប់គ្រងការបោះផ្សាយ និងការជួញដូរមូលបត្ររដ្ឋ ប្រកបដោយតម្លាភាព, គណនេយ្យភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធភាព ព្រមទាំងធានាបាននូវចីរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ត្រូវអនុវត្តផែនការសកម្មភាព ដូចតទៅ៖

## ៤.១. ផែនការសកម្មភាពក្នុងការពង្រឹងសមត្ថភាពស្ថាប័ន

- ជ្រើសរើសមន្ត្រី និងមន្ត្រីកិច្ចសន្យាថ្មី ដែលមានសមត្ថភាព និងធន្ទះវិជ្ជាជីវៈខ្ពស់បន្ថែមទៀត ប្រកបដោយតម្លាភាព និងភាពប្រកួតប្រជែង ឱ្យស្របតាមទំហំការងារ និងតម្រូវការជំនាញជាក់ស្តែង។
- អនុវត្តវិធានការចាំបាច់នានាក្នុងការរក្សាទុកមន្ត្រីមានសមត្ថភាព និងធន្ទះវិជ្ជាជីវៈខ្ពស់ ដែលមានស្រាប់ឱ្យនៅបំពេញការងារ ដើម្បីបន្តនិរន្តរភាព តាមរយៈការបង្កើតកាលានុវត្តភាពសម្រាប់ការវិវឌ្ឍអាជីពរបស់មន្ត្រី ទាំងក្នុងមុខដំណែងរដ្ឋបាល និងវិជ្ជាជីវៈ ព្រមទាំងតែងតាំងមន្ត្រីឱ្យកាន់មុខដំណែង ដោយផ្អែកលើសមត្ថភាព, បុគ្គលិកលក្ខណៈ, និងអតីតភាពការងារ។
- បែងចែកមន្ត្រីផ្អែកលើគុណវុឌ្ឍិ, ជំនាញ, និងការចង់បានរបស់មន្ត្រី ដើម្បីធានាបាននូវការប្រើប្រាស់ចំជំនាញ និងមានប្រសិទ្ធភាព។
- ពិនិត្យឡើងវិញ និងកែសម្រួលតួនាទីភារកិច្ច នៃការិយាល័យជួរមុខ សម្រាប់ការគ្រប់គ្រងបំណុលសាធារណៈក្នុងប្រទេស ស្របតាមតម្រូវការជាក់ស្តែង និងឧត្តមានុវត្តន៍ជាអន្តរជាតិ។
- កសាង និងពង្រឹងប្រព័ន្ធលើកទឹកចិត្ត ទាំងហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសម្បូរបែប ដែលជំរុញលើកទឹកចិត្តមន្ត្រីឱ្យសកម្ម និងបុរេសកម្មការងារ និងអនុវត្តប្រព័ន្ធនេះ ប្រកបដោយតម្លាភាព ព្រមទាំងត្រូវពង្រឹងប្រព័ន្ធ និងយន្តការតាមដានវាយតម្លៃសមិទ្ធកម្ម ដើម្បីជាមូលដ្ឋានសម្រាប់ការផ្តល់ការលើកទឹកចិត្ត។
- អនុវត្តការងារជាក្រុម ប្រកបដោយវិជ្ជាជីវៈ និងគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ, ប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និងគោលការណ៍ប្រសិទ្ធភាពថវិកា, និងរៀនផង-ធ្វើផង។

## ៤.២. ផែនការសកម្មភាពក្នុងការពង្រឹងសមត្ថភាពធនធានមនុស្ស

- បំពាក់បំប៉នសមត្ថភាពមន្ត្រីពាក់ព័ន្ធ តាមអភិក្រម ដូចខាងក្រោម៖
  - **ការបណ្តុះបណ្តាលក្នុងប្រទេស** ដែលរួមមាន៖ ១) ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញ ដែលបង្ហាត់បង្ហាញ ដោយជំនាញការអន្តរជាតិ ឬមន្ត្រីស្ថាប័នជំនាញអន្តរជាតិ, ២) ការរៀបចំសិក្ខាសាលា, វេទិកា, ឬសន្និសីទ ដោយមានការចូលរួមពីជំនាញការជាតិ អន្តរជាតិ ឬមន្ត្រីជំនាញនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ, ៣) ការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា វេទិកាពាក់ព័ន្ធ, និង ៤) ការសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត។
  - **ការបណ្តុះបណ្តាលក្រៅប្រទេស** ដែលរួមមាន៖ ១) ការចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ដែលរៀបចំដោយអង្គការ-ស្ថាប័នក្នុងតំបន់ ឬអន្តរជាតិនានា, ២) ការចូលរួមសិក្ខាសាលា, វេទិកា ឬសន្និសីទក្នុងតំបន់ ឬអន្តរជាតិ លើប្រធានបទជំនាញពាក់ព័ន្ធ, ៣) ការធ្វើទស្សនកិច្ចសិក្សា នៅតាមក្រសួង ស្ថាប័នជំនាញនៃប្រទេសក្នុងតំបន់ និងប្រទេសជឿនលឿននានាលើសកលលោក, និង ៤) ការចូលរួមកម្មវិធីហាត់ការរបស់ស្ថាប័នជំនាញអន្តរជាតិ។

បន្ថែមលើនេះ, ត្រូវរៀបចំឱ្យមានកម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុង ដើម្បីជាការចែករំលែកចំណេះដឹងបន្តពីមន្ត្រីដែលបានចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេស ដល់មន្ត្រីពាក់ព័ន្ធផ្សេងទៀត។

- យកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពធនធានមនុស្ស លើមុខជំនាញពាក់ព័ន្ធសំខាន់ៗ ដូចជា៖
    - **ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ**
        - ការរៀបចំលិខិតបទដ្ឋានគតិយុត្ត, គោលនយោបាយ និងយុទ្ធសាស្ត្រពាក់ព័ន្ធ
        - ការរៀបចំផែនការបោះផ្សាយលក់មូលបត្ររដ្ឋ (Issuance Plan)
        - វិធីសាស្ត្របោះផ្សាយលក់មូលបត្ររដ្ឋ (Issuance Method)
        - ការអភិវឌ្ឍឧបករណ៍មូលបត្ររដ្ឋ (Product Development)
        - ទំនាក់ទំនងវិនិយោគិន (Investor Relations)
        - ទំនាក់ទំនងសាធារណៈ និងការចរចា (Public Relations and Negotiation)
        - ហេដ្ឋារចនាសម្ព័ន្ធគាំទ្រទីផ្សារហិរញ្ញវត្ថុ (Financial Market Infrastructure)
        - ការបោះផ្សាយមូលបត្ររដ្ឋតាមវិស័យ (Thematic Bond Issuance)
        - ការបោះផ្សាយមូលបត្ររដ្ឋនៅក្រៅប្រទេស (International Bond Issuance)
        - ការវាយតម្លៃចំណាត់ថ្នាក់ឥណទាន (Credit Rating)
        - នីតិវិធីប្រតិបត្តិការសម្រាប់ការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ(Issuance and Trading Procedures)
        - ការគ្រប់គ្រងមូលបត្ររដ្ឋ (Government Securities Management)
        - ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គ្រប់គ្រងការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ (Government Securities Management System)
        - ការគ្រប់គ្រងទិន្នន័យមូលបត្ររដ្ឋ(Government Securities Database Management)
        - ការគ្រប់គ្រងគម្រោង, ហិរញ្ញវត្ថុគម្រោង, លទ្ធកម្មគម្រោង ក្រោមក្របខ័ណ្ឌហិរញ្ញប្បទានពីការបោះផ្សាយលក់មូលបត្ររដ្ឋ (Proceeds Management)
        - ការអភិវឌ្ឍទីផ្សារបន្ទាប់ (Secondary Market)
        - ការអភិវឌ្ឍទីផ្សាររូបិយវត្ថុ (Money Market)។
    - **ការវិភាគ និងគ្រប់គ្រងហានិភ័យ**
        - ការគណនាថ្លៃមូលបត្ររដ្ឋ និងអត្រាគូប៉ុង (Bond Price/Coupon Calculation)
        - ការស្រាវជ្រាវ និងវិភាគទីផ្សារ (Market Research and Analysis)
        - ការបង្កើត និងវិភាគខ្សែកោងទិន្នផល (Yield Curve Calculation and Analysis)
        - ការវិភាគចីរភាពបំណុល (Debt Sustainability Analysis – DSA)
        - ការវិភាគចង្កោមបំណុល (Debt Portfolio Analysis – DPA)
        - ការវិភាគថ្លៃ និងហានិភ័យ (Cost at Risk – CaR and Value at Risk – VaR)
        - ការគ្រប់គ្រងហានិភ័យ និងអនុលោមភាពពាក់ព័ន្ធនឹងការបោះផ្សាយ និងជួញដូរមូលបត្ររដ្ឋ (Risk Management and Compliance)
        - ការរៀបចំយន្តការបញ្ចៀស ឬបង្ការការខាតបង់តម្លៃហិរញ្ញវត្ថុ (Hedging Mechanism)។

- **<u>មុខជំនាញពាក់ព័ន្ធផ្សេងទៀត</u>**
  - មូលដ្ឋានគ្រឹះម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយរូបិយវត្ថុ (Fundamentals of Macroeconomics and Monetary Policy)
  - មូលដ្ឋានគ្រឹះទីផ្សារហិរញ្ញវត្ថុ (Fundamentals of Financial Market)
  - ការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management)
  - ការគ្រប់គ្រងហិរញ្ញវត្ថុ និងបំណុលសាធារណៈ (Public Finance and Debt Management)
  - ស្ថិតិ និងការវិភាគទិន្នន័យ (Statistics and Data Analysis)
  - ឧបករណ៍គាំទ្រការវិភាគ (Analytical Tools)
  - ការគ្រប់គ្រងសាច់ប្រាក់ និងថវិកា (Cash Management and Budgeting)
  - នីតិវិធីពន្ធដារ (Taxation)។ល។

# ជំពូកទី៥
# គម្រោងប៉ាន់ស្មានថវិកាចំណាយ សម្រាប់ការបន្តពង្រឹងសមត្ថភាពស្ថាប័ន និង ធនធានមនុស្ស ២០២៣ - ២០២៨

*ឯកតា៖ ពាន់ដុល្លាអាមេរិក*

| ផែនការសកម្មភាព | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ | ឆ្នាំទី៦ | សរុប |
|---|---|---|---|---|---|---|---|
| ១) ក្នុងប្រទេស | ១២៥ | ១២៥ | ១២៥ | ១២៥ | ១២៥ | ១២៥ | ៧៥០ |
| ក) វគ្គបណ្ដុះបណ្ដាលជំនាញ | ៦០ | ៦០ | ៦០ | ៦០ | ៦០ | ៦០ | ៣៦០ |
| ខ) សិក្ខាសាលា | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ១៨០ |
| គ) វេទិកា | ២០ | ២០ | ២០ | ២០ | ២០ | ២០ | ១២០ |
| ឃ) សន្និសីទ | ១០ | ១០ | ១០ | ១០ | ១០ | ១០ | ៦០ |
| ង) ការសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត | ៥ | ៥ | ៥ | ៥ | ៥ | ៥ | ៣០ |
| ២) ក្រៅប្រទេស | ២៥០ | ២៥០ | ២៥០ | ២៥០ | ២៥០ | ២៥០ | ១៥០០ |
| ក) វគ្គបណ្ដុះបណ្ដាលជំនាញ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ៥០ | ៣០០ |
| ខ) សិក្ខាសាលា | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ២៤០ |
| គ) វេទិកា | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ១៨០ |
| ឃ) សន្និសីទអន្តរជាតិ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ១៨០ |
| ង) ទស្សនកិច្ចសិក្សា | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ១០០ | ៦០០ |
| **សរុប (១+២)៖** | **៣៧៥** | **៣៧៥** | **៣៧៥** | **៣៧៥** | **៣៧៥** | **៣៧៥** | **២២៥០** |

# សមាសភាព

# ក្រុមការងាររៀបចំ

# ក្របខ័ណ្ឌគោលនយោបាយ

# ស្តីពី

# ការអភិវឌ្ឍមូលបត្ររដ្ឋ

# ២០២៣ - ២០២៨

**«ក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣ - ២០២៨»** ត្រូវបានវិភាគ និងតាក់តែង ដោយលេខាធិការដ្ឋាន នៃក្រុមការងារបច្ចេកទេសរៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ហៅកាត់ថា **«ក.ម.រ.»** ក្រោមការណែនាំជារួមរបស់ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាន **ក.ម.រ.** ព្រមទាំងការដឹកនាំផ្ទាល់របស់ឯកឧត្តម **ប៉ែន ធីរុទ្ធ** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានប្រចាំការ **ក.ម.រ.** ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | លោក **ម៉ាង សុភារ៉ា** | អគ្គនាយករង នៃ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ គ្រប់គ្រងបំណុល (អ.ស.ប.) និងជាប្រធានលេខាធិការដ្ឋាន |
| ២- | លោក **ឃឹម ហ្វាដាណេ** | អគ្គនាយករង នៃ អ.ស.ប. |
| ៣- | លោកស្រី **ឈុន ទីរៈវឌ្ឍនា** | ប្រធាននាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ៤- | លោក **ខៀវ ណាវ៉ា** | ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាបំណុល |
| ៥- | លោក **ខៀង សុខតីរម្យ** | ប្រធាននាយកដ្ឋានមូលបត្ររដ្ឋ |
| ៦- | លោកស្រី **គុណា ម៉ាលីនាថ** | អនុប្រធាននាយកដ្ឋានមូលបត្ររដ្ឋ |
| ៧- | លោកស្រី **ឌុន មុនីតា** | អនុប្រធាននាយកដ្ឋានវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ៨- | លោក **អ៊ុន ពិសិដ្ឋ** | មន្ត្រីជំនាញផ្នែកមូលបត្ររដ្ឋ |
| ៩- | លោក **សៀម ពេជ្រណារៈ** | មន្ត្រីជំនាញផ្នែកមូលបត្ររដ្ឋ |
| ១០- | លោកស្រី **គង់ យ៉ាដា** | មន្ត្រីជំនាញផ្នែកមូលបត្ររដ្ឋ |
| ១១- | កញ្ញា **ខឿន វត្តីឆត្រីស្តីនា** | មន្ត្រីជំនាញផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ១២- | កញ្ញា **លឹម លីចេង** | មន្ត្រីជំនាញផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |
| ១៣- | កញ្ញា **គន ណាម៉ូនិច** | មន្ត្រីជំនាញផ្នែកមូលបត្ររដ្ឋ |
| ១៤- | កញ្ញា **ជួន មុនីមធុរត្ន** | មន្ត្រីជំនាញផ្នែកមូលបត្ររដ្ឋ |
| ១៥- | លោក **ប៉ែន ម៉ុនថង** | មន្ត្រីជំនាញផ្នែកវិភាគ និងគ្រប់គ្រងហានិភ័យបំណុល |

ទាញយកឯកសារ

តាមរយៈ QR Code


**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អាសយដ្ឋាន៖ ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ, រាជធានីភ្នំពេញ

Email: admin@mef.gov.kh

Hotline: (855) 23 890 666